# វគ្គទី ៥
# សម្រែកស្រែករកសេរីភាព
# (ទសវត្សរ៍ឆ្នាំ ១៩៨០)

មួយឆ្នាំបន្ទាប់ពីជ័យជំនះរបស់ខ្មែរក្រហមមក សហគមន៍ខ្មែរនៅប្រទេសបារាំងបានឃើញសភាពការណ៍កាន់តែច្បាស់ឡើងនៅក្នុងប្រទេសកម្ពុជា ។ របបខ្មែរក្រហមបានក្លាយទៅជារបបផ្តាច់ការមួយ ដែលប្រព្រឹត្តអំពើសាហាវយង់ឃ្នង និង អមនុស្សធម៌ជាទីបំផុតនៅក្នុងពិភពលោក ដែលពួកនេះមិនអាចប្រកែកបានឡើយ ។ ជនភៀសខ្លួនខ្មែរទាំងឡាយ ដែលបន្តិចម្តងៗនាំគ្នារត់ចេញពីប្រទេសកម្ពុជាបាននាំមកជាមួយពីមួយថ្ងៃទៅមួយថ្ងៃនូវភ័ស្តុតាងយ៉ាងច្បាស់ក្រឡែតពីអំពើព្រៃផ្សៃនៃរបបខ្មែរក្រហមនោះ ។ ជនភៀសខ្លួនទាំងនោះ បានរៀបរាប់យ៉ាងលំអិតអំពីជីវភាពប្រចាំថ្ងៃដ៏លំបាកអស្ចារ្យ អំពីការបង្អត់អាហារ និង អំពីការកាប់សម្លាប់ទៅលើជនស្លូតត្រង់ ដែលពួកខ្មែរក្រហមបានធ្វើយ៉ាងយង់ឃ្នងបំផុត ។ ជនរួមជាតិខ្មែរដែលតាមដានសភាពការណ៍នៅកម្ពុជាយល់ច្បាស់ណាស់ថា គេពុំអាចសង្ឃឹមថា អ្នកដឹកនាំខ្មែរក្រហមអាចនឹងផ្តល់នូវសេរីភាព សិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្សជូនប្រជាពលរដ្ឋខ្មែរបានឡើយ ។ ជាពិសេស ជនរួមជាតិទាំងនោះមិននឹកសង្ឃឹមថា អ្នកដឹកនាំខ្មែរក្រហមអាចនឹងបើកចំហរប្រទេស ឲ្យមានទំនាក់ទំនងជាមួយពិភពលោកសោះឡើយ ។ ជាប្រពៃណីរៀងមក ជនរួមជាតិខ្មែរដែលជាពុទ្ធសាសនិកជនតែងរត់ទៅជ្រកក្រោមម្លប់ព្រះពុទ្ធសាសនា នៅពេលដែលជួបប្រទះទុក្ខព្រួយណាមួយ ដោយចិញ្ចឹមកូនចិត្តថាពេលវេលាធូរស្រាលក្នុងជីវិត និង អនាគតភ្លឺស្វាងអាចនឹងកើតមកវិញ នៅថ្ងៃណាមួយមិនខាន។ នៅប្រទេសបារាំង បងប្អូនជន

រួមជាតិទាំងនោះនាំគ្នាទៅវត្តអារាម ដើម្បីបង្កើតឡើងវិញនូវប្រព័ន្ធទំនាក់ទំនងគ្នាផ្នែកសង្គមនៅគ្រាដំបូង និង ជាប្រព័ន្ធទំនាក់ទំនងផ្នែកនយោបាយនៅគ្រាបន្ទាប់ ។ ដោយសារការគ្រប់គ្រងប្រទេសដ៏ចម្លែករបស់ពួកខ្មែរក្រហម ខ្មែរនៅប្រទេសបារាំងគ្រប់ជាន់ថ្នាក់ក៏ដូចជាប្រជាពលរដ្ឋខ្មែរភាគច្រើននៅឯប្រទេសកម្ពុជាដែរ បានបាត់បង់នូវអ្វីៗទាំងអស់ ជាពិសេសគឺ ការបាត់បង់ទឹកដី ធ្វើឲ្យពួកគេក្លាយជាមនុស្ស ឬក្រុមអ្នកអត់ស្រុក ឬ អ្នកអត់នគរ ។

## ជាតិជាជនភៀសខ្លួន គ្មានអ្នកតូច គ្មានអ្នកធំ

មន្ត្រីជាន់ខ្ពស់រាប់តាំងពីរដ្ឋមន្ត្រី អ្នកការទូត ឧត្តមសេនីយ នាយទាហាន ឬក៏អ្នកធ្វើការធម្មតា ឬ កូនទាហាន សុទ្ធតែធ្លាក់ខ្លួនទៅជាជនភៀសខ្លួន ដែលមានសិទ្ធិប្រហាក់ប្រហែលៗគ្នា ។ នៅប្រទេសបារាំង មនុស្សជាទូទៅមានអារម្មណ៍ថាពួកគេស្ថិតនៅក្នុងសភាពការណ៍ដូចៗគ្នា មានសិទ្ធិស្មើៗគ្នា ដែលគ្មានអ្នកតូច អ្នកធំ អ្នកខ្ពស់ អ្នកទាប ដូចសម័យមុនឡើយ ។

ដើម្បីផ្តល់ទស្សនៈរបស់ខ្លួនលើអនាគតប្រទេសកម្ពុជា ឬ ដើម្បីបញ្ចេញមតិស្តីពីការកសាងជាតិឡើងវិញ អ្នកនយោបាយជើងចាស់មួយចំនួនយកវេទិកានៃពិធីបុណ្យសាសនាជាដើម ដើម្បីសំដែងមតិទាំងនោះ ឲ្យសាធារណជនបានដឹងឮ ។ ក្នុងចំណោមអ្នកនយោបាយជើងចាស់ទាំងនោះ មានលោកតា សឺន សាន ដែលជាអតីតរដ្ឋមន្ត្រីទីមួយរបស់សម្តេច សីហនុ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ដែលបានសាកល្បងដោយបរាជ័យក្នុងការធ្វើជាមេអណ្តើកផ្សះផ្សាគ្នា ស្វែងរកដំណោះស្រាយវិបត្តិកម្ពុជាដោយសន្តិវិធីនៅទសវត្សរ៍ឆ្នាំ ១៩៧០ ។ ពេលមួយនោះ លោកតា សឺន សាន បានចូលរួមក្នុងពិធីបុណ្យព្រះពុទ្ធសាសនាមួយ ។ គាត់និយាយថារបបខ្មែរ

ក្រហមជារបបមួយ ដែលនឹងដើរទៅដល់ជញ្ជាំង ហើយលោកតាអំពាវនាវឲ្យសហគមន៍ខ្មែរនៅប្រទេសបារាំងត្រៀមខ្លួនទៅបន្តវេន នៅពេលដែលខ្មែរក្រហមដួលរលំនៅថ្ងៃណាមួយពុំខាន ។ ពាក្យថា ខ្មែរក្រហមដើរទៅដល់ជញ្ជាំង ក៏ចូលទៅក្នុងខួរក្បាលខ្មែរមួយចំនួនធំ ។ ក៏ប៉ុន្តែអ្នកនយោបាយមួយចំនួន និយាយផ្ទុញ់ឲ្យលោកតា សឺន សាន ថាខ្មែរក្រហមមិនគ្រាន់តែដល់ជញ្ជាំងទេ តែវានឹងបុកទម្លាយជញ្ជាំងនោះ ។

នៅសម័យនោះ ខ្ញុំហាក់ដូចជាមិនសូវអើពើនឹងបុណ្យទានខាងផ្នែកព្រះពុទ្ធសាសនាប៉ុន្មានឡើយ ។ ក៏ប៉ុន្តែ ឃឹម ខាន់កែវ និង តឹកលីន ច្រើនតែនិយាយឲ្យខ្ញុំដឹងនូវអ្វីៗដែលកើតឡើង ឬ ព្រឹត្តិការណ៍សង្គមទាំងឡាយ ដែលសហគមន៍ខ្មែរនៅប្រទេសបារាំងបានចាត់ចែងឡើង ។ ពួកគេបាននិយាយប្រាប់ខ្ញុំអំពីទស្សនៈលោកតា សឺន សាន ក្នុងការថែរក្សាការពារនូវអត្តសញ្ញាណខ្មែរ និង អំពីការកសាងប្រទេសកម្ពុជាឡើងវិញ ។ ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះទស្សនៈជាតិនិយម និង ការកសាងប្រទេស និង សង្គមជាតិឡើងវិញណាស់ ។ យ៉ាងណាក៏ដោយ ខ្ញុំហាក់ដូចជាចង់ដឹងថា តើខ្មែរយើងដែលរស់នៅក្រៅប្រទេស អាចធ្វើសកម្មភាពអ្វីបានខ្លះ ដើម្បីធ្វើឲ្យប្រទេសកម្ពុជាយើងវិលត្រឡប់មករកមាគ៌ាដ៏ត្រឹមត្រូវវិញ ។

ហេតុដូច្នេះ ទើបខ្ញុំស្នើឲ្យ ឃឹម ខាន់កែវ និង តឹកលីន នាំខ្ញុំទៅជួបលោកតា សឺន សាន ភ្លាមៗដោយពុំមានគ្រោងទុកជាមុន ។ ថ្ងៃមួយនោះ យើងនាំគ្នាទៅផ្ទះលោកតា សឺន សាន នៅផ្ទះលេខ ៤៥ ស្ពួន ផ្លូវអាកាស្យា ក្នុងសង្កាត់ ១៧ ទីក្រុងប៉ារីស ដែលជាសង្កាត់អភិជនមួយប្រកបដោយសណ្តាប់ធ្នាប់ហើយក៏មិននៅឆ្ងាយពីវិមាន ហ្សាល ដឺ ហ្គោល ដែរ ។ យើងគោះទ្វារផ្ទះ និង សាកសួរចង់ជួបលោកតា សឺន សាន ក៏ប៉ុន្តែមានសម្លេងមួយឆ្លើយពីក្នុងផ្ទះមកថា "លោកមិននៅទេ" ។ នៅពេលនោះ ខ្ញុំដូចជាចង់ជួបលោកតាមែនទែន ។ ក៏ប៉ុន្តែ ខ្ញុំមិនអាចទៅជួបលោក

តាបានស្រួលៗយ៉ាងដូច្នេះទេ ព្រោះគាត់ជាមនុស្សសំខាន់ ជាអ្នកធំម្នាក់ ។ តាមធម្មតា យើងត្រូវទូរស័ព្ទទៅមុន ដើម្បីសុំណាត់ជួប ។

## សឺន សាន ជានរណា?

លោកតា សឺន សាន មានដើមកំណើតចេញពីគ្រួសារខ្មែរដ៏ចំណាស់មួយនៅកម្ពុជាក្រោម (ខ្មែរនៅកូសាំងស៊ីនផ្នែកខាងត្បូងនៃប្រទេសវៀតណាម) ។ តាមជីវប្រវត្តិផ្លូវការ លោកតា សឺន សាន កើតថ្ងៃទី ០៥ តុលា ១៩១១ នៅទីក្រុងភ្នំពេញមិនមែននៅកម្ពុជាក្រោមដូចអ្នកខ្លះជឿនោះទេ ។ លោកតា និយាយភាសាខ្មែរ ដោយមិនមានសំនៀងខ្មែរកម្ពុជាក្រោមទេ តែមានសំនៀងដូចជនជាតិវៀតណាមនិយាយខ្មែរ ពីព្រោះតាំងពីតូច លោកតារស់នៅជាមួយមេដោះជនជាតិវៀតណាម[52] ។ លោកឪពុករបស់លោកតាគឺ លោកឧកញ៉ា សឺន សាច់ ដែលបានចេញពីកម្ពុជាក្រោមមកទីក្រុងភ្នំពេញ ដើម្បីបន្តការសិក្សាក្រោមការឧបត្ថម្ភ របស់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សុផានុវង្ស ។ ក្រោយមកឧកញ៉ា សឺន សាច់ បានទៅធ្វើការផ្ទាល់ជាមួយព្រះអង្គម្ចាស់ នរោត្តម សុរាម្រឹត កាលព្រះអង្គមិនទាន់ឡើងគ្រងរាជ្យនៅឡើយ ហើយដែលកាលនោះទ្រង់កាន់តំណែងជារដ្ឋមន្ត្រីក្រសួងកសិកម្ម ។ ព្រះករុណាព្រះបាទ នរោត្តម សុរាម្រឹត ជាព្រះវររាជបិតានៃ សម្តេច សីហនុ ។ គ្រួសារត្រកូល សឺន ជាគ្រួសារមួយដែលខ្មែរកម្ពុជាក្រោមភាគច្រើនស្គាល់ស្ទើរទាំងអស់ ព្រោះជាត្រកូលល្បីល្បាញមួយ ដែលចេញពីបុព្វបុរសម្នាក់ឈ្មោះចៅហ្វាយ គុយ ។

---

[52] នេះជារឿងដំណាលប្រាប់ខ្ញុំ ដោយស្ត្រីជំនឹតម្នាក់របស់លោកតា សឺន សាន កាលពួកយើងនៅជួបជុំគ្នានាចុងទសវត្សរ៍ឆ្នាំ ១៩៧០ នៅប្រទេសបារាំង ។

លោកចៅហ្វាយ គុយ ជាចៅហ្វាយស្រុកព្រះត្រពាំង បានសុខចិត្តបូជាជីវិតប្តូរនឹងការថែរក្សានូវព្រះពុទ្ធសាសនាថេរវាទសំរាប់ជនរួមជាតិខ្មែរកម្ពុជាក្រោម ។

កាលនៅពីក្មេងលោក សឺន សាន ជាយុវជនខ្មែរមួយរូប ដែលបានប្រឡងជាប់សញ្ញាប័ត្រពីសាលាដ៏ល្បីល្បាញរបស់បារាំងមួយឈ្មោះថា សាលាជាន់ខ្ពស់ខាងពាណិជ្ជកម្ម (H.E.C: Hautes Etudes Commerciales)ក្នុងឆ្នាំ ១៩៣៣ ។ នៅឆ្នាំ ១៩៣៤ ពេលត្រឡប់មកពី ប្រទេសបារាំងវិញ លោក សឺន សាន ត្រូវបានទទួលតំណែងជាអភិបាលរងខេត្តបាត់ដំបង[53] ។ ពីឆ្នាំ ១៩៣៧ ដល់ឆ្នាំ ១៩៣៩ គាត់បានផ្លាស់ទៅធ្វើជាអភិបាលរងខេត្តព្រៃវែង ដែលជាខេត្តកំណើតរបស់ខ្ញុំ ។ ដោយគាត់មានបំណងចង់ប្រើប្រាស់នូវចំណេះវិជ្ជា ដែលគាត់រៀនខាងផ្នែកពាណិជ្ជកម្ម លោក សឺន សាន បានលាឈប់ពីរាជការ មកធ្វើការក្នុងក្រុមហ៊ុនរបស់ឪពុកក្មេកក្នុងក្រុមហ៊ុន ឡឺ ប៉ឺទី ប៉ារីស (Le Petit Paris) ។ ក្នុងឆ្នាំ ១៩៤០ នៅពេលដែលជប៉ុនចរចាជាមួយបារាំង ដើម្បីទិញអង្ករខ្មែរ អាជ្ញាធរបារាំងក៏បានចាត់តាំងលោកឲ្យចូលរួមក្នុងគណៈប្រតិភូបារាំងទៅកាន់ទីក្រុងតូក្យូ ។

នៅឆ្នាំ ១៩៤៦ ក្រោមការដឹកនាំរបស់ព្រះអង្គម្ចាស់ យុត្តិវង្ស រដ្ឋាភិបាលរបស់គណបក្សប្រជាធិបតេយ្យក៏បានត្រូវបង្កើតឡើង ឯលោក សឺន សាន ក៏ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ។ ចាប់តាំងពីឆ្នាំ ១៩៤៦ រហូតដល់ឆ្នាំ ១៩៦៨ លោកកាន់តំណែងជារដ្ឋមន្ត្រីជាច្រើនលើកច្រើនគ្រា ជាពិសេសកាន់តំណែងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាឧបនាយករដ្ឋមន្ត្រី ជារដ្ឋមន្ត្រីក្រសួងការបរទេស និង ជារដ្ឋមន្ត្រីទី១ ។

[53] កាលសម័យនោះ គេហៅអភិបាលរងខែត្រថា ភូឈួយខែត្រ ។

នៅក្នុងជំនាន់សភាជាតិ ចេញពីគណបក្សប្រជាធិបតេយ្យពីឆ្នាំ ១៩៥១ ដល់ ១៩៥២ លោកត្រូវជាប់ឆ្នោត ជាអ្នកតំណាងរាស្ត្រមណ្ឌលភ្នំពេញ និង ជាប្រធានរដ្ឋសភា ។ លោក សឺន សាន ជាអ្នកបង្កើតធនាគារជាតិកម្ពុជានៅឆ្នាំ ១៩៥៥ និង កាន់តំណែងជាទេសាភិបាលនៃធនាគារនេះរហូតដល់ឆ្នាំ ១៩៦៨ ។ លោក សឺន សាន ជាមនុស្សជិតដិតម្នាក់ដ៏កម្រ និង ជាទីប្រឹក្សាដ៏ទុកចិត្តម្នាក់ខាងផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់សម្តេច សីហនុ ក្នុងសម័យសង្គមរាស្ត្រនិយម ។ មនុស្សទុកចិត្តម្នាក់ទៀតគឺ សម្តេច ប៉ែន នុត ដែលបានរួមដង្ហែរសម្តេច សីហនុ ក្នុងពេលភៀសព្រះអង្គទៅរស់នៅក្នុងប្រទេសចិន និង បន្ទាប់មកដង្ហែរព្រះអង្គមករស់នៅប្រទេសកម្ពុជា ក្រោមរបបខ្មែរក្រហមទៀតផង ។

លោកតា សឺន សាន ជាអ្នកកាន់ព្រះពុទ្ធសាសនា ។ កូនចៅលោកតានិយាយថា លោកតាចាប់ថ្វាយបង្គំព្រះយ៉ាងទៀងទាត់ តាំងពីពេលដែលកូនប្រុសច្បងរបស់គាត់បានស្លាប់ ក្នុងគ្រោះថ្នាក់ចរាចរណ៍មួយក្នុងប្រទេសកម្ពុជា និង តាំងពីពេលដែលលោកលាលែងពីតំណែងរាជការក្នុងឆ្នាំ ១៩៦៨ ។ នៅក្នុងប្រទេសបារាំងសម័យទស្សវត្សរ៍ឆ្នាំ ១៩៧០ នោះ មនុស្សជាច្រើននិយាយថាលោកតាថ្វាយបង្គំព្រះ មួយថ្ងៃពីរដង ហើយគាត់វៀរចាកមិនពិសាស្រាទេ ទោះបីជាគាត់ធ្លាប់ពិសាស្រាល្អៗយ៉ាងណាក៏ដោយ ។ នៅសម័យនោះ ទោះបីជានៅប្រទេសបារាំងក៏ដោយ ក៏លោកតា សឺន សាន នៅមានការគោរពរាប់អានពីជនរួមជាតិខ្មែរមួយភាគដែរ ដែលធ្លាប់ធ្វើជាមន្ត្រីរាជការ ។ នៅខែ មិថុនា ១៩៧៦ លោកតា សឺន សាន បានបង្កើតសមាគមមួយដែលមានឈ្មោះហៅថា សមាគមទូទៅខ្មែរនៅបរទេស ហៅកាត់ថា អា ហ្សេ កា អឺ (AGKE: Association Générale des Khmers à l'Etranger) ។

# សមាគមទូទៅខ្មែរនៅបរទេស

លក្ខន្តិកៈនៃសមាគមបានគូសបញ្ជាក់នូវគោលបំណងដូចតទៅ៖ "ថែរក្សាព្រះពុទ្ធសាសនា វប្បធម៌ និង អារ្យធម៌ខ្មែរ គាំទ្រពង្រឹងឯកភាពជាតិ និង ភាតរភាពរវាងខ្មែរទាំងអស់ និង ផ្តល់នូវការជួយសង្គ្រោះគ្នា ទាំងខាងស្មារតី ទាំងផ្លូវចិត្ត ទាំងផ្លូវកាយ និង ផ្លូវសម្ភារៈ" ។ ក្នុងចំណោមស្ថាបនិករបស់សមាគមទាំងអស់ ខ្ញុំសង្កេតឃើញមានឥស្សរជនជាច្រើន ដែលខ្លះធ្លាប់កាន់តំណែងជានាយករដ្ឋមន្ត្រី ជារដ្ឋមន្ត្រី ឬ មន្ត្រីជាន់ខ្ពស់នៃរបប សីហនុ និង របប លន់ នល់ ដូចជា៖ ឯ.ឧ. ទេព ផន ឯ.ឧ. ស៊ឹម វ៉ា ឯ.ឧ. នង គឹមនី ឯ.ឧ. យ៉ែម សំបូរ ឯ.ឧ. ចាយ ធុល ឯ.ឧ. អ៊ិន តាំ ឯ.ឧ. សុន វ៉ុនសៃ ឯ.ឧ. ជុន អ៊ុក ឯ.ឧ. សុខ ឆុង ឯ.ឧ. គន់ រ៉ិច ឧត្តមសេនីយ គង់ ធុច ឧត្តមសេនីយ ស្រី សាម៉ន លោក ជួន អ៊ិន លោក កែ ណុល លោក នេត្រ គួន លោក សាយ បូរី លោក សាយ បូរាណ លោក នាង ផង់ លោក ទ្រឿង មាលី វេជ្ជ. សិប ហៀង អ្នកស្រី ថៃន ជឿន អ្នកស្រី សួនកាសេត ។ល។ សមាជិកភាពនេះ ធ្វើឲ្យមានការចាប់អារម្មណ៍ណាស់ ដែលហាក់បង្ហាញឲ្យឃើញថា សមាគមនេះបានប្រមូលផ្តុំនូវមន្ត្រីជាន់ខ្ពស់ អ្នកនយោបាយ និង បញ្ញវន្តមិនមែនកុម្មុយនីស្តមួយចំនួនធំ ។ ក្នុងសម័យនោះ សមាគម អា ហ្សេ កា អឺ ជាសមាគមខ្មែរតែមួយគត់ ដែលមានលក្ខណៈគួរឲ្យទុកចិត្តបាននៅក្នុងប្រទេសបារាំង ហើយដែលបានធ្វើឲ្យមានការចូលរួមពីសំណាក់ខ្មែរអ្នកជាតិនិយមទាំងអស់ រាប់តាំងពីអ្នករាជានិយម អ្នកប្រជាធិបតេយ្យ រហូតដល់អ្នកស្រឡាញ់ សាធារណរដ្ឋផង ។ ដោយពុំទាន់មានវត្តមានរបស់សម្តេច សីហនុ លោកតា សឺន សាន បានត្រូវគេមើលឃើញថា ជាឥស្សរជនដ៏កម្រមួយរូបនៅក្រៅប្រទេស ដែលអាចប្រមូលការគាំទ្រពីប្រជាពលរដ្ឋខ្មែរបាន ។

# ខ្មែរក្រហមប្រមូលយកជ័យជំនះ ១៧ មេសា តែម្នាក់ឯង

បន្ទាប់ពីជោគជ័យរបស់គេនៅខែ មេសា ១៩៧៥ ពួកខ្មែរក្រហមមិនបានប្រញាប់ប្រញាល់យាង សម្តេច សីហនុ និង អញ្ជើញសម្តេច ប៉ែន នុត ដែលជាព្រះប្រមុខរដ្ឋ និង ជានាយករដ្ឋមន្ត្រីរបស់ពួកគេ ឲ្យនិវត្តចូលប្រទេសកម្ពុជាភ្លាមនោះឡើយ ។ ពួកខ្មែរក្រហមរង់ចាំរហូតដល់ពេលអ្នកដឹកនាំរបស់ពួកគេម្នាក់គឺ លោក ខៀវ សំផន មកធ្វើទស្សនកិច្ចនៅប្រទេសចិនក្នុងខែ សីហា ១៩៧៥ ទើបគេយល់ព្រមឲ្យសម្តេចយាងនិវត្តទៅកម្ពុជាវិញ ។ យោងតាមសេចក្តីថ្លែងការណ៍ផ្លូវការចុះថ្ងៃទី ១៨ សីហា ១៩៧៥ លោក ខៀវ សំផន បានជួបជាមួយមេដឹកនាំចិនគឺ លោក តេង ស៊ាវពីង និង លោក ហួរ គួហ្វេង ។

គណៈប្រតិភូរបស់ខ្មែរក្រហមកាលនោះមានជាអាទិ៍ លោក អៀង សារី ឧបនាយករដ្ឋមន្ត្រី លោក សារិន ឆាក រដ្ឋមន្ត្រីក្រសួងការបរទេស ភរិយាលោក អៀង សារី គឺ អ្នកស្រី អៀង ធិរិទ្ធ រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច លោក គាត ឈន់[54] និង លោក ជួន ប្រសិទ្ធ សមាជិកបំរុងនៃការិយាល័យនយោបាយរបស់គណៈកម្មាធិការកណ្តាលរណសិរ្សរួបរួមជាតិកម្ពុជា ។ ខ្ញុំជឿថាប្រហែលជាដោយមានអនុសាសន៍ពី លោក តេង ស៊ាវពីង ទើបនៅទីបំផុត ពួកខ្មែរក្រហមយល់ព្រមកំណត់ថ្ងៃ ខែ ពេល វេលា ដើម្បីសម្តេច សីហនុ និង សម្តេច ប៉ែន នុត យាង និង អញ្ជើញទៅប្រទេសកម្ពុជាវិញ ។ ពួកគេបានកំណត់យកថ្ងៃទី ៩ ខែ កញ្ញា ១៩៧៥ ជាថ្ងៃយាង និង អញ្ជើញនិវត្តនៃសម្តេចទាំងពីរ ទោះបីជាសមាជពិសេសរបស់ពួកគេដែលបានរៀបចំឡើង បន្ទាប់ពីជ័យជំនះនៅទីក្រុងភ្នំពេញ នៅថ្ងៃទី ២៥-២៦-២៧ មេសា

[54] នេះជាការលើកឡើងតាមបណ្តាញសារព័ត៌មានអន្តរជាតិដែលខ្ញុំបានអានប៉ុណ្ណោះ ជាពិសេសទីភ្នាក់ងារចិនថ្មី ឬ ស៊ីនហួ

១៩៧៥ បានទទួលស្គាល់ជាឯកច្ឆ័ន្ទថា "សម្តេច សីហនុ ជាព្រះប្រមុខរដ្ឋ និង ជាប្រធានរណសិរ្សរួមរួបជាតិកម្ពុជា ជាឥស្សរជនស្នេហាជាតិដ៏ឧត្តុង្គឧត្តមម្នាក់ ដែលបានរួមចំណែកធ្វើឲ្យបដិវត្តន៍របស់ពួកគេទទួលជោគជ័យ ក្នុងការតស៊ូរំដោះប្រទេសកម្ពុជាទាំងមូល" ។

# សម្តេច សីហនុ យាងទៅទីក្រុងញូវយ៉ក

នៅខែ កញ្ញា ១៩៧៥ ក្រោយដែលបានស្នាក់នៅមួយសប្តាហ៍ក្នុងប្រទេសកម្ពុជា សម្តេច សីហនុ ត្រូវបានអង្គការចាត់តាំងឲ្យយាងទៅទីក្រុងញីវយ៉ក (New York) ដើម្បីថ្លែងសុន្ទរកថានៅក្នុងអង្គការសហប្រជាជាតិក្នុងឋានៈព្រះអង្គជាព្រះប្រមុខរដ្ឋ ។ ក្នុងដំណើរយាងទៅអង្គការសហប្រជាជាតិនោះ សម្តេចត្រូវបានអមដំណើរដោយមន្ត្រីខ្មែរក្រហម និង បានយាងឆ្លងកាត់ប្រទេសបារាំង ។ នៅក្នុងប្រទេសបារាំងនោះ អ្នកយកព័ត៌មាននៃទូរទស្សន៍បារាំង បានធ្វើសម្ភាសន៍ជាមួយព្រះអង្គ ដើម្បីចង់ដឹងអំពីជីវភាពជាក់ស្តែងពិតប្រាកដនៃរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ។ កាលនោះ សម្តេចនៅការពាររបបខ្មែរក្រហមនៅឡើយ ដោយទ្រង់ពិពណ៌នាជីវភាពនៅទីក្រុងភ្នំពេញថា មានសន្តិភាពបរិបូណ៌ មានការរៀបចំល្អ មានសន្តិសុខពិតប្រាកដ ។ល។ សម្តេចមានបន្ទូលថា មុខងារព្រះអង្គជាប្រមុខរដ្ឋគឺ គ្រាន់បើជាងសម្តេចមហាក្សត្រីយានី អេលី ហ្សាប៉ែតទី ២ (Elisabeth II) នៃប្រទេសអង់គ្លេសបន្តិច ដោយហេតុថាព្រះអង្គអាចយាងបំពេញបេសកកម្មក្រៅប្រទេស ដូចជាឯកអគ្គរាជទូតគោចរមួយនៃប្រទេសកម្ពុជានៅក្នុងពិភពលោក ។ កាលនោះ ដោយទន្ទឹងរង់ចាំដំណឹងពីប្រទេសកម្ពុជាជាយូរមកហើយ ខ្ញុំបានត្រៀមរៀបចំកាមេរ៉ាភាព

យន្ត ១៦ មម ថតសេចក្តីសម្ភាសន៍របស់សម្តេច ពីទូរទស្សន៍បារាំង អង់តែន ២ ព្រោះនៅសម័យនោះ យើងពុំទាន់មានម៉ាស៊ីនថត វីស៊ីអែរ (VCR) នៅឡើយទេ ។

ក៏ប៉ុន្តែ នៅខែ តុលា ១៩៧៥ កាសែតរបស់បារាំងឈ្មោះ ឡឺហ្វីហ្គារ៉ូ (Le Figaro) និង ឡាគ្រ័រ (La Croix) បានចុះផ្សាយអត្ថបទពីរគឺ៖ មួយចុះថ្ងៃទី ១៥ ខែ តុលា ដែលសរសេរដោយលោក ហ្សង់ប៊ូដារីយ៉ា (Jean Boudaria) និង មួយទៀតចុះថ្ងៃទី ២៤ ដែលសរសេរដោយបុព្វជិតកាតូលីក ហ្វ្រង់ស័រ ប៉ុងសូ (François Ponchaud) ដែលធ្លាប់រស់នៅប្រទេសកម្ពុជាយ៉ាងយូរ ហើយក៏ជាអ្នកឯកទេសខាងបញ្ហាខ្មែរផងដែរ ។ អត្ថបទទាំងពីរបានរៀបរាប់អំពីការបំផ្លិចបំផ្លាញប្រទេសខ្មែរ ការកាប់សម្លាប់ និង ការបង្ខំឲ្យធ្វើការជាទម្ងន់ ដែលពួកខ្មែរក្រហមប្រព្រឹត្តមកលើប្រជាពលរដ្ឋខ្មែរ ។ ព័ត៌មានទាំងនោះ បានធ្វើឲ្យពិភពលោកទាំងមូលមានការភ្ញាក់ផ្អើលរំជើបរំជួលកាន់តែខ្លាំង ជាពិសេស សហគមន៍ខ្មែរនៅបរទេស ។ នៅខែ តុលា ១៩៧៥ មានការវាយតម្លៃថាមានជនភៀសខ្លួនចំនួនបួនម៉ឺននាក់បានមកដល់ប្រទេសថៃ ។

# ព្រះអង្គសុំលាលែងពីតំណែងប្រមុខរដ្ឋនៃរបបខ្មែរក្រហម

បន្ទាប់ពីដំណើរយាងទៅអង្គការសហប្រជាជាតិ សម្តេច សីហនុ ក៏យាងត្រឡប់ទៅភ្នំពេញយ៉ាងស្ងៀមស្ងាត់ ។ តាំងពីពេលនោះមក ពិភពលោកក៏លែងទទួលដំណឹងអ្វីសោះពីព្រះអង្គរហូតដល់ខែ មេសា ១៩៧៦ ។ ពេលនោះ សម្តេចទ្រង់បានផ្សព្វផ្សាយតាមវិទ្យុជាតិនូវការសុំលាលែងរបស់ព្រះអង្គ ពីតំណែងប្រមុខរដ្ឋនៃរបបខ្មែរក្រហម ។ នៅឆ្នាំនោះគឺ ឆ្នាំ ១៩៧៦ ពួកខ្មែរក្រហមបានជ្រើសរើស

រដ្ឋធម្មនុញ្ញថ្មី ដោយប្តូរឈ្មោះប្រទេសកម្ពុជាទៅជា "កម្ពុជាប្រជាធិបតេយ្យ" ដោយមានលោក ប៉ុល ពត ជានាយករដ្ឋមន្ត្រី ។ លោក ខៀវ សំផន ត្រូវបានជ្រើសរើសជាប្រធានរដ្ឋ (Président du Présidium) គឺប្រមុខរដ្ឋជំនួសសម្តេច សីហនុ ។ ពួកខ្មែរក្រហមសន្យាថា នឹងថ្វាយប្រាក់សោធនចំនួន ៨០០០ ដុល្លារ ក្នុងមួយឆ្នាំចំពោះព្រះអង្គ ក៏ប៉ុន្តែតាមពិតពួកខ្មែរក្រហមពុំបានចំណាយប្រាក់មួយដុល្លារណាតាមពាក្យសន្យានោះឡើយ ។ តាមព័ត៌មាន ដែលលេចចេញពីលោកខាងលិចថា ប៉ុន្មានអាទិត្យមុននឹងព្រះអង្គលាឈប់ពីតំណែងប្រមុខរដ្ឋ សម្តេច សីហនុ បានទទួលលោកឯកអគ្គរាជទូតនៃប្រទេសស៊ុយអែត ដែលបានរៀបរាប់អំពីជំនួបនោះនៅក្នុងបណ្តាញសារព័ត៌មានអន្តរជាតិ[55] ។ ចាប់ពីពេលនោះរហូតមក ពួកយើងនៅខាងក្រៅកម្រនឹងបានទទួលព័ត៌មានអំពីព្រះអង្គ ឬ ពីសហការីរបស់ព្រះអង្គណាស់ ដោយនៅពេលនោះ ពួកខ្មែរក្រហមកំពុងអនុវត្តនយោបាយប្រល័យពូជសាសន៍យ៉ាងពេញទំហឹង ។ ពិភពលោកត្រូវរង់ចាំរហូតដល់ខែ មករា ១៩៧៩ ទើបឃើញ សម្តេច សីហនុ លេចចេញផ្លោឡើងវិញ ដើរតួនាទីដ៏សំខាន់នៅក្នុងឆាកនយោបាយខ្មែរជាថ្មីម្តងទៀត ។

## សកម្មភាពរបស់សមាគម អា ហ្សេ កា អឺ

សកម្មភាពរបស់សមាគម អា ហ្សេ កា អឺ មានតាំងពីផ្នែកសង្គមកិច្ចសាសនា វប្បធម៌ រហូតដល់សកម្មភាពនយោបាយ ។ ក្នុងចំណោមការផ្តួចផ្តើមគំនិតទីមួយរបស់សមាគម មានការធ្វើក្នុងទំនាក់ទំនងអន្តរជាតិ ដូចជាបានធ្វើពាក្យបណ្តឹងចុះថ្ងៃទី ២៧ កញ្ញា ១៩៧៦ ផ្ញើជូនលោកអគ្គលេខាធិការអង្គការសហប្រជា

[55] A Correspondent, Waging War on the Land, Far Eastern Economic Review, March 26, 1976, pp. 24-25.

ជាតិដើម្បីសុំមានឲ្យការស៊ើបអង្កេតពីករណីរំលោភសិទ្ធិមនុស្សនៅកម្ពុជា ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ មិនបានឆ្លើយតបជាវិជ្ជមានទេ ដោយលោកសំអាងថាអង្គការសហប្រជាជាតិមិនអាចធ្វើអ្វីបានឡើយ ប្រសិនបើគ្មានការយល់ព្រម និង សហប្រតិបត្តិការពីរដ្ឋាភិបាលខ្មែរក្រហម ។ សមាគម អា ហ្សេ កា អឺ ក៏បានលើកបញ្ហារំលោភសិទ្ធិមនុស្សនេះ ទៅសុំអន្តរាគមន៍ពីអង្គការនិរទោសអន្តរជាតិ (Amnesty International) ដោយជឿជាក់ថាយ៉ាងហោចណាស់ ក៏សម្លេងនៃប្រជាពលរដ្ឋខ្មែរដ៏ស្លូតត្រង់អាចត្រូវបានគេដឹងឮដែរ ។ សកម្មភាពដទៃទៀតរបស់សមាគម រួមមានការបង្កើតឡើងវិញនូវរបាំព្រះរាជទ្រព្យដែលមានព្រះអង្គម្ចាស់ក្សត្រី នរោត្តម វឌ្ឍរ៉ា ជាតារាឯក ។ សកម្មភាពមួយទៀត មានការកសាងវត្តអារាមសំរាប់ព្រះសង្ឃខ្មែរគង់នៅទីក្រុងប៉ារីស ។ បន្តបន្ទាប់មក ការសំដែងរបាំព្រះរាជទ្រព្យ មិនគ្រាន់តែបង្ហាញនូវការខំប្រឹងប្រែងរបស់សមាគម អា ហ្សេ កា អឺ ក្នុងការការពារវប្បធម៌ ប្រពៃណីខ្មែរប៉ុណ្ណោះទេ ថែមទាំងបានក្លាយជាមធ្យោបាយសំរាប់ឲ្យសមាគមរៃអង្គាសប្រាក់កាស ដើម្បីនាំទៅជួយគាំទ្រសកម្មភាពយោធារបស់យុទ្ធជនមួយក្រុម ដែលមានឈ្មោះថា ខ្មែរសេរីកា នៅតាមព្រំដែនខ្មែរ-ថៃផង ។

យឹម ខាន់កែវ និង តឹកលីន បានចូលរួមក្នុងសមាគមនេះ តាំងពីដើមដំបូងមកម្ល៉េះ ។ អ្នកទាំងពីរចូលរួមយ៉ាងទៀងទាត់ នៅក្នុងអង្គប្រជុំប្រចាំសប្តាហ៍របស់សមាគម ហើយនៅពេលខ្លះទៀត ពួកគេចំណាយពេលវេលាទៅជួយធ្វើការសមាគមនៅក្នុងការិយាល័យ ។ យឹម ខាន់កែវ ដែលជាមនុស្សពូកែប្រាជ្ញព្រោក ចេះរកវិធីបានចូលទៅជិតលោកតា សឺន សាន ។ យឹម ខាន់កែវ និយាយបញ្ចុះបញ្ចូលលោក សឺន សាន ឲ្យដឹងពីសកម្មភាពការងាររបស់ខ្ញុំ ដោយបានលើកសរសើរអំពីចំណោះដឹង គុណសម្បត្តិ និង សីលធម៌ខ្ពស់របស់ខ្ញុំ ដែលធ្វើឲ្យលោកតា សឺន សាន ចង់បានខ្ញុំឲ្យទៅធ្វើការជាមួយគាត់ដើម្បីជាផលប្រយោជន៍ជាតិ ។ ដូច្នេះ យឹម

ខាន់កែវ ក៏បានដើរតួជាអ្នកនាំពាក្យពីខ្ញុំទៅលោកតា សឺន សាន ពីលោកតា សឺន សាន មកខ្ញុំ ។ គេនិយាយប្រាប់ខ្ញុំថា គេគោរព និង ស្រឡាញ់លោកតា ដោយសារគាត់មានសេចក្តីក្លាហាន ជាមនុស្សស្អាតស្អំ និង ជាអ្នកជាតិនិយម ។ គេនិយាយប្រាប់លោកតាថា គេគោរពស្រឡាញ់ខ្ញុំ ព្រោះខ្ញុំបានទទួលជោគជ័យផ្នែកវិជ្ជាជីវៈ និង មានសេចក្តីស្នេហាជាតិខ្ពស់ ។ គឺជាការច្បាស់ណាស់ដែល ខាន់កែវ បង្កលក្ខណៈឲ្យលោកតា សឺន សាន ចង់ជួបខ្ញុំ និង ឲ្យខ្ញុំចង់ជួបលោកតា សឺន សាន ។ នៅទីបំផុត លោកតាបានស្នើឲ្យ ខាន់កែវ បញ្ចុះបញ្ចូលខ្ញុំ ឲ្យចូលទៅក្នុងសមាគម អា ហ្សេ កា អឺ ។ លោកតា សឺន សាន បានត្រៀមខ្លួន ទទួលខ្ញុំគ្រប់ពេលវេលានៅផ្ទះរបស់គាត់ ។ ដូច្នេះ ខាន់កែវ ក៏រៀបចំកម្មវិធីឲ្យខ្ញុំ និង លោកតាបានជួបគ្នា ។

## ជំនួបជាមួយលោកតា សឺន សាន

ខ្ញុំត្រូវទៅជួបលោកតា សឺន សាន នៅគេហដ្ឋានរបស់គាត់នៅផ្លូវ អាកាស្យា (Accacias) នៅល្ងាចថ្ងៃអាទិត្យមួយ នាខែ កញ្ញា ១៩៧៦ ។ តាមធម្មតា នៅពេលឈប់សំរាក ខ្ញុំមិនស្លៀកពាក់អាវធំចងក្រវ៉ាត់ ដែលខ្ញុំតែងតែស្លៀកពាក់នៅរាល់ថ្ងៃធ្វើការទេ ។ ដូច្នេះ ខ្ញុំទៅជួបលោក សឺន សាន អតីតរដ្ឋមន្ត្រីទីមួយនៃប្រទេសខ្មែរគឺ មន្ត្រីធំម្នាក់ធ្លាប់កាន់តំណែងជារដ្ឋមន្ត្រីក្រសួងការបរទេសនៅថ្ងៃដែលខ្ញុំកើត ក្នុងសំលៀកបំពាក់មិនសូវសមរម្យទេគឺ អាវយឺត (T-shirt) និង ខោជីន (Jean) ។ តាមពិតទៅ ខ្ញុំមិនសូវបានយកចិត្តទុកដាក់ និង យល់ដឹងច្បាស់លាស់អំពីរបៀបរបបពិធីការប៉ុន្មានឡើយ ។ ក៏ប៉ុន្តែ ខ្ញុំទៅដល់ទាន់ពេលវេលាល្អណាស់ ។ ខ្ញុំចុចកណ្តឹងផ្ទះដែលជាផ្ទះល្វែង ប្រកបដោយការតុបតែងដ៏ប្រណិតតាមរបៀបអភិជន ។ នៅពេលដែលទ្វារបើកហើយ ខ្ញុំក៏ត្រូវនាំទៅបន្ទប់ទទួលភ្ញៀវដែល នៅ

ក្នុងនោះ លោកតា សឺន សាន ក្នុងសំលៀកបំពាក់អាវធំបីជាន់ចងក្រវ៉ាត់ ឈរចាំទទួលខ្ញុំជាស្រេច ។ នៅអមជាមួយគាត់ មាននារីអាយុសាមសិបប្លាយឆ្នាំម្នាក់ពាក់វ៉ែនតាមីញ៉ូបឈ្មោះអ្នកស្រី សួន កាសេត ជាអ្នកចាំកត់ត្រា និង ដោយមានកូនប្រុសរបស់លោកតាម្នាក់ឈ្មោះ មុនា ដែលជាស្ថាបត្យករជាអ្នកបំរើគ្រឿងភេសជ្ជៈ ។

ឆ្លើយតបនឹងគារវកិច្ចដោយលើកដៃសំពះបែបប្រពៃណីរបស់ខ្ញុំ លោកតាលូកចាប់ដៃខ្ញុំរលាក់យ៉ាងកក់ក្តៅ ។ ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះបុគ្គលិកលក្ខណៈរបស់លោកតា ដែលខ្ញុំមិនដែលបានជួបនិយាយជាមួយដោយផ្ទាល់ឡើយ ។ ខ្ញុំឃើញលោកតាហាក់ដូចជានៅក្មេងជាងអាយុ ។ នៅពេលនោះ ខ្ញុំទើបមានអាយុ ២៦ ឆ្នាំ ឯលោកតា មានអាយុ ៦៥ ឆ្នាំ ។ គាត់មានរាងខ្ពស់ ចំណែកឯត្រចៀកទាំងសងខាងរបស់គាត់មានសណ្ឋានវែង ដែលតាមជំនឿរបស់ខ្មែរយើងថាជាមនុស្សអាយុវែង ។ យ៉ាងណាក៏ដោយ នៅពេលជួបគ្នាគ្រាដំបូងនោះ លោកតាមហាក់ដូចជាមនុស្សមានកម្លាំងខ្សោយ ក៏ប៉ុន្តែនៅពេលក្រោយៗមកអស់រយៈច្រើនឆ្នាំ ដែលបានធ្វើការជាមួយគ្នា ខ្ញុំសង្កេតឃើញថាលោកតាមានអំណត់អត់ធ្មត់ក្នុងការងារ ។ តាមពិត ខ្ញុំមិននឹកស្មានថាខ្ញុំត្រូវបានទទួលកិត្តិយស ដោយបានទទួលការស្វាគមន៍រាក់ទាក់យ៉ាងកក់ក្តៅពីលោកតាយ៉ាងនេះឡើយ ។

លោកតា សឺន សាន បានធ្វើការរៀបរាប់យ៉ាងវែងអំពីស្ថានភាពនយោបាយនៅកម្ពុជានៅក្នុងរបបគ្រប់គ្រងនីមួយៗកន្លងមក ។ លោកតាគូសបញ្ជាក់ថា រាល់ដងដែលខ្មែរបែកបាក់ ប្រទេសជាតិតែងទន់ខ្សោយ ហើយអាចទទួលរងគ្រោះរលាយបាត់ពីផែនដីផង ។ យ៉ាងនេះហើយ ទើបកាលពីប៉ុន្មានឆ្នាំមុនគឺ មុនពេលដែលរបបសាធារណរដ្ឋដួលរលំ លោកតាបានព្យាយាមដោយមិនខ្លាចនឿយហត់ដើម្បីបញ្ចុះបញ្ចូលសម្តេច សីហនុ លោក លន់ នល់ និង អ្នកគាំទ្រទាំងសងខាងដូចជា សហរដ្ឋអាមេរិក និង ប្រទេសចិនជាដើម ឲ្យចូលមកចរចាគ្នាតាមសន្តិវិធី

វិញ ។ ក៏ប៉ុន្តែលោកតាមិនបានទទួលជោគជ័យ ដោយសារពុំមានការគាំទ្រខ្លាំងក្លានៅពីខាងក្រោយ ដូច្នេះក៏គ្មាននរណាស្តាប់ និង ធ្វើតាម ។ នៅទីបញ្ចប់ ខ្មែរក្រហមក៏ឡើងកាន់អំណាច ដោយបង្កើតរដ្ឋអំណាចដ៏ឃោរឃៅមួយ ដែលកាប់សម្លាប់ និង រំលោភសិទ្ធិមនុស្សលើប្រជាពលរដ្ឋឯង ។ ក្នុងជំនួបលើកដំបូងនោះ មែនទែនទៅ យើងនិយាយគ្នាច្រើនអំពីបញ្ហានយោបាយ ជាងបញ្ហាសង្គមកិច្ច និង វប្បធម៌ ។

ចំពោះខ្ញុំវិញ ខ្ញុំគ្រាន់តែបានរៀបរាប់យ៉ាងខ្លីៗអំពីបទពិសោធន៍របស់ខ្ញុំខាងផ្នែកនយោបាយនៅក្នុងជួរគណបក្សប្រជាធិបតេយ្យ ជាពិសេសទំនាក់ទំនងផ្ទាល់របស់ខ្ញុំជាមួយលោក ថៅ សៅ ។ លោកតា សឺន សាន ចាប់អារម្មណ៍ជាពិសេសចំពោះចំណុចនេះ ព្រោះគាត់ធ្លាប់ស្គាល់លោក ថៅ សៅ ច្បាស់លាស់ណាស់ ដោយហេតុថា លោក ថៅ សៅ ធ្លាប់ធ្វើការនៅក្រោមបង្គាប់របស់លោកតា ដែលមានជំនឿទុកចិត្ត និង ទទួលស្គាល់ថាលោក ថៅ សៅ ជាសហការីដែលមានសមត្ថភាពខ្ពស់ ។ ខ្ញុំបានជំរាបលោកតា សឺន សាន ថាខ្ញុំមិនមែនជាអ្នកប្រឆាំងនឹងរបបរាជានិយមទេ ដែលនេះជាចំណុចខុសគ្នារវាងខ្ញុំ និង លោក ថៅ សៅ ។ នៅទីបញ្ចប់នៃជំនួបគ្នានោះ ខ្ញុំបានប្តេជ្ញាផ្តល់ការគាំទ្រចំពោះលោកតា សឺន សាន ហើយនឹងចូលរួមក្នុងសមាគម អា ហ្សេ កា អឺ ។ នៅពេលនោះ លោកតា សឺន សាន បានប្រាប់ទៅលោកស្រី សួន កាសេត ឲ្យជួយសំរួលការងារ ដើម្បីឲ្យខ្ញុំចូលរួមក្នុងការបោះពុម្ពផ្សាយនូវព្រឹត្តិប័ត្រប្រចាំខែរបស់សមាគម អា ហ្សេ កា អឺ ដែលមានឈ្មោះថា លិខិតជូនដំណឹង ។ លិខិតជូនដំណឹងនេះ ត្រូវបានផ្សព្វផ្សាយជូនដល់សហគមន៍ខ្មែរទាំងអស់ និង ជូនដល់បណ្តាញសារព័ត៌មាននៅក្នុងប្រទេសបារាំងផង ។

# ខ្ញុំធ្វើការដើម្បីសហគមន៍ខ្មែរ

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំខឹតខំធ្វើការនៅក្នុងសមាគម អា ហ្សេ កា អឺ ដោយយកចិត្តទុកដាក់ជាទីបំផុត ។ ខ្ញុំចំណាយពេលវេលាក្រៅម៉ោងធ្វើការជាច្រើនម៉ោងក្នុងមួយថ្ងៃៗដើម្បីបំរើសមាគមនេះ ។ សមាគម អា ហ្សេ កា អឺ ក៏ដូចជាសមាគមខ្មែរឯទៀតដែរ មានសមាជិក និង អ្នកគាំទ្រច្រើន ក៏ប៉ុន្តែ សមាជិកដែលសកម្មការងារ និង អ្នកស្ម័គ្រចិត្តមកជួយធ្វើការងារមានចំនួនតិចតួចប៉ុណ្ណោះ ព្រោះម្នាក់ៗសុទ្ធតែជាប់រវល់ក្នុងការងារចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគេ ។

នៅគ្រាដំបូង ខ្ញុំទទួលភារកិច្ចក្នុងការបោះពុម្ពផ្សាយព្រឹត្តិប័ត្រតែម្នាក់ឯង ។ ក្នុងឋានៈជាអ្នកទទួលខុសត្រូវផ្នែកផ្សព្វផ្សាយនោះ ខ្ញុំពុំមានដៃគូ ឬ អ្នកជំនួយការច្រើនទេគឺ ខ្ញុំត្រូវប្រមែប្រមូលព័ត៌មានដោយខ្លួនឯង និង សរសេរអត្ថបទភាគច្រើនដោយឯងខ្លួន មិនតែប៉ុណ្ណោះ ខ្ញុំត្រូវវាយអក្សរ កែសំរួលអត្ថបទ ធ្វើការបោះពុម្ព និង ផ្ញើនូវលិខិតជូនដំណឹងទាំងនោះតាមប្រៃសណីយ៍ទៅសមាជិកគ្រប់ៗរូប ដោយខ្លួនឯងផង ។ ជួនកាលខ្ញុំក៏បានទទួលជំនួយពីមិត្តភក្តិដែលមកពីផ្នែកដទៃ ដែលជាទូទៅគឺជាមនុស្សដដែលៗគឺ ពីពួកកូនចៅលោកតា សឺន សាន ផ្ទាល់ ព្រោះសមាគមបានយកផ្ទះលោកតាជាទីស្នាក់ការកណ្តាល ។ នៅចុងសប្តាហ៍សមាជិកជាច្រើន បានមករួមប្រជុំដើម្បីស្តាប់របាយការណ៍អំពីសកម្មភាពរបស់សមាគម ឬ អំពីការវិវត្តផ្នែកនយោបាយនៅប្រទេសកម្ពុជា ដែលធ្វើឡើងដោយលោកតា សឺន សាន ។ បន្ទាប់ពីការប្រជុំម្តងៗ ខ្ញុំមិនត្រឡប់ទៅផ្ទះវិញទេគឺ នៅបន្តការងារនៅក្នុងការិយាល័យរបស់សមាគមតទៅទៀត ។ ទោះជាខ្ញុំមានភារកិច្ចទទួលខុសត្រូវផ្នែកលិខិតជូនដំណឹងយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅមានការងារឯទៀតនៅក្នុងសមាគមនេះ

ដែរ ។ ក្រៅពីការបង់ប្រាក់វិភាគទានខ្ញុំក៏បានស្ម័គ្រចិត្តធ្វើសកម្មភាពផ្សេងៗជាច្រើននៅក្នុងសមាគមដូចជាការវាយកុំព្យូទ័រកំប៉ុកនៅក្នុងការិយាល័យ និង ជួយដឹកជញ្ជូនសមាជិកឯទៀតដែលគ្មានយានជំនិះដិះត្រឡប់ទៅផ្ទះដោយខ្លួនឯង ឬ ទៅសួរសុខទុក្ខជនភៀសខ្លួន ដែលកាន់តែមានចំនួនច្រើនឡើងនៅប្រទេសបារាំង ឬ ក៏ធ្វើដំណើរទៅតាមខេត្ត ដើម្បីបង្កើតសាខារបស់សមាគម ឬ ដើម្បីប្រារព្ធពិធីបុណ្យសាសនា ឬ ក៏រួមដំណើរជាមួយលោកតា សឺន សាន ដែលមានកម្មវិធីជួបជុំជាមួយប្រជាពលរដ្ឋខ្មែរនៅទូទាំងស្រុកបារាំង ។

កាលសម័យនោះ សមាគម អា ហ្សេ កា អឺ ជាសមាគមដ៏សំខាន់មួយមែនពិត ដែលមានអ្នកធំ អ្នកតូចជាច្រើនចូលរួម ក៏ប៉ុន្តែសមាគមនោះ ក៏មានការប្រណាំងប្រជែងពីសមាគមឯទៀតដែរ ដែលចេះតែមានចំនួនកើនឡើងស្មោកស្មុះដូចផ្សិត ។ សមាគមមួយចំនួនតូច បានប្ដេជ្ញាផ្ដល់ការគាំទ្រដល់យុទ្ធជនប្រឆាំងខ្មែរក្រហមនៅទល់ដែនខ្មែរ-ថៃ ។ បើតាមឯកសារប្រវត្តិរបស់ចលនា រ. ជ. រ. ប. ខ. (រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ) បានឲ្យដឹងថា បន្ទាប់ពីរបបសាធារណរដ្ឋដួលរលំនៅថ្ងៃទី ១៧ មេសា ១៩៧៥ មក មានទាហានខ្មែរសាធារណរដ្ឋមួយចំនួនពុំបានទម្លាក់អាវុធឡើយ ហើយបង្កើតជាក្រុមប្រដាប់អាវុធនៅខែ វិច្ឆិកា ១៩៧៥ ។ ក្រុមយុទ្ធជនទាំងនោះមានជាអាទិ៍ៈ ក្រុមលោក កេត រ៉េត (ស័ក្តិ ៥ សាធារណរដ្ឋ) ក្រុមលោក សេក សំអៀត ដែលជាឧត្តមសេនីយម្នាក់នៃរបបសាធារណរដ្ឋ និង លោក ឃួន ថៃ ។ នៅឆ្នាំ ១៩៧៦ មានក្រុមដទៃទៀតដូចជាៈ ក្រុម អៀ ងួន ក្រុមលោក ព្រុំ វិត ក្រុមលោក យក់ ម៉ន លោក កាន់ វណ្ណា លោក លី ធាង ចេក លោក គីរីរម្យ និង កែវ ជួន ជាដើម ។ ក្រុមទាំងនោះច្រើនជាក្រុមស្វយ័តរកស៊ីកាប់ឈើលក់ ឬ រកត្បូង ដើម្បីចិញ្ចឹមចលនា ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមឧត្តមសេនីយថៃ ។

នៅទីក្រុងប៉ារីស មានសមាគមខ្មែរមួយឈ្មោះ មូលខ្មែរ ដែលបង្កើតឡើងដោយអតីតឧត្តមសេនីយសាធារណរដ្ឋពីរនាក់ និង អ្នកជំនាញការហិរញ្ញវត្ថុធនាគារមួយរូប បានធ្វើការទាក់ទងជាមួយក្រុមយុទ្ធជនទាំងនោះ ។ នៅខែ កុម្ភៈ ១៩៧៧ សមាគមមូលខ្មែរ បានធ្វើការសាកល្បងបង្រួបបង្រួមក្រុម កេត រ៉េត និង អៀ ងួន ឲ្យចូលគ្នា ។ ក៏ប៉ុន្តែ នៅខែ ឧសភា ១៩៧៧ ជាដំបូងក្រុម សេក សំអៀត និង ឃួន ថៃ និង បន្ទាប់មកនៅខែ តុលា ១៩៧៧ ក្រុមលោក កេត រ៉េត បានត្រូវរំលាយចោល ។ នៅខែ វិច្ឆិកា ឆ្នាំដដែលក៏មានចលនាបង្រួបបង្រួមរវាងក្រុមលោក អ៊ឹម ឈូដេត ជាមួយក្រុមលោក សេក សំអៀត ដែរ ។

# ចលនាតស៊ូខ្មែរសេរីកា

លោក អ៊ឹម ឈូដេត ជាអតីតវរសេនីយឯកនៃសាធារណរដ្ឋខ្មែរ ។ មុនស្រុកធ្លាក់ គាត់កាន់តំណែងជាអនុព័ន្ធការពារប្រទេស នៅអមស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ។ នៅក្នុងមុខតំណែងនេះ គាត់មានភ័ព្វសំណាងបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងមេបញ្ជាការជាន់ខ្ពស់នៃកងទ័ពថៃ ។ គាត់មានការជិតស្និទ្ធជាមួយលោកឧត្តមសេនីយ គ្រៀងស័ក្តិ ឆោមចំណាន ដែលជាមេបញ្ជាការជាន់ខ្ពស់បំផុតនៃកងទ័ពថៃ ហើយដែលបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីនៃប្រទេសថៃ ក្រោយរដ្ឋប្រហារយោជាមួយក្នុងខែ តុលា ១៩៧៧ ។ លោក អ៊ឹម ឈូដេត ស្គាល់អ្នកដឹកនាំថៃច្បាស់លាស់ជាទីបំផុត ដែលអាចឲ្យគាត់ចេញចូលជួបលោក គ្រៀងស័ក្តិ បានគ្រប់ពេលវេលា ។ លោក អ៊ឹម ឈូដេត និយាយភាសាថៃយ៉ាងស្ទាត់ជំនាញ ព្រោះធ្លាប់បានរៀនរហូតដល់មធ្យមសិក្សានៅក្នុងសាលាថៃ ។ បន្ថែមលើនេះ លោក អ៊ឹម ឈូដេត ត្រូវបានខ្មែរភាគច្រើនស្គាល់ថាជាអ្នកនិពន្ធប្រលោមលោកយ៉ាងល្បីល្បាញ ។

គាត់និពន្ធប្រលោមលោកខ្មែរជាច្រើន ក៏ប៉ុន្តែប្រលោមលោកដែលល្បីជាងគេនោះ មានចំណងជើងថា "ភរិយាពីរ" ។

បន្ទាប់ពីការដួលរលំនៃរបបសាធារណរដ្ឋ លោក អ៊ឹម ឈូដេត មិនបាន ចេញពីប្រទេសថៃទេ ។ គាត់បន្តរៀបចំបណ្ដាញក្រុមយុទ្ធជន ដើម្បីតស៊ូស្វែងរក សេរីភាពជាបន្តទៀត ។ នៅពេលដែលពួកឧត្តមសេនីយថៃបានសំរេចច្បាស់ថាយក នយោបាយគាំទ្រចលនារួបរួមរបស់ក្រុមយុទ្ធជនខ្មែររួចហើយ ពួកឧត្តមសេនីយថៃ ទាំងនោះ ក៏ស្វែងរកអ្នកដឹកនាំនយោបាយខ្មែរម្នាក់ ដើម្បីដឹកនាំចលនាតស៊ូប្រឆាំង ខ្មែរក្រហម ។ នៅពេលនោះ លោក អ៊ឹម ឈូដេត បានផ្ដល់មតិជូនលោក គ្រឿង ស័ក្ដិ ថាគួរអញ្ជើញលោកតា សឺន សាន ឲ្យមកធ្វើការបង្រួបបង្រួមក្រុមយុទ្ធជន ទាំងនោះ ព្រោះបើតាមការយល់ដឹងរបស់គាត់ លោកតា សឺន សាន ជាវរជនខ្មែរ មួយរូបដែលនៅមានភាពគ្រាន់បើ និង ស្អាតស្អំជាងគេ ។ នេះជាការអះអាងរបស់ លោក អ៊ឹម ឈូដេត ប្រាប់រូបខ្ញុំ និង ប្រាប់អ្នកតស៊ូឯទៀតនៅពេលក្រោយជាបន្ត បន្ទាប់ ។ ក៏ប៉ុន្តែ បើតាមលោកតា សឺន សាន មនុស្សដែលមកទាក់ទង ក្នុងឋានៈជា មេអណ្ដើករវាងលោកតា សឺន សាន និង អាជ្ញាធរយោធាថៃនោះ ឈ្មោះ ឡេ កុក ទុយ (Le Quoc Tuy)[56] ដែលជាមេដឹកនាំក្រុមវៀតណាមសេរីប្រឆាំងក្រុង ហាណូយ ។

នៅទីបំផុត ខ្ញុំបានដឹងនៅពេលក្រោយៗមកទៀតថា វរសេនីយឯកថៃម្នាក់ ឈ្មោះ ឆាវលិត យុងឆៃយុទ្ធ បានធ្វើដំណើរមកទីក្រុងប៉ារីស ដើម្បីទាក់ទងផ្ទាល់ជា មួយលោកតា សឺន សាន និង ស្នើលោកតាឲ្យមកបង្កើតចលនាតស៊ូនៅទល់ដែន ខ្មែរ-ថៃ ។ លោកវរសេនីយឯករូបនេះដែលក្រោយៗមកបានក្លាយទៅជានាយករដ្ឋ មន្ត្រីនៃប្រទេសថៃ កាលសម័យនោះ ជាអ្នកជំនាញការក្នុងបញ្ហាខ្មែរ ។ លោក

[56] The Memoirs of Son Sann, Cambodia Daily Press, 2011, p.127.

ឆាវលិត ជានាយទាហានថៃម្នាក់ ដែលមានឥទ្ធិពលយ៉ាងខ្លាំង និង ដែលមានសមត្ថភាពទាញយកផលប្រយោជន៍យ៉ាងសម្បើម សំរាប់ប្រទេសថៃ តាមរយៈការលូកដៃផ្ទាល់ចូលក្នុងជម្លោះនៅកម្ពុជា ។

ជាដំបូង ខ្ញុំមិនបានដឹងថាលោក ឆាវលិត បានមកទាក់ទងសមាគម អាហ្សេ កា អឺ និង មិនបានដឹងថា សមាគមបានផ្តល់ការគាំទ្រហិរញ្ញវត្ថុជាសម្ងាត់ដល់យុទ្ធជននៅតាមជាយដែនទេ ព្រោះនោះជានយោបាយជាន់ខ្ពស់ ដែលមានតែមនុស្សតិចតួច ហើយជិតដិតបំផុតជាមួយលោកតា សឺន សាន ប៉ុណ្ណោះទើបបានដឹង ។ តាមពិតទៅ លោកតា សឺន សាន បានធ្វើសកម្មភាព "នយោបាយជាន់ខ្ពស់" នេះ តែជាមួយមនុស្សមួយក្តាប់តូចដែលគាត់ទុកចិត្ត ដែលសុទ្ធសឹងតែជាសមាជិកសកម្មនៅក្នុងសមាគម និង ជាមួយកូនចៅរបស់លោកតាខ្លះៗប៉ុណ្ណោះ ។ ក្នុងចំណោមអ្នកទាំងនោះ ក្រៅពីអ្នកស្រី សួន កាសេត ខ្ញុំក៏អាចរាប់បន្ថែមនូវកូនប្រសាលោកតា សឺន សាន ម្នាក់គឺ លោកបណ្ឌិតឱសថសាស្ត្រ ឆាយ ហាន់ចេង ដែលធ្លាប់កាន់តំណែងជារដ្ឋលេខាធិការក្រសួងសុខាភិបាល ក្នុងសម័យសង្គមនាទសវត្សរ៍ឆ្នាំ ១៩៦០ ។ លោក ឆាយ ហាន់ចេង បំរើលោកតាផ្ទាល់ ដូចជាអង្គរក្ស ឬ ក៏លេខា ឬ ក៏ប្រធានខុទ្ទកាល័យផ្ទាល់ក៏បាន ។ ឲ្យតែលោកតាប្រើ លោក ឆាយ ហាន់ចេង ធ្វើជូនទាំងអស់ ។ នៅថ្ងៃមួយដែលលោកតា សឺន សាន មានសុខភាពមិនល្អនិយាយឮពុំបាននៅក្នុងអង្គប្រជុំ លោកតានិយាយដាក់ត្រចៀកកូនប្រសា ហើយកូនប្រសានោះ ក៏និយាយបន្តដូចជានិយាយដាក់មេក្រូយ៉ាងដូច្នោះ ។

ក្រោយមក ខ្ញុំក៏ឃើញមនុស្សម្នាក់ទៀត ជាមនុស្សជិតស្និទ្ធនឹងលោកតាដែរ ដែលជាអតីតមន្ត្រីជាន់ខ្ពស់ក្នុងរាជការស៊ីវិលខ្មែរ ឈ្មោះលោក នាង ជិនហាន ។ ជាមួយនោះ ក៏មានឧត្តមសេនីយសម័យសាធារណរដ្ឋម្នាក់ ដែលគេស្គាល់ថាជាអ្នកមានសមត្ថភាពគ្រាន់បើ ក្នុងជួរកងទ័ពរបស់លោក លន់ នល់ ឈ្មោះលោកឧត្តម

សេនីយ ដៀន ដែល ។ បន្ទាប់ពីបានប្រជុំជាមួយគ្នាច្រើនដងមក ខ្ញុំសំគាល់ឃើញលោកឧត្តមសេនីយរូបនេះ មានគោលជំហរនយោបាយល្អ ព្រោះគាត់ប្រកាន់ថាកងទ័ពត្រូវតែបំរើលទ្ធិប្រជាធិបតេយ្យ ។

លោក នាង ជិនហាន ជាមន្ត្រីជាន់ខ្ពស់មួយរូប ដែលបានទទួលសញ្ញាប័ត្រចេញពីសាលាភូមិន្ទរដ្ឋបាល ហើយធ្លាប់បានបំរើការជាប្រធានលេខាធិការដ្ឋានរបស់សម្តេច សីហនុ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ។ នៅប្រទេសបារាំងគាត់ធ្វើការសិក្សាបន្ថែម ផ្នែកវិទ្យាសាស្ត្រនយោបាយ និង ធុរកិច្ច ហើយបានទទួលសញ្ញាប័ត្រទាំងពីរផ្នែកនេះទៀតផង ។ លោក នាង ជិនហាន មានជំនាញខ្ពស់ខាងផ្នែករដ្ឋបាល ហើយគាត់អាចសរសេរសុន្ទរកថានយោបាយជាភាសាបារាំងបានយ៉ាងល្អ ។ លោក នាង ជិនហាន មានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកស្រី សួន កាសេត ។ ចំណែកឯអ្នកស្រី សួន កាសេត ក៏ធ្លាប់ជាមន្ត្រីបំរើការផ្ទាល់នៅក្នុងខុទ្ទកាល័យរបស់សម្តេច សីហនុ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ដែរ ក្នុងឋានៈជាអ្នកទទួលខុសត្រូវផ្នែកការផ្សាយនៃព្រឹត្តិប័ត្រប្រចាំខែឈ្មោះ កាំបូជ្យា (Kambuja) ។ អ្នកស្រី សួន កាសេត បានទទួលការអប់រំរបៀបបារាំង ហើយកើតចេញពីត្រកូលអ្នកធំខ្មែរ ដែលធ្លាប់កាន់តំណែងជារដ្ឋមន្ត្រី និង ឯកអគ្គរាជរដ្ឋទូតជាដើម ។ អ្នកស្រីនិយាយភាសាបារាំងបានយ៉ាងស្ទាត់ជំនាញ និយាយភាសាខ្មែរក៏ល្អដែរ ក៏ប៉ុន្តែគាត់មិនចេះអាន និងសរសេរអក្សរខ្មែរទេ ។ អ្នកស្រី សួន កាសេត រៀបការជាមួយមន្ត្រីជាន់ខ្ពស់ក្រសួងកសិកម្មម្នាក់ ហើយមានកូនបីនាក់ ដែលគាត់នាំយកមករស់នៅជាមួយនៅប្រទេសបារាំង បន្ទាប់ពីពួកខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ ដោយទុកចោលស្វាមីឲ្យនៅទីនោះ ។ តាំងពីពេលខ្មែរក្រហមចូលកាន់កាប់ប្រទេសនោះរហូតមក អ្នកស្រីពុំដែលបានទទួលដំណឹងពីស្វាមីសោះឡើយ ។

ដោយសារសមាគមខ្មែរនានានៅប្រទេសបារាំង កើតមានឡើងច្រើនដូចផ្សិត អ្នកខ្លះផ្តួចផ្តើមគំនិតឲ្យមានការសំរបសំរួលសកម្មភាពរបស់សមាគមទាំងនោះដូចជាការបង្កើតគណៈកម្មាធិការទំនាក់ទំនងមួយឈ្មោះ សេ ដេ អិល (CDL: Comité de Liaison) ឬ គណៈកម្មការដើម្បីឯករាជ្យអព្យាក្រឹតជាដើម ។ ទោះជាយ៉ាងនោះក្តី ក៏មកដល់ឆ្នាំ ១៩៧៩ គេអាចរាប់ឃើញថាមានសមាគមខ្មែរប្រហែលជា ១៥០ បានត្រូវបង្កើតនៅក្នុងប្រទេសបារាំង ដែលនៅក្នុងនោះចំនួនពាក់កណ្តាលមាននៅក្នុងទីក្រុងប៉ារីស និង ជាយក្រុងនេះ ។ ពួកខ្មែរៗដែលបង្កើតសមាគមទាំងនេះ ប្រហែលនឹកគិតថាសកម្មភាពនយោបាយរបស់ខ្លួនអាចនឹងធ្វើឲ្យមានឧបសគ្គ ឬ ផលប៉ះពាល់ដល់ទង្វើរបស់ពួកខ្មែរក្រហមនៅក្នុងប្រទេសបានដោយគ្រាន់តែធ្វើការជជែកគ្នា បោះពុម្ពផ្សាយ ឬ ចេញផ្សាយនូវសេចក្តីថ្លែងការណ៍ព្រឹត្តិប័ត្រព័ត៌មាន ឬ ធ្វើសន្និសីទព័ត៌មានជាដើម ។ ចំពោះខ្ញុំៗមានភាពច្បាស់លាស់ក្នុងចិត្តរបស់ខ្ញុំជាស្រេចថា ដើម្បីរំដោះទឹកដីខ្មែរចេញពីពួកខ្មែរក្រហមមានតែសកម្មភាពជាក់ស្តែង នៅលើសមរភូមិតែប៉ុណ្ណោះគឺ នៅលើទឹកដីខ្មែរផ្ទាល់ មិនមែនធ្វើសកម្មភាពពីចម្ងាយ រាប់ពាន់គីឡូម៉ែត្រពីប្រទេសខ្មែរនោះឡើយ ។ ដោយសារមានការប្តេជ្ញាចិត្តច្បាស់លាស់យ៉ាងនេះ ទើបខ្ញុំសំរេចចិត្តថា ត្រូវត្រៀមខ្លួនដើម្បីធ្វើអ្វីមួយឲ្យបានខិតទៅជិតប្រទេសខ្មែរ ឬ យ៉ាងហោចណាស់ ទៅធ្វើការផ្ទាល់ជាមួយយុទ្ធជនដែលស្នេហាសេរីភាព នៅលើសមរភូមិដោយផ្ទាល់តែម្តង ។ សេចក្តីសំរេចទីមួយរបស់ខ្ញុំគឺសុំលាឈប់ពីការងារនៅក្នុងក្រុមហ៊ុន ម៉ុត្តុង ទាំងពីរ ។

## ឃ្លាតកាយ ណាយចិត្ត

ថ្ងៃនោះជាថ្ងៃដែលពោរពេញទៅដោយក្តីសោកសៅ និង ភាពតានតឹងក្នុងចិត្តចំពោះក្រុមគ្រួសារថៅកែខ្ញុំ ។ នៅពេលដែលខ្ញុំប្រគល់លិខិតលាលែងរបស់ខ្ញុំ

ក្នុងខែ តុលា ១៩៧៨ នោះ អ្នកស្រី ម៉ុត្តុង បង្ហូរទឹកភ្នែកដោយក្តីក្តុកក្តួល ។ ខ្ញុំនិយាយប្រាប់ពួកគេថា អនាគតរបស់ខ្ញុំនៅឯស្រុកខ្មែរ មិនមែននៅស្រុកបារាំងនេះទេ ។ ខ្ញុំមិនអាចរស់នៅយកសុខតែម្នាក់ឯង នៅពេលដែលខ្ញុំដឹងថាប្រជារាស្ត្រខ្ញុំ និង ប្រទេសជាតិខ្ញុំកំពុងជួបប្រទះនូវសោកនាដកម្មដែលមិនធ្លាប់មានសោះនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ ។ តាមពិត នៅពេលនោះ ខ្ញុំនៅមិនទាន់មានគំនិតអ្វីច្បាស់លាស់ថា តើពេលណា និង ធ្វើយ៉ាងដូចម្តេច ដើម្បីវិលត្រឡប់មកប្រទេសកម្ពុជា និង តំបន់ទល់ដែនវិញនោះនៅឡើយទេ ។ បន្ទាប់ពីលាចេញពីក្រុមហ៊ុន ម៉ុត្តុង នោះមក ខ្ញុំក៏បានទៅធ្វើការនៅក្រុមហ៊ុនពីរទៀត ទី១ ឈ្មោះ ឡា ទ្រីពីរី ដឺ ឡា វីឡែត (La Triperie de la Villette) និង មួយទៀត ឈ្មោះ អាឡេន ប្រាឡេ (Allen-Bradley) ដែលជាក្រុមហ៊ុនអាមេរិកាំង មុននឹងចេញដំណើរជាស្ថាពរពីប្រទេសបារាំង ។ ក៏ប៉ុន្តែសេចក្តីសំរេចលាលែងរបស់ខ្ញុំចេញពីក្រុមហ៊ុន ម៉ុត្តុង នេះ គឺខ្ញុំធ្វើឡើងដោយបង្ខំចិត្ត ដើម្បីកាត់ចំណងមនោសញ្ចេតនារវាងខ្ញុំ និង គ្រួសារនេះ ព្រោះបើពុំនោះទេ ខ្ញុំប្រហែលជានៅជាប់ជំពាក់នឹងបញ្ហាផ្ទាល់ខ្លួន ហើយមិនអាចផ្ទង់ស្មារតី ឬ សតិអារម្មណ៍របស់ខ្ញុំ ឆ្ពោះទៅធ្វើអ្វីមួយ ដែលខ្ញុំយល់ថាត្រូវតែធ្វើនៅពេលអនាគតនោះឡើយ ។ ចំពោះខ្ញុំនាពេលនោះ អ្វីៗក៏ដោយក៏ត្រូវចាប់ផ្តើមពីពាក្យមួយឃ្លាថា "ឃ្លាតកាយណាយចិត្ត" ។

## ខ្មែរក្រហមមានជម្លោះជាមួយប្រទេសជិតខាង

ចំណែកឯនៅប្រទេសកម្ពុជាវិញ របបខ្មែរក្រហមដ៏កាចឃោរឃៅនោះ ចាប់ផ្តើមធ្វើឲ្យលេចឃើញនូវវិនាសកម្ម ដែលកាន់តែរីកធំឡើងៗឥតឈប់ឈរ ។ តាម

រយៈសារព័ត៌មានអន្តរជាតិ ខ្ញុំបានទទួលដំណឹងថារហូតដល់ឆ្នាំ ១៩៧៧ ប្រជាពលរដ្ឋខ្មែរប្រមាណ មួយលានពីរសែននាក់ បានត្រូវបាត់បង់ជីវិត ដោយសារការអត់អាហារ ការបង្ខំឲ្យធ្វើការជាទម្ងន់ ឬ ដោយសារការកាប់សម្លាប់ ។ ជនភៀសខ្លួនខ្មែររាប់សិបពាន់នាក់បានរត់មកស្នាក់នៅក្នុងទឹកដីថៃ និង វៀតណាម ។ ជាមួយគ្នានោះ ពួកខ្មែរក្រហមក៏ត្រូវជួបប្រទះនូវការប្រឆាំងផ្នែកអាវុធពីក្នុងស្រុកផង និងប៉ះទង្គិចខាងផ្លូវអាវុធជាមួយប្រទេសជិតខាងផងគឺ ប្រទេសថៃ និង វៀតណាម ។

ជម្លោះជាមួយប្រទេសថៃ អាចនិយាយថាមានឫសគល់ខាងផ្នែកមនោគមវិជ្ជា ព្រោះថាប្រទេសទាំងពីរប្រកាន់មនោគមវិជ្ជាខុសគ្នា បន្ថែមលើជម្លោះដណ្ដើមទឹកដីគ្នាទៀតផង ។ ម្យ៉ាងប្រទេសកម្ពុជា នាពេលនោះ ប្រកាន់យករបបកុម្មុយនីស្តដ៏តឹងតែង រីឯប្រទេសថៃជាប្រទេសសេរី ជាសម្ព័ន្ធមិត្តជិតស្និទ្ធជាមួយសហរដ្ឋអាមេរិក ហើយក៏ធ្លាប់ទៅច្បាំងប្រឆាំងកុម្មុយនីស្តនៅវៀតណាមទៀតផង ។ ម្យ៉ាងទៀតចាប់ពីខែ តុលា ១៩៧៦ ដោយសាររដ្ឋប្រហារ ប្រទេសថៃបានត្រូវដឹកនាំដោយរដ្ឋាភិបាលស្តាំនិយមប្រឆាំងនឹងកុម្មុយនីស្តយ៉ាងដាច់ខាតមួយ ។ ដូច្នេះរដ្ឋាភិបាលថៃថ្មីនេះ មានគោលនយោបាយប្រឆាំងប្រទេសខ្មែរកុម្មុយនីស្ត ឈ្មោះកម្ពុជាប្រជាធិបតេយ្យ ដែលគេយល់ថាអាចផ្ដល់ជម្រកដល់ពួកថៃកុម្មុយនីស្ត ឲ្យវាយប្រហារប្រឆាំងរបបនយោបាយរបស់គេ ។ ម្យ៉ាងទៀត រដ្ឋាភិបាលថៃសម័យនោះ ក៏មានយុទ្ធវិធីផ្ដល់ការគាំទ្រដល់ចលនាខ្មែរទាំងឡាយ ដែលប្រឆាំងខ្មែរក្រហមកុម្មុយនីស្តជាពិសេស ដល់ពួកខ្មែរសេរី និង ខ្មែរសេរីកា ។

កាលពីដំបូង នៅក្នុងជម្លោះរវាងខ្មែរក្រហម និង ថៃ ប្រទេសវៀតណាមដែលធ្លាប់ជាយុទ្ធមិត្តរបស់ខ្មែរក្រហម បានគាំទ្រពួកខ្មែរក្រហមយ៉ាងពេញទំហឹង ។ កាលនោះក្នុងឆ្នាំ ១៩៧៦ នៅពេលដែលខ្មែរក្រហម ប្រកាសថាមានយន្តហោះអាមេរិកទម្លាក់គ្រាប់បែក នៅក្នុងខេត្តសៀមរាប ទាំងទីក្រុងហាណូយ ទាំងទីក្រុង

ប៉េកាំង សុទ្ធតែបានស្រែកបន្ទរតាមការចោទប្រកាន់របស់ខ្មែរក្រហម[57]។ ក៏ប៉ុន្តែទីក្រុងហាណូយ ហាក់ដូចជាបង្ហាញនូវការចាប់អារម្មណ៍លើការទម្លាក់គ្រាប់បែកនោះខ្លាំងជាងទីក្រុងប៉េកាំងទៅទៀត ។ នៅខែ មីនា ១៩៧៦ បណ្តាញព័ត៌មានអន្តរជាតិ បានផ្សព្វផ្សាយថាវៀតណាម បានផ្តន្ទាទោសការទម្លាក់គ្រាប់បែកយ៉ាងធ្ងន់ធ្ងរនេះ នៅក្នុងសេចក្តីថ្លែងការណ៍មួយរបស់ខ្លួន ដែលមានសេចក្តីជាអាទិ៍៖ "សហរដ្ឋអាមេរិកនៅតែបន្តប្រើប្រាស់ទឹកដីថៃ ដើម្បីធ្វើការប្រឆាំងកម្ពុជា លាវ និង វៀតណាម ។ ពួកគេគាំទ្រពួកខ្មែរប្រតិកិរិយា[58] ដែលរស់នៅលើទឹកដីថៃ ហើយលួចបញ្ចូលពួកនេះមកកម្ពុជាវិញ ដើម្បីធ្វើវិទ្ធង្សនា និង សកម្មភាពបំផ្លិចបំផ្លាញបដិវត្តន៍កម្ពុជា" ។

នៅសម័យនោះ ប្រទេសកុម្មុយនីស្តទាំងពីរគឺ វៀតណាម និង កម្ពុជាប្រជាធិបតេយ្យ ឈរកៀកគ្នាទប់ទល់ជាមួយសត្រូវរួម ទោះបីជាប្រទេសកុម្មុយនីស្តទាំងពីរនេះ ចាប់ផ្តើមមានជម្លោះទល់ដែនជាបណ្តើរៗរួចមកហើយក៏ដោយ ចាប់តាំងពីខែ ឧសភា ១៩៧៥ ។ កាលពីខែ សីហា ១៩៧៥ នៅពេលដែលមេដឹកនាំកុម្មុយនីស្តវៀតណាម ឡេ យន់ មកធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញ ភាគីទាំងពីរ វៀតណាម និង ខ្មែរក្រហម បានព្រមព្រៀងថានឹងដោះស្រាយជម្លោះនោះដោយសន្តិវិធី ។ បណ្តាញព័ត៌មានអន្តរជាតិបានផ្សព្វផ្សាយថា ជនភៀសខ្លួនខ្មែររាប់ពាន់នាក់ដែលបានរត់ទៅជ្រកនៅតាមបណ្តាខេត្តជិតខាងនានា ក្នុងប្រទេសវៀតណាមបានត្រូវបញ្ជូនត្រឡប់មកកម្ពុជាប្រជាធិបតេយ្យវិញ ។ មួយចំនួនត្រូវបានចាប់បញ្ជូនមក

---

[57] Nayan Chanda, The Barbarous Raid Mystery, Far Eastern Economic Review, March 12, 1976, p. 14.

[58] តាមពិតទៅ តាំងពីសម័យសង្គមរាស្ត្រនិយមមកម្ល៉េះ ប្រទេសថៃ តែងតែជួយចិញ្ចឹមក្រុមខ្មែរសេរី ឲ្យធ្វើការប្រឆាំងរដ្ឋាភិបាលខ្មែរ ។ នៅសម័យខ្មែរក្រហម ក៏មានក្រុមខ្មែរប្រដាប់អាវុធ ជ្រកកោននៅលើទឹកដីថៃដែរ ។ ចំពោះខ្មែរសេរី ឬ សេរីកា ប្រទេសកុម្មុយនីស្តតែងហៅពួកទាំងនោះថាជាពួកប្រតិកិរិយា ។

ឲ្យខ្មែរក្រហម ។ ក៏ប៉ុន្តែជនភៀសខ្លួនមួយចំនួនដែលចេញផុតពីខេត្តទល់ដែនចូលជ្រៅទៅក្នុងប្រទេសវៀតណាម ក៏បានរស់នៅបន្តទៅទៀត ។

នៅក្រុងហូជីមិញ (អតីតទីក្រុងព្រៃនគរ) មានជនភៀសខ្លួនប្រហែលមួយម៉ឺននាក់ ភាគច្រើនរស់នៅ តាមវត្តអារាម ។ បណ្តាញព័ត៌មានទាំងនោះបញ្ជាក់ថាក្នុងចំណោមនោះ មានជនភៀសខ្លួនប្រមាណតែប៉ុន្មានរយនាក់ប៉ុណ្ណោះ ដែលអាចទទួលការអនុញ្ញាតឲ្យចេញទៅរស់នៅប្រទេសបារាំង មុនពេលវៀតណាមផ្តាច់ចំណងទាក់ទងជាមួយទីក្រុងភ្នំពេញ ។

## យុទ្ធសាស្ត្រចិននាំឲ្យថៃ និង ខ្មែរក្រហមផ្អាកជម្លោះ

នៅខែ សីហា ១៩៧៦ ប្រទេសថៃ និង របបខ្មែរក្រហមបានសាកល្បងកែលំអឡើងវិញនូវទំនាក់ទំនងគ្នា ដោយសុខចិត្តបើកច្រកព្រំដែន ដើម្បីធ្វើពាណិជ្ជកម្ម ទោះបីជាជម្លោះព្រំដែននៅតែបន្តកើតមានយ៉ាងណាក៏ដោយ ។ ក៏ប៉ុន្តែនៅឆ្នាំ ១៩៧៧ ទំនាក់ទំនងថៃ និង ខ្មែរក្រហមបានត្រូវខូចខាតដោយសារមានការប៉ះទង្គិចខាងផ្នែកយោធា ដែលបង្កឲ្យមានការបាញ់កាំភ្លើងធំ និង ការវាយប្រហារផ្លូវអាកាសពីខាងកងទ័ពថៃផង ។ នៅថ្ងៃទី ២៨ មករា ១៩៧៧ អ្នកស្រុកថៃចំនួន ៦០ នាក់ បានត្រូវខ្មែរក្រហមសម្លាប់ ។ ចាប់តាំងពីពេលនោះមក ប្រទេសថៃក៏បិទច្រកព្រំដែនជាមួយកម្ពុជាឡើងវិញ ។ នៅខែ វិច្ឆិកា រដ្ឋាភិបាលថៃបានធ្វើការតវ៉ាតាមផ្លូវការមួយច្បាប់ទៅអាជ្ញាធរខ្មែរក្រហម ។ ខ្មែរក្រហមបានចេញសេចក្តីថ្លែងការណ៍ ៨ ទំព័រ អះអាងថា ប្រទេសថៃជាអ្នកទទួលខុសត្រូវក្នុងការកាប់សម្លាប់នេះ និង ថាព្រឹត្តិការណ៍ទាំងនោះ បានកើតឡើងលើទឹកដីខ្មែរ ។ ចាប់តាំងពីពេលនោះមក ខ្មែរក្រហមក៏សម្ងំស្ងៀម ។ មន្ត្រីថៃជាដំបូងអះអាងថា មានទាហានខ្មែរក្រហមបានឆ្លងកាត់ទល់ដែន ចូលទៅកាប់សម្លាប់ និង បំផ្លិចបំផ្លាញទ្រព្យសម្បត្តិប្រជា

ពលរដ្ឋថៃ ។ ក្រោយមក អ្នកវិភាគស្ថានការណ៍យោធានៅទីក្រុងបាងកក បានបកស្រាយថា តំបន់អារញ្ញប្រថេតជាទីដែលមានការកាប់សម្លាប់នោះគឺ ជាសំបុកខ្មែរប្រឆាំងកុម្មុយនីស្ត ដែលគេហៅថាខ្មែរសេរី[59] ហើយដែលកំពុងតែធ្វើការតស៊ូ ដើម្បីរំដោះប្រទេសកម្ពុជាពីក្រុមខ្មែរក្រហម ។ គេចង់បកស្រាយថា ប្រសិនបើមានការប៉ះទង្គិចគ្នាមែន ការប៉ះទង្គិចគ្នានោះកើតឡើងដោយសារក្រុមខ្មែរសេរីដែលប្រឆាំងនឹងក្រុមខ្មែរក្រហម មិនមែនដោយសារកងកម្លាំងរបស់រដ្ឋាភិបាលថៃឡើយ ។

គេប៉ាន់ស្មានថា ក្រុមខ្មែរសេរីមានចំនួនប្រមាណ ២០០០ នាក់ នៅតាមតំបន់ព្រំដែន បានធ្វើការទាក់ទងជាមួយនាយទាហានថៃ និង អ្នកជំនួញខ្មែរ-ថៃមួយចំនួន ។ ជាការពិតណាស់ ដែលមានយុទ្ធជនខ្មែរសេរី កំពុងប្រតិបត្តិការនៅក្នុងតំបន់អារញ្ញប្រថេត ។ ពួកនេះ បានយកទឹកដីថៃ ដើម្បីធ្វើសង្គ្រាមទ័ពព្រៃវាយប្រហារលើពួកខ្មែរក្រហម ក្នុងបំណងធ្វើសកម្មភាពទាក់ទាញរកជំនួយបន្ថែម និង ឆាឆៅទាហានខ្មែរក្រហមនេះផង ។ ការវាយឆ្មក់តាមរបៀបទ័ពព្រៃរបស់ក្រុមខ្មែរសេរីទាំងនេះ បានធ្វើឲ្យខ្មែរក្រហមមានប្រតិកម្មខឹង និង វាយតបចូលទឹកដីថៃវិញ ។ ចាប់តាំងពីខែ មីនា ដល់ខែ តុលា ១៩៧៧ ការប៉ះទង្គិចខាងផ្លូវអាវុធកាន់តែកើនឡើង និង ខ្លាំងក្លាឡើង ហើយរាលដាលចូលដល់ខេត្តត្រាតនៃប្រទេសថៃ ។

ដើម្បីឆ្លើយតបចំពោះការវាយប្រហាររបស់ពួកខ្មែរក្រហម ថៃបានបញ្ជូនកាណូតប្រដាប់អាវុធ និង កប៉ាល់ហោះចម្បាំងទៅកាន់តំបន់នោះ ។ មេបញ្ជាការកំពូលនៃកងទ័ពថៃ ឧត្តមសេនីយ គ្រៀងស័ក្តិ ប្រកាសថាកងទ័ពប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវនយោបាយវាយតបតទៅវិញ ចំពោះអំពើឈ្លានពានទាំងឡាយណា មកលើទឹកដីថៃដើម្បីការពារអធិបតេយ្យ និង សិទ្ធិអំណាចរបស់ប្រជាពលរដ្ឋថៃ ។

---

[59] Norman Peagam, Political Stability at Stake, Questions after the Massacre, Far Eastern Economic Review, February 11, 1977, p. 9-10.

ការវាយប្រហារកើតឡើងចំពេលដែល ប៉ុល ពត កំពុងបញ្ចប់ទស្សនកិច្ចជាបងប្អូន ក្នុងរយៈពេល ៥ ថ្ងៃនៅប្រទេសកូរ៉េខាងជើង និង ចាប់ផ្តើមទស្សនកិច្ចជាផ្លូវការនៅប្រទេសចិន ចាប់ពីថ្ងៃ ២៨ កញ្ញា ១៩៧៧ ។ គាប់ជួនពេលជាមួយនោះដែរ អតីតនាយករដ្ឋមន្ត្រីថៃ គុគ្រឹត ប្រាមោជ ក៏បានទៅធ្វើទស្សនកិច្ចជាផ្លូវឯកជននៅទីក្រុងប៉េកាំង និង បានជួបពិភាក្សាយ៉ាងស្និទ្ធស្នាលជាមួយប្រធាន ហួ គួហ្វេង ។ ប្រហែលជានៅពេលនោះ ចិនចាប់ផ្តើមធ្វើអន្តរាគមន៍ ដើម្បីបញ្ឈប់នូវជម្លោះរវាងប្រទេសថៃ និង ខ្មែរក្រហម ក្នុងន័យបង្កើតឲ្យបាននូវសម្ព័ន្ធភាពថ្មីមួយប្រឆាំងសូវៀត និង វៀតណាម ។ នៅថ្ងៃទី ២០ តុលា ១៩៧៧ ក្រុមយោធាថៃដែលបានទម្លាក់រដ្ឋាភិបាលរបស់លោក សេនី ប្រាមោជ កាលពីថ្ងៃទី ៦ តុលា ១៩៧៦ បានឡើងកាន់អំណាចឡើងវិញ ដោយទម្លាក់រដ្ឋាភិបាលស្តាំនិយមប្រឆាំងកុម្មុយនីស្តនិយមរបស់លោក តានីន ក្រៃវិឈៀន និង លើកលោកឧត្តមសេនីយ គ្រៀងស័ក្តិ ឲ្យកាន់តំណែងជានាយករដ្ឋមន្ត្រី ។ លោកឧត្តមសេនីយ គ្រៀងស័ក្តិ ធ្លាប់ថ្លែងជាញឹកញាប់ជាសាធារណៈថា គាត់មានទស្សនៈកែលំអទំនាក់ទំនងជាមួយប្រទេសឥណ្ឌូចិនកុម្មុយនីស្ត ។ ទំនាក់ទំនងល្អជាភារកិច្ចដ៏សំខាន់របស់លោកនាយករដ្ឋមន្ត្រីថ្មីរូបនេះ ។

នៅខែ វិច្ឆិកា ១៩៧៧ មួយថ្ងៃមុនឧត្តមសេនីយ គ្រៀងស័ក្តិ ឡើងកាន់តំណែងជាផ្លូវការ វិទ្យុខ្មែរក្រហមបានផ្សាយនូវសេចក្តីថ្លែងការណ៍មួយអំពាវនាវឲ្យថៃចូលមកចរចា ដើម្បីកែលំអទំនាក់ទំនងរវាងប្រទេសទាំងពីរ ។ សេចក្តីថ្លែងការណ៍នោះ បានទទូចឲ្យប្រទេសថៃជួបជាមួយមន្ត្រីខ្មែរក្រហមនៅទីក្រុងវៀងច័ន្ទ ។ ខ្មែរក្រហមនិយាយថា ពួកគេបានធ្វើសេចក្តីអញ្ជើញនេះជាលើកដំបូងនៅពេលដែលលោក អៀង សារី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសខ្មែរក្រហម បានជួបជាមួយនឹងលោក ឧបឌិត បាចរិយាគុណ រដ្ឋមន្ត្រីក្រសួងការបរទេសថៃ នៅអង្គការ

សហប្រជាជាតិ កាលពីថ្ងៃទី ១២ តុលា ១៩៧៧ ។ ពួកថៃបានស្វាគមន៍សេចក្តីអំពាវនាវនេះ ។ អ្នកវិភាគនយោបាយជាច្រើនយល់ថា ការផ្លាស់ប្តូរជាបន្ទាន់នៃយុទ្ធសាស្ត្ររបស់ខ្មែរក្រហមនោះ ប្រាកដជាលទ្ធផលនៃនយោបាយចិនដែលចាប់តាំងពីឆ្នាំ ១៩៧៥ មកខឹតខំជួយជំរុញឲ្យមានទំនាក់ទំនងល្អរវាងថៃ និង ខ្មែរក្រហម ។

នៅចុងខែ មករា ១៩៧៨ រដ្ឋាភិបាលដែលមានការគាំទ្រពីក្រុមយោធាបានចាត់បញ្ជូនគណៈប្រតិភូការទូតជាន់ខ្ពស់របស់ប្រទេសថៃ ដែលដឹកនាំដោយលោករដ្ឋមន្ត្រីការបរទេស ឧបឱត បាចរិយាគុណ មកទីក្រុងភ្នំពេញដើម្បីកែសម្រួលឡើងវិញនូវទំនាក់ទំនងខ្មែរក្រហម-ថៃ និង ដោះស្រាយដោយសន្តិវិធីនូវជម្លោះទល់ដែន ។ នៅក្នុងសុន្ទរកថា ដែលថ្លែងក្នុងឱកាសលៀងសាយភោជន៍ទទួលគណៈប្រតិភូថៃ លោក អៀង សារី បានបញ្ចេញឲ្យដឹងនូវមូលហេតុនៃការផ្លាស់ប្តូរនយោបាយរបស់ខ្មែរក្រហម ។ គាត់និយាយថារដ្ឋាភិបាលណាក៏ដោយនៅក្នុងតំបន់ ទោះជាកុម្មុយនីស្ត ឬ មិនមែនកុម្មុយនីស្តសុទ្ធតែមានផលប្រយោជន៍ ក្នុងការគាំទ្រខ្មែរក្រហម ក្នុងសង្គ្រាមប្រឆាំងកងទ័ពឈ្លានពានរបស់វៀតណាម ដែលគេហៅថាពួកពង្រីកទឹកដីលេបទឹកដីដែលមានមហិច្ឆតាឥតឈប់ឈរ ។ នៅពេលនោះគឺជាពេលដែលកងទ័ពខ្មែរក្រហម និង កងទ័ពវៀតណាម កំពុងវាយប្រហារគ្នាយ៉ាងខ្លាំងក្លានៅតាមទល់ដែន ។ អៀង សារី និយាយថា "ប្រសិនបើកម្ពុជាប្រជាធិបតេយ្យរបស់យើងមិនបានសុខសន្តិភាពទេ ដោយសារអំពើរំលោភឈ្លានពាន ឬ ដោយសារការជ្រៀតជ្រែកបញ្ហាផ្ទៃក្នុងនោះ ប្រទេសឯទៀតនៅក្នុងអាស៊ីភាគអាគ្នេយ៍នេះ ក៏មិនមានសន្តិភាព និង សន្តិសុខដែរ" ។ ចំពោះទំនាក់ទំនងទ្វេភាគីវិញ អៀង សារី បន្តក្នុងសុន្ទរកថារបស់គាត់ថា "យើងមិនត្រូវធ្វើអ្វីរំលោភលើសន្តិសុខគ្នាទៅវិញទៅមកនោះទេ ដូចជាសកម្មភាពឈ្លបយកការណ៍ ឬ ធ្វើអំពើវិទ្ធង្សនាគ្រប់យ៉ាង យើងមិនត្រូវអនុញ្ញាតឲ្យនរណាម្នាក់ប្រើប្រាស់ទឹកដីយើងដោយផ្ទាល់ ឬ ដោយប្រយោលក្នុង

ប្រការណាក៏ដោយ......... ដែលផ្ទុយពីសេចក្តីថ្លែងការណ៍រួមថៃ-កម្ពុជា នាខែ តុលា ១៩៧៥" ។ លោក អៀង សារី ចង់រំលឹកទៅដល់សកម្មភាពសម្ងាត់របស់ក្រុមខ្មែរមិនមែនកុម្មុយនីស្ត ឬ ខ្មែរសេរី ដែលផ្តុងផ្តើម និង គាំទ្រដោយឧត្តមសេនីយថៃមួយចំនួន ។ យុទ្ធជនអ្នកតស៊ូប្រឆាំងខ្មែរក្រហមទាំងនោះ ត្រូវបានជ្រើសរើសក្នុងចំណោមជនភៀសខ្លួនខ្មែរ ដែលរស់នៅក្នុងជំរុំក្នុងប្រទេសថៃ នៅតាមតំបន់ទល់ដែន ។ ឆ្លើយតបចំពោះសុន្ទរកថារបស់លោក អៀង សារី រដ្ឋមន្ត្រីការបរទេសថៃបាននិយាយថា "គឺ ជាការគួរឲ្យសោកស្តាយណាស់ ដែលយើងមានការមិនយល់គ្នានាពេលកន្លងមក ហើយមានអំពើខ្លះបានកើតឡើងដោយ ដៃមនុស្សទី ៣" ។

## នរណាជាដៃទី៣?

នៅទីក្រុងបាងកក ឧត្តមសេនីយ គ្រៀងស័ក្តិ នាយករដ្ឋមន្ត្រីថៃបាននិយាយប្រាប់អ្នកសារព័ត៌មានអំពីតួនាទី "ដៃមនុស្សទី៣" ដែលគាត់ហាក់ដូចជាទទួលស្គាល់ថា ខ្មែរក្រហមមិនមែនជាអ្នកទទួលខុសត្រូវចំពោះការប៉ះទង្គិចនៅតាមទល់ដែននោះឡើយ ។ ក៏ប៉ុន្តែរដ្ឋាភិបាលថៃមិនបានបង្ហើបឲ្យដឹងថា តើនរណាដែលស្ថិតនៅពីក្រោយ "ដៃមនុស្សទី៣" នោះឡើយ ។ រឿងរ៉ាវដ៏ចម្លែករបស់កម្លាំងទីបី ឬ ដៃមនុស្សទី៣នេះ បានត្រូវបណ្តាញសារព័ត៌មានថៃ ទម្លាយឲ្យដឹងពីរខែក្រោយមក ។ រឿងនោះត្រូវបែកធ្លាយ នៅពេលដែលអាជ្ញាធរថៃចាប់បានគ្រឿងអាវុធមួយចំនួននៅស្រុកអារញ្ញប្រាថេត ។

កាលនោះគឺ នៅល្ងាចថ្ងៃទី ២០ ធ្នូ ១៩៧៧[60] នៅតាមផ្លូវក្នុងស្រុកអារញ្ញប្រាថេត ក្រុមកាយរិទ្ធដែលគេដាក់ឲ្យធ្វើការជួយប៉ូលីស បានរកឃើញគ្រឿងយុទ្ធភ័ណ្ឌដែលមានកាំភ្លើងAK 47 កាំភ្លើង M16 គ្រាប់បែក និង ស្បៀងមួយចំនួនដែលត្រូវដឹកតាមរថយន្តប៊ុស (Bus) មួយ ដោយមានជនជាតិខ្មែរ ៣០ នាក់ និង ព្រះសង្ឃ ៤ អង្គ ។ ប៉ូលីសបានចាប់រថយន្តនោះ ដោយស្មានថាជាការរត់ពន្ធគ្រឿងអាវុធ ហើយឃាត់ខ្លួនមនុស្សទាំងអស់នៅពេលនោះ ។ នៅទីបំផុតក្រុមខ្មែរទាំងនេះក៏បានបង្ហាញនូវអត្តសញ្ញាណរបស់ខ្លួនថា ពួកគេជាសមាជិកចលនាតស៊ូខ្មែរប្រឆាំងកុម្មុយនីស្ត ដែលបានទទួលការគាំទ្រពីបញ្ជាការនៃកិច្ចប្រតិបត្តិការសន្តិសុខផ្ទៃក្នុងថៃ (Internal Security Operations Command) អាយ អេស អូស៊ី (ISOC) ។ នៅពេលនោះ នាយប៉ូលីសក៏បានធ្វើការទាក់ទងជាមួយអង្គភាព អាយ អែស អូ ស៊ី ជាបន្ទាន់ ។ ស្អែកឡើង នាយទាហានថ្នាក់វរសេនីយឯករបស់អាយ អែស អូ ស៊ី ក៏បានមកដល់ទីកន្លែងទាំងព្រឹកព្រលឹម ហើយក៏បានសំរួលឲ្យមានការដោះលែងយុទ្ធជនខ្មែរទាំង ៣០ នាក់នោះ ។

ពួកខ្មែរទាំងនោះជាសមាជិកចលនាតស៊ូខ្មែរ ដែលបានទទួលការឧបត្ថម្ភយ៉ាងខ្លាំង ពីព្រះសង្ឃថៃមួយអង្គព្រះនាមព្រះគ្រូ គិទិវុទ្ធោ ចៅអធិការវត្តចិត្តាផាវន្តនៅជាប់មាត់សមុទ្រក្បែរទីក្រុងប៉ាតាយ៉ានៃប្រទេសថៃ ។ ព្រះសង្ឃថៃអង្គនេះ មានព្រះនាមល្បីល្បាញ ដោយលោកចេញមុខបង្ហាញគោលជំហរនយោបាយស្តាំជ្រុលនិយមប្រឆាំងកុម្មុយនីស្តរបស់ព្រះអង្គ ។ លោកធ្លាប់ទេសនាពន្យល់ឧបាសកឧបាសិកាថា "សម្លាប់ពួកកុម្មុយនីស្តមិនបាបទេ" ។ ព្រះសង្ឃអង្គនេះធ្លាប់បញ្ចេញមតិថា លោកមិនខ្លាចលះបង់ស្បង់ចីវរ ដើម្បីកាន់អាវុធតស៊ូច្បាំងទល់ជាមួយកុម្មុយនីស្តក្នុងការការពារជាតិ សាសនា និង រាជបល្ល័ង្កថៃ ។ ព្រះអង្គដើរតួនាទីដ៏សំខាន់

[60] Richard Nations, Busload of Trouble, Far Eastern Economic Review, March 10, 1978, p.10.

ក្នុងយុទ្ធសាស្ត្រប្រឆាំងកុម្មុយនីស្តរបស់ប្រទេសថៃ ។ ហេតុដូច្នេះ ទើបព្រះគ្រូ គិទិវុទ្ធោ ធ្វើសកម្មភាពចិញ្ចឹមចលនាតស៊ូខ្មែរសេរី ឬ ខ្មែរសេរីកាយ៉ាងពេញទំហឹង ។ លោក អ៊ឹម ឈូដេត ដែលជាមេដឹកនាំចលនាខ្មែរសេរីកាម្នាក់ដែរនោះ គោរពប្រណិប័តព្រះគ្រូ គិទិវុទ្ធោ ជាគ្រូរបស់គាត់ផ្ទាល់ ។ មនុស្សរបស់លោក អ៊ឹម ឈូដេត មួយចំនួនធំ ដែលគេស្គាល់ថាជាសមាជិកចលនារាជសីហ៍ សុទ្ធតែធ្លាប់មកស្នាក់អាស្រ័យនៅវត្តចិត្តាផាវន្ត ដែលនៅទីនោះពួកគេតែងទទួលបាននូវម្ហូបអាហារ និង ប្រាក់កាសពីព្រះគ្រូព្រះចៅអធិការ គិទិវុទ្ធោ ជានិច្ច ។

តាមធម្មតាព្រះគ្រូចៅអធិការអង្គនេះ មានខ្សែបណ្តាញរបស់លោកក្នុងចំណោមក្រុមស៊ើបការសំងាត់ថៃ ដែលបង្កប់ខ្លួននៅតាមជាយដែនខ្មែរ-ថៃ ។ បណ្តាញនេះ ជាអ្នកសម្រឹតសម្រាំងជ្រើសរើសជនភៀសខ្លួន ដែលឆ្លងដែនចូលមកក្នុងប្រទេសថៃតាមជំរុំក្តី ឬ ក្រៅជំរុំក្តី ហើយដែលចង់ចូលរួមចលនាតស៊ូខ្មែរប្រឆាំងកុម្មុយនីស្ត ។ នៅពេលណាដែលខ្សែបណ្តាញបានត្រួតពិនិត្យ តាមរយៈការធ្វើសម្ភាសន៍ជាច្រើនលើកច្រើនសាមក និង ដឹងច្បាស់ថាជនភៀសខ្លួនខ្មែរនោះប្រាកដជាមានបំណងចង់ចូលរួមក្នុងចលនាប្រឆាំងកុម្មុយនីស្តមែន ខ្សែបណ្តាញនឹងនាំជនភៀសខ្លួនទៅស្នាក់នៅវត្តចិត្តាផាវន្តជាបណ្តោះអាសន្ន ដើម្បីរង់ចាំជួបអ្នកទទួលខុសត្រូវខ្មែរសេរី ឬ ខ្មែរសេរីកា ។ តាមធម្មតា មនុស្សចំណូលថ្មីមិនទាន់អាចជួបព្រះគ្រូចៅអធិការភ្លាមទេ នៅពេលមកដល់វត្តចិត្តាផាវន្ត ។ ក៏ប៉ុន្តែ ព្រះគ្រូចាត់ចែងឲ្យទំនុកបំរុងបាយទឹកនំចំណីមិនឲ្យខ្វះឡើយ ។ មនុស្សសំខាន់ អាចដើរលេងតាមឆ្នេរសមុទ្ររបស់វត្ត និង ទទួលប្រាក់កាសខ្លះសម្រាប់ចាយវាយ ក្នុងរយៈពេលរង់ចាំនេះ ។

ច្រើនថ្ងៃបន្ទាប់មក ទើបអ្នកទទួលខុសត្រូវខ្មែរទៅដល់វត្តចិត្តាផាវន្ត ។ នៅ

ពេលដែលអ្នកទទួលខុសត្រូវខ្មែរ ទទួលយកមនុស្សថ្មីនោះថាជាសមាជិករបស់គេហើយ ទើបគេទាំងអស់គ្នានាំគ្នាទៅថ្វាយបង្គំលោកគ្រូចៅអធិការ ដើម្បីធ្វើពិធីស្បថស្បែសច្ចាប្រណិធាន ប្ដេជ្ញាមិនក្បត់គ្នា និង សុំពរជ័យពីព្រះអង្គ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ ព្រះគ្រូ គិទិវុទ្ធោ ចាត់ឲ្យមានពិធីផឹកទឹកសម្បថ ដើម្បីឲ្យសមាជិកថ្មីប្ដេជ្ញាធ្វើការចូលរួមតស៊ូដើម្បីរំដោះជាតិខ្មែរ និង ដើម្បីកសាងប្រទេសកម្ពុជាជាសាធារណរដ្ឋ ឲ្យមានសេរីភាពបរិបូណ៌ និង លទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។ នៅសម័យនោះ គ្មាននរណានឹកថា ប្រទេសយើងអាចវិលមកយករបបរាជានិយម ជាពិសេស របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញដូចសព្វថ្ងៃនេះទេ ។ ម្យ៉ាងទៀតអ្នកណាក៏ដឹងដែរថា តាំងពីសម័យសង្គមរាស្ត្រនិយមរបស់សម្ដេច នរោត្តម សីហនុ ក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និង ១៩៦០ មកម្ល៉េះ ប្រទេសថៃធ្លាប់ធ្វើជាជំរករបស់ក្រុមខ្មែរសេរីដឹកនាំដោយលោក សឺង ង៉ុក ថាញ់ ដែលសម្ដេច សីហនុ ចោទថា ជាពួកសាធារណរដ្ឋប្រឆាំងព្រះរាជបល្ល័ង្កខ្មែរ ។ ដូច្នេះការជួយគាំទ្រអ្នកសាធារណរដ្ឋនិយមខ្មែរ ក៏អាចជាទម្លាប់របស់អ្នកនយោបាយថៃ ប្រឆាំងរបបគ្រប់គ្រងរាជានិយមខ្មែរបានយ៉ាងដូច្នោះដែរ ។ ក្នុងសកម្មភាពប្រឆាំងកុម្មុយនីស្តរបស់លោក ព្រះគ្រូ គិទិវុទ្ធោ ប្រាកដជាមានកិច្ចសហការដ៏ជិតស្និទ្ធពីកងទ័ពថៃមិនលែងឡើយ ។ លោកពិតជា សមាជិកដ៏សំខាន់មួយរូបនៃអ្វីដែលហៅថា "ដៃមនុស្សទី៣" ឬ "កម្លាំងទី៣" ដែលប្រើប្រាស់កងកម្លាំងប្រដាប់អាវុធខ្មែរសេរី ឬ ខ្មែរសេរីកា បង្កឲ្យមានការប៉ះទង្គិច ខាងផ្លូវអាវុធជាញឹកញាប់ជាមួយខ្មែរក្រហម ធ្វើឲ្យពួកខ្មែរក្រហមនេះវាយបកសងសឹកវិញទៅលើអ្នកស្រុកថៃ នៅតាមបណ្ដាភូមិនានាជាប់ទល់ដែនខ្មែរ-ថៃ ។ ដូច្នេះ ឧត្តមសេនីយ គ្រឿងស័ក្តិ ប្រាកដជាដឹងថានរណាជា "ដៃមនុស្សទី៣" ឬ "កម្លាំងទី៣" នេះ ។

តាមពិតតាំងពីពេលពាក់កណ្ដាលខែ មិថុនា ១៩៧៦ មកម្ល៉េះ នៅប្រទេស

បារាំង ខ្ញុំក៏បានឃើញអត្ថបទនៅក្នុងសារព័ត៌មានបារាំងមួយចំនួន និយាយអំពីចលនាតស៊ូតាមផ្លូវអាវុធប្រឆាំងនឹងក្រុមខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ឧទាហរណ៍ដូចជា អត្ថបទស្ដីអំពីយុទ្ធជនសម្ងាត់មួយក្រុមដើរឈ្លប និង យាមល្បាតក្នុងព្រៃក្នុងប្រទេសខ្មែរ ។ ក្រុមនោះមានមេដឹកនាំសុទ្ធតែជាអតីតនាយទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលធ្វើការតស៊ូ ដើម្បីរំដោះប្រទេសកម្ពុជាឲ្យមានសេរីភាព និង លទ្ធិប្រជាធិបតេយ្យឡើងវិញ ។

បើយើងសិក្សាឲ្យស៊ីជំរៅ អំពីយុទ្ធសាស្ត្រប្រឆាំងកុម្មុយនីស្តរបស់ថៃ "ដៃមនុស្សទី៣" ឬ "កម្លាំងទី៣" នេះជាកម្លាំងដែលបញ្ជាការកិច្ចប្រតិបត្តិការសន្តិសុខផ្ទៃក្នុងថៃ (អាយ អេស អូ ស៊ី) បង្កើតឡើង ដើម្បីទប់ទល់ដំណើររុលទៅមុខនៃប្រទេសឥណ្ឌូចិនទាំងបីនាសម័យនោះគឺ លាវ វៀតណាម និង កម្ពុជាប្រជាធិបតេយ្យ ។ បញ្ជាការកិច្ចប្រតិបត្តិការសន្តិសុខផ្ទៃក្នុងថៃ ប្រាកដជាបានអនុវត្តគោលនយោបាយរបស់ក្រុមប្រឹក្សាសន្តិសុខជាតិរបស់ប្រទេសថៃ ដែលអនុញ្ញាតឲ្យមានការលួចលាក់ចិញ្ចឹមកងកម្លាំង ដែលពីមុនមានឈ្មោះខ្មែរសេរី ឬ ក្រោយមកមានឈ្មោះថាខ្មែរសេរីកា ក៏ដូចជាលួចចិញ្ចឹមកងកម្លាំងវៀតណាមសេរី និង ឡាវសេរីដែរ ។ សកម្មភាពនៃអង្គភាពពិសេសរបស់កងទ័ព និង សកម្មភាពរបស់ព្រះគ្រូគិទិវិទ្ធោ ជារួមមានការជួយចិញ្ចឹមកងកម្លាំងដែលហៅថា "ខ្មែរសេរីកា" ទាំងអស់ ។ សមាជិកមួយចំនួននៃចលនាតស៊ូហៅថា រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ(រ.ជ.រ.ប.ខ) បាននិយាយប្រាប់ខ្ញុំយ៉ាងហូរហែ អំពីការពាក់ព័ន្ធរបស់អាជ្ញាធរថៃក្នុងជីវិតតស៊ូរបស់ពួកគេ ។

# ទាហានថៃជួយយុទ្ធជនសេរីកា

សមាជិកម្នាក់ឈ្មោះ ឡេង បានរៀបរាប់ប្រវត្តិរបស់គាត់ ប្រាប់ខ្ញុំដូចតទៅ ៖ នៅខែ មេសា ១៩៧៥ នៅពេលដែលខ្មែរក្រហម ចូលដល់ទីរួមខេត្តបាត់ដំបង ប្រជាពលរដ្ឋទាំងអស់បានត្រូវពួកខ្មែរក្រហមជម្លៀស ឲ្យទៅរស់នៅស្រុកស្រែទាំងអស់ ។ ក្នុងសម័យនោះ ឡេង ជាសិស្សថ្នាក់ទីបញ្ចប់នៃវិទ្យាល័យ ។ ឡេង បានត្រូវខ្មែរក្រហមចាត់ឲ្យធ្វើការក្នុងក្រុមចល័ត ដែលត្រូវរើទីតាំងពីស្រុកមួយទៅស្រុកមួយឥតឈប់ឈរ ។ ក្នុងខែ កក្កដា ១៩៧៧ ឡេង ត្រូវបានគេប្រើឲ្យធ្វើជាអ្នកវាស់ដីនៅទំនប់កំពីងពួយ ភាគខាងលិចនៃប្រទេសកម្ពុជា ។ នៅទីនោះ ជាញឹកញាប់នៅពេលយប់ គេតែងឃើញយុទ្ធជនសេរីកាចំនួនបួន ឬ ប្រាំនាក់ ក្នុងសំលៀកបំពាក់ខ្មៅដូចខ្មែរក្រហម តែងមកធ្វើការឃោសនាបំផុសបំផុលប្រឆាំងខ្មែរក្រហម ។ ពួកយុទ្ធជនទាំងនោះ មានមូលដ្ឋានសម្ងាត់ដែលគ្មាននរណាដឹងឡើយ ។ ដោយមិនអាចទ្រាំទ្រចំពោះទារុណកម្មដែលពួកខ្មែរក្រហមធ្វើមកលើខ្លួន ដោយសារការខ្វះខាត និង ដោយចង់បានសេរីភាពផង ឡេង ព្រមជាមួយមិត្តរួមការងារម្នាក់ទៀតឈ្មោះ ដា បានសំរេចចិត្តលបរត់ចេញពីការត្រួតត្រារបស់ខ្មែរក្រហម ទៅរកមូលដ្ឋានសម្ងាត់របស់អ្នកតស៊ូនៅតាមព្រំដែនខ្មែរ-ថៃ ។

ដើម្បីត្រៀមដំណើរនោះ ពួកគេចាប់ផ្តើមលបលួចអង្ករយកទៅលាក់ទុកនៅក្នុងព្រៃ ។ ក្រោយដែលគេសន្សំបានអង្ករប្រហែលកន្លះគីឡូក្រាម ពួកគេក៏លបដាំបាយ ។ ថ្ងៃមួយគេលួចរត់ចេញពីភូមិ ។ បន្ទាប់ពីបានដើរដោយជើងទទេឆ្លងកាត់វាលស្រែដ៏ធំល្វឹងល្វើយ និង ព្រៃជ្រៅយ៉ាងក្រាស់អស់រយៈពេលមួយសប្តាហ៍ យុវជនដ៏ក្លាហានទាំងពីរនាក់ បានមកដល់ទល់ដែន ព្រោះពួកគេស្គាល់ទីនោះជាតំបន់

ភ្នំបន្ទាត់ ។ ពួកគេមិនដឹងថាមូលដ្ឋានពួកសេរីកានោះស្ថិតនៅតំបន់ណាទេ ក៏ប៉ុន្តែគេបានប្តេជ្ញាចិត្តថា ត្រូវតែទៅរួបរួមជាមួយពួកអ្នកតស៊ូទាំងនោះ ប្រឆាំងខ្មែរក្រហម ប៉ុល ពត ។ អស់ជាច្រើនថ្ងៃ ពួកគេមិនឃើញមានផ្ទះ ឬ ភូមិអ្នកស្រុកណាមួយសោះ ។ ពួកគេហេវហត់អស់កម្លាំងខ្លាំងណាស់ នៅពេលចូលទៅដល់ភូមិដាច់ស្រយាលមួយ ។

ពេលនោះ ពួកគេមិនទាន់ដឹងថា ខ្លួនបានចូលទៅក្នុងទឹកដីថៃនៅឡើយទេ ។ ព្រឹកនោះ នៅពេលឃើញផ្ទះទីមួយដំបូងបង្អស់ ពួកគេក៏ស្ទុះចូលទៅ ។ នៅក្នុងផ្ទះ មនុស្សម្នាក់កំពុងអង្គុយទទួលទានអាហារពេលព្រឹក ។ បុរសនោះ ជាមន្ត្រីនគរបាលព្រំដែនរបស់ថៃ ។ នៅពេលដែលក្រឡេកឃើញយុវជនខ្មែរទាំងពីរនាក់ភ្លាមនោះ នគរបាលថៃនេះមានការតក់ស្លុតណាស់ ព្រោះអ្នកទាំងពីរនាក់នោះចូលទៅដល់ទូដែលផ្ទុកទៅដោយកាំភ្លើង ។ នគរបាលថៃនឹកសង្ស័យថា ប្រហែលជាពួកខ្មែរក្រហមរំលោភឆ្លងដែនចូលមក ដោយហេតុតំបន់នេះជាតំបន់មានការប៉ះទង្គិចជាញឹកញាប់ជាមួយពួកខ្មែរក្រហម ។ ក៏ប៉ុន្តែយុវជនខ្មែរទាំងពីរនាក់នោះ មិនមានបំណងអាក្រក់អ្វីទៅលើរូបនគរបាលថៃនេះទេ ហើយថែមទាំងមិនដឹងខ្លួនថាពួកគេកំពុងឈរក្បែរទូកាំភ្លើងនោះទៀតផង ។ ម្យ៉ាងទៀត ពួកគេក៏មិនទាន់ដឹងថាកំពុងជាន់លើទឹកដីថៃផង ។ ដោយសារការខំប្រឹងធ្វើដំណើរជាច្រើនថ្ងៃនោះ ពួកគេអស់កម្លាំងខ្លាំងពេក មិនអាចហើបមាត់និយាយ ឬ ធ្វើកាយវិការអ្វីបានដោយស្រួលឡើយ ។

នគរបាលថៃនោះ ក៏ហៅជំនួយការខ្មែររបស់គាត់ឲ្យជួយបកប្រែ ព្រោះអ្នកទាំងពីរនាក់នោះមិនចេះនិយាយភាសាថៃសោះ ។ នៅទីបំផុត នគរបាលថៃក៏បានដឹងថា យុវជនខ្មែរទាំងពីរនាក់នោះ គ្មានចេតនាអាក្រក់ ឬ សកម្មភាពអមិត្តមកលើរូបគាត់ឡើយ ។ គាត់ក៏ឲ្យរៀបបាយទឹកឲ្យអ្នកទាំងពីរទទួលទាន រួចទើបបញ្ជូនទៅ

ទីស្នាក់ការនគរបាល ដើម្បីសួរចម្លើយ ព្រោះគេនៅសង្ស័យថាយុវជនទាំងពីរអាចជាទាហានខ្មែរក្រហមមកបន្លំស៊ើបការណ៍ ។ នៅទីស្នាក់ការនគរបាលថៃ ឡេង និង ជា បានត្រូវគេដាក់ខ្នោះ និង ចងមុខបិទភ្នែក ។ មន្ត្រីនគរបាលម្នាក់ទៀតជាអ្នកសួរចម្លើយ ដោយជួនកាលមានទាំងភ្ជង់កាំភ្លើងផងតាមបច្ចេកទេសឈ្លេចសួរចម្លើយ ដើម្បីបញ្ជាក់ឲ្យច្បាស់ថាប្រាកដជាអ្នករត់ចេញពីខ្មែររបបក្រហម និង ពិតជាមិនមែនទាហានខ្មែរក្រហមទេ ។ សំណួរមានជាអាទិដូចជាតើអ្នកឯងជាទាហានខ្មែរក្រហមឬ?តើអង្គភាពអ្នកឯងនៅត្រង់ចំណុចណា? តើមេអ្នកឯងឈ្មោះអ្វី? ក៏ប៉ុន្តែចម្លើយរបស់អ្នកទាំងពីរនៅតែដដែលៗមិនផ្លាស់ប្តូរអ្វីឡើយគឺៈ ពួកខ្ញុំមិនមែនជាទាហានខ្មែរក្រហមទេ ហើយក៏មិនស្គាល់មេទ័ពខ្មែរក្រហមណាម្នាក់ដែរ ពួកខ្ញុំដើររកក្រុមខ្មែរតស៊ូប្រឆាំងខ្មែរក្រហម ព្រោះពួកខ្ញុំចង់ទៅចូលរួមជាមួយយុទ្ធជនសេរីកា ។ បន្ទាប់ពីសួរចម្លើយយ៉ាងយូរ យុវជនខ្មែរទាំងពីរនាក់នោះ ត្រូវបានគេបញ្ជូនតាមរថយន្តទៅទីស្នាក់ការនគរបាលស្រុក ប្រចាំស្រុកប៉ុងណាំរ៉ង ដែលពួកគេទាំងពីរនាក់បានទៅដល់នៅវេលាថ្ងៃត្រង់ ។ នៅទីនោះ ពួកគេមិនបានត្រូវដាក់ខ្នោះ ឬ ចងមុខដូចពីមុនទៀតទេ មិនតែប៉ុណ្ណោះថែមទាំងបានទទួលបាយទឹកជាថ្មីម្តងទៀតផង ។ ទោះបីជានៅមិនទាន់ដឹងអំពីជោគវាសនារបស់ពួកគេយ៉ាងណាក៏ដោយ ដោយសារអត់ឃ្លានជាយូរថ្ងៃមកហើយនោះ អ្នកទាំងពីរគិតតែខំទទួលទានម្ហូបអាហារឲ្យបានច្រើន ។ នៅជាមួយខ្មែរក្រហម ពួកគេត្រូវធ្វើការងារជាទម្ងន់ ហើយទទួលទានតែបបរតែប៉ុណ្ណោះ ។ នគរបាលនៅតែបន្តសួរសំណួរដដែលៗ ឯចម្លើយវិញ ក៏នៅតែដដែលៗមិនផ្លាស់ប្តូរអ្វីឡើយ ។

នៅពេលដែលពួកនគរបាលទាំងនោះ អស់មានក្តីមន្ទិលសង្ស័យលើយុវជនខ្មែរទាំងពីរនាក់នោះហើយ និង ក្រោយពីដឹងថាពួកគេទាំងពីរនាក់ ពិតជាមានបំណងទៅចូលរួមចលនាតស៊ូប្រឆាំងខ្មែរក្រហមប្រាកដមែន ទើបពួកនគរបាល

បញ្ជូនដំណឹងទៅនាយទាហានថៃម្នាក់ឲ្យធ្វើការសើុបសួរបន្តទៅទៀត ។ ពេលនោះ គេដឹកអ្នកទាំងពីរយ៉ាងរហ័ស ទៅក្នុងបរិវេណនៃទីបញ្ជាការទ័ពពិសេសថៃមួយ ដែលគ្មាននរណាអាចដឹងទីកន្លែងច្បាស់លាស់បានឡើយ ព្រោះទីកន្លែងនោះមានសភាពហាក់ដូចជាផ្ទះសម្បែងរបស់អ្នកស្រុកធម្មតា ។ អង្គភាពយោធាពិសេសនេះមានមួយឈុតដែលមានថ្នាក់ដឹកនាំម្នាក់ និង នាយទាហានពីរនាក់ ។ ពួកទាហានទាំងនោះមិនស្លៀកពាក់ ឬ បង្ហាញសញ្ញាថាពួកគេជាកងទ័ពនោះឡើយ ។ នៅទីនោះ ឡេង និង ជា ត្រូវទាហានថៃឃុំឃាំងក្នុងរថយន្តដ៏ធំមួយ អស់រយៈពេលប្រហែលមួយសប្តាហ៍ ។ នៅពេលនោះ អ្នកទាំងពីរនាក់ក៏បានសំគាល់ថាមានជនជាតិខ្មែរពីរនាក់ទៀតធ្វើការនៅទីនោះដែរ ជាអ្នកដាំបាយ ដាំតែ ឬ បោសសំអាត ។ នៅក្នុងបរិវេណទីស្នាក់ការទាហានឈុតពិសេសនេះ ឡេង និង មិត្តរបស់គេ មិនត្រូវជាប់ខ្នោះទៀតឡើយ ។ ក្រោយមក ទើបគេអនុញ្ញាតឲ្យអ្នកទាំងពីរទៅរស់នៅបន្ទប់មួយក្បែរនោះ ។ ក្នុងនោះ គេឲ្យទៅជួយធ្វើការដូចខ្មែរពីរនាក់ទៀតនោះដែរគឺ ជួយដាំបាយ និង បោសសំអាត ។ បន្ទាប់មកក្រុមយោធាក៏ធ្វើសម្ភាសន៍អ្នកទាំងពីរម្តងទៀតដែលមានសំណួរខ្លះដូចសំណួររបស់នគរបាលដែរ តែមានមួយចំនួនទៀតមានលក្ខណៈច្បាស់លាស់ជាង ដូចជាសំណួរថាតើអ្នកទាំងពីរនាក់ចេះធ្វើអ្វីខ្លះ? ចេះនិយាយភាសាអ្វីខ្លះ? មួយខែបន្ទាប់មក ក្រោយពីបានរស់នៅក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់នោះ ទាហានថៃក៏សួរ ឡេង និង ជា ថាតើអ្នកទាំងពីរនាក់ចង់ទៅចូលរួមជាមួយក្រុមសេរីកាមែន ឬ ក៏ចង់ទៅកាន់ជំរុំជនភៀសខ្លួន ឬ ក៏ចង់វិលត្រឡប់ទៅប្រទេសកម្ពុជាវិញ ។

នៅពេលដែលយោធាថៃប្រាកដក្នុងចិត្តថា ឡេង និង ជា ពិតជាចង់ចូលរួមក្នុងក្រុមសេរីកាមែន ពួកគេក៏ដឹកអ្នកទាំងពីរទៅកន្លែងយោធាមួយទៀត នៅក្នុងទីរួមខេត្តត្រាត ។ ពីត្រាត គេបញ្ជូនតាមរថយន្ត ទៅបរ៉ាយ ជាទីកន្លែងជីករកត្បូង

នៅក្នុងខេត្តច័ន្ទបូរី ។ នៅបរ៉ាយ ពួកថៃនាំពួកគេទាំងពីរនាក់ទៅកន្លែងមួយឆ្ងាយពីគេឯង ។ នៅទីនោះ គេឃើញមានឃ្លាំងមួយដ៏ធំ ដែលគេទុកស្បៀងរាប់រយបាវ ។ នៅក្នុងឃ្លាំងនោះ គេឃើញកម្មករប្រមាណដប់នាក់និយាយភាសាខ្មែរ កំពុងប្រញ៉ឹកដៃលី ឬ សែងបាវអង្ករ ត្រីងៀត ប្រេងឆា និង របស់របរជាច្រើនមុខទៀត ។ ប៉ុន្មាននាទីក្រោយមក អ្នកទាំងនោះក៏នាំស្បៀងទាំងនោះ ធ្វើដំណើរចូលព្រៃបាត់ទៅ ។ កន្លះម៉ោងក្រោយមក មនុស្សមួយក្រុមទៀតក៏មកដល់ ។ ក្នុងចំណោមនោះ ឡេង អាចសំគាល់ឃើញមិត្តចាស់របស់គេម្នាក់ឈ្មោះ ភាព ដែលទំនងដូចជាមេផ្នែកភ័ស្តុភារនៃក្រុមទាំងពីរ ។ នៅពេលគេអាចនិយាយខ្មែរបានជាមួយ ភាព ទើបឡេងដឹងថា នៅទីបំផុតខ្លួនបានជួបជាមួយនឹងក្រុមអ្នកតស៊ូខ្មែរមែន ។ ក៏ប៉ុន្តែ ភ្លាមនោះ ឡេង និង ជា មិនអាចចូលទៅជាមួយនឹងពួកខ្មែរទាំងនោះបានទេ ព្រោះពួកគេត្រូវរង់ចាំរហូតដល់យោធាថៃមួយឈុតទៀត ក្នុងសំលៀកបំពាក់ស៊ីវិល លេចចេញពីក្នុងព្រៃមក ដោយជិះម៉ូតូជប៉ុនផង មកប្រាប់ឲ្យពួកគេទាំងពីរនាក់ដើរតាមយុទ្ធជនខ្មែរអ្នកតស៊ូទៅមូលដ្ឋានរបស់គេ នៅប៉ុន្មានគីឡូម៉ែត្រឆ្ងាយពីនោះ ។ នៅពេលគេដើរដល់ជើងភ្នំបន្ទាត់ ឡេង ឃើញខ្ទមមួយ ដែលមានប្រក់សំពត់ប្លាស្ទីកទំហំប្រាំម៉ែត្របួនជ្រុង ប្រដាប់ដោយគ្រឿងសម្ភារៈពេទ្យបន្តិចបន្តួច ដែលនោះជាផ្ទះពេទ្យរបស់អ្នកតស៊ូ ។ នៅក្នុងផ្ទះពេទ្យនេះ មានពេទ្យខ្មែរជាអ្នកគ្រប់គ្រង ពួកគេកំពុងព្យាបាលអ្នកជម្ងឺខ្មែរ ប្រាំ ឬ ប្រាំមួយនាក់ ដែលកំពុងមានជម្ងឺគ្រុនចាញ់ ។ បន្ទាប់ពីដើរអស់រយៈពេលពីរម៉ោងមកទៀត ដោយឆ្លងកាត់អូរ និង ឡើងចុះទួលខ្ពស់ជាច្រើនមក នៅទីបំផុត ទាំងអស់គ្នាក៏ឡើងទៅដល់កំពូលភ្នំ ។

នៅពេលគេទៅដល់ច្រកចូលនៃទីបញ្ជាការយោធា ដែលស្ថិតក្នុងព្រៃលើភ្នំនោះ ឡេង សង្កេតឃើញទាហានខ្មែរកាន់កាំភ្លើងនៅដៃ ឈរតាមដើមឈើធំៗ នៅក្នុងព្រៃដ៏ក្រាស់ ដែលពន្លឺថ្ងៃស្ទើរតែជ្រៀតចូលពុំបាន ។ នៅក្នុងជំរុំយោធានោះ

ឡេង ឃើញខ្ទមឫស្សីប្លួន ។ ខ្ទមមួយជារបស់មេទ័ពខ្មែរ និង ខ្ទមមួយទៀតជារបស់ក្រុមឃោជាថៃ ដែលឈរជើងនៅទីនោះ ដើម្បីប្រមូលព័ត៌មាន និង ដើម្បីសំរបសំរួលផ្តល់ការគាំទ្រផ្នែកភ័ស្តុភារដល់ក្រុមអ្នកតស៊ូ ។ នៅទីបំផុត គេក៏នាំ ឡេង ឲ្យទៅជួបនឹងមេដឹកនាំខ្មែរគឺ លោកវរសេនីយ ព្រុំ វិត ដែលទទួលស្វាគមន៍ ឡេង យ៉ាងរាក់ទាក់ និង កក់ក្តៅ ។ លោកវរសេនីយ បានត្រូវកូនចៅគាត់ ហៅថា "លោកតា" ។ គាត់មានបុគ្គលិកលក្ខណៈគួរឲ្យចាប់អារម្មណ៍គឺ មានសម្បុរខ្មៅ តែរូបរាងមាំទាំខែងវែង ស្លៀកខោខ្លី និង បង់កក្រមា ។

លោកតាមានការគោរពរាប់អានពីកូនចៅគាត់ ដោយសារគាត់ជាមេទ័ពដែលមានគោលការណ៍ច្បាស់លាស់គឺជាអ្នកតស៊ូដែលគោរពវិន័យ ។ នៅពេលនោះសមាជិកចលនាទទួលស្គាល់ថា លោកតាបានយកជីវិតមកបំរើផលប្រយោជន៍រួម និង ដើម្បីរំដោះប្រទេសកម្ពុជាឲ្យចេញពីអំណាចផ្តាច់ការរបស់ពួកខ្មែរក្រហម ។ នេះជាករណីដែលបង្ហាញថានៅពេលនោះ ប្រាកដជាមានកងទ័ពខ្មែរសេរី ឬ សេរីកាដែលទទួលការឧបត្ថម្ភគាំទ្រដោយទាហានថៃ ។

មែនទែនទៅ នៅសម័យនោះ ចលនាតស៊ូប្រឆាំងខ្មែរក្រហម ទោះជាមានការចងកំហឹង និង ស្អប់ខ្ពើមខ្មែរក្រហមដល់កំរិតណាក៏ដោយ ក៏មិនអាចធ្វើសកម្មភាពអ្វីធំដុំ ដែលអាចឲ្យពួកប្រល័យពូជសាសន៍នេះ រង្គោះរង្គើ ឬ ព្រួយបារម្ភបានឡើយ ។ ម្យ៉ាង ការក្តាប់យ៉ាងណែននូវការគ្រប់គ្រងប្រជាពលរដ្ឋឲ្យរស់នៅតាមរបៀបសមូហភាពដ៏តឹងតែង មានធ្វើការជាទម្ងន់ និង បាយរួមជាដើមរបស់រដ្ឋអំណាចខ្មែរក្រហម[61] បង្កើតឧបសគ្គដ៏ធំដល់រាល់ការប៉ុនប៉ងរើបំរះ ឬ ការបះបោរពីសំណាក់ចលនា ឬ ក្រុមប្រឆាំងណាមួយ ដែលមានទីជំរកនៅតាមទល់ដែន ជា

---

[61] សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានវាយតម្លៃត្រឹមត្រូវល្អណាស់ចំពោះឧបសគ្គនៃការរើបំរះ នៅក្នុងសៀវភៅក្រោមចំណងជើង "១៣ ទសវត្សរ៍ នៃដំណើរកម្ពុជា" ការផ្សាយរបស់កាសែតប្រជាជនឆ្នាំ ១៩៩៦ ទំព័រ ២៣៤-២៣៧ ។

ពិសេស នៅទល់ដែនខ្មែរ-ថៃ ។ ម្យ៉ាងទៀត ជំនួយដែលប្រទេសថៃផ្តល់ដល់ចលនាតស៊ូប្រឆាំងខ្មែរក្រហមមានកំរិតតិចតួចណាស់ ។ ថៃត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់ក្នុងសកម្មភាពប្រឆាំងខ្មែរក្រហមរបស់ពួកគេ ព្រោះនៅពីក្រោយខ្មែរក្រហមមានប្រទេសចិនដ៏ធំមហិមា ដែលមានឥទ្ធិពលដ៏ខ្លាំងចំពោះសន្តិសុខផ្ទាល់របស់ប្រទេសថៃ ។

នៅសម័យនោះ ប្រទេសថៃកំពុងស្ថិតនៅក្នុងបរិបទនៃតំបន់មួយដែលទាមទារឲ្យមានកិច្ចសហការល្អជាមួយប្រទេសចិន ជាជាងធ្វើសកម្មភាពប្រឆាំងប្រទេសដ៏ធំនៃទ្វីបអាស៊ីនេះ ។ ដូច្នេះ នៅសម័យនោះ ប្រទេសថៃមិនអាចជាបង្អែកដ៏រឹងមាំសម្រាប់ធ្វើការផ្តួលរំលំរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យបានឡើយ ។ ថៃជួយចិញ្ចឹមដោយលួចលាក់នូវកម្លាំងខ្មែរសេរី ឬ ខ្មែរសេរីកាដើម្បីយកធ្វើជាឧបករណ៍ទុកសម្រាប់ជាថ្នូរដោះដូរជាមួយខ្មែរក្រហម និង ចិនក្នុងការរក្សាសន្តិសុខរបស់គេតែប៉ុណ្ណោះ ។ កម្លាំងតស៊ូដែលអាចផ្តួលរំលំរបប ប៉ុល ពត បាន មានតែកម្លាំងខ្មែរអ្នកតស៊ូផ្ទៃក្នុង ហើយដែលមានការគាំទ្រពីប្រទេស ដែលហ៊ានចេញមុខវាយប្រហាររបបនេះតែប៉ុណ្ណោះ ។ ព្រឹត្តិការណ៍ដែលកើតមានជាបន្តបន្ទាប់ក្រោយៗមក បានបញ្ជាក់នូវនិន្នាការនៃសច្ចធម៌នេះ ។

## ជម្លោះរវាងខ្មែរក្រហម និង វៀតណាម

ប្រសិនបើជម្លោះរវាងខ្មែរក្រហម និង ថៃ មានប្រភពដើមចេញពីមនោគមវិជ្ជាកុម្មុយនីស្ត ប្រឆាំងលទ្ធិមូលធននិយម ជម្លោះរវាងខ្មែរក្រហម និង វៀតណាម ដែលជាយុទ្ធមិត្តជាមួយគ្នានោះ កើតឡើងដោយសារមូលហេតុដទៃជាច្រើន ។

ម្យ៉ាង មហាប្រទេសកុម្មុយនីស្តពីរគឺចិន និង សហភាពសូវៀត[62] ដែលមានឥទ្ធិពលលើខ្មែរក្រហម និង វៀតណាម មានជម្លោះរវាងគ្នានិងគ្នា ។ ជម្លោះរវាងមហាប្រទេសកុម្មុយនីស្តនោះ បានជះផលប៉ះពាល់ទៅលើប្រទេសដែលដើរតាមពួកគេ ។

ការខ្វែងគំនិតគ្នារវាងចិន និង សហភាពសូវៀត មានរាប់សិបឆ្នាំមកហើយ គឺ មានតាំងពីទសវត្សរ៍ឆ្នាំ ១៩៦០ មកម្ល៉េះ ។ ជាដំបូង មានការខ្វែងគំនិតគ្នាក្នុងមនោគមវិជ្ជាកុម្មុយនីស្តនេះ ដែលបានចាប់ផ្តើមឡើងទៅទសវត្សរ៍ឆ្នាំ ១៩៥០ នៅពេលដែលសហភាពសូវៀត បោះបង់លែងប្រកាន់យកនូវរបបស្តាលីននិយម ឬ បន្ទាប់ពីលោកសេនាប្រមុខ ស្តាលីន ទទួលមរណភាពទៅ ។ ប្រទេសចិនបានចោទសហភាពសូវៀតថា ជាអ្នកសើរើនិយម ។ ចិនផ្តន្ទាទោសសហភាពសូវៀតចំពោះអ្វីដែលគេហៅថាអនុត្តរភាពរបស់សូវៀតនៅក្នុងពិភពលោក ។ ចិនប្រឆាំងនឹងនយោបាយរបស់សហភាពសូវៀតនៅអឺរ៉ុបខាងកើត ជាពិសេស ចំពោះព្រឹត្តិការណ៍នៅឆេកូស្លូវ៉ាគី នាឆ្នាំ ១៩៦៨ ។ ចិនចាត់ទុកសហភាពសូវៀតថា ជាសង្គមចក្រពត្តិ និង ថានយោបាយក្រៅប្រទេសរបស់សហភាពសូវៀត ជានយោបាយវាតទី ឬ អនុត្តរភាពនិយម ។

ជម្លោះទល់ដែនរវាងមហាប្រទេសទាំងពីរដែលបានផ្ទុះឡើងនៅឆ្នាំ ១៩៦៩ រឹតតែនាំឲ្យចិនមើលឃើញថា សហភាពសូវៀតគំរាមកំហែងយ៉ាងខ្លាំង ទៅលើសន្តិ

---

[62] សហភាពសូវៀត ជាបណ្តុំប្រទេសកាន់លិទ្ធិកុម្មុយនីស្ត ចំនួន ១៥ ដែលមានរដ្ឋធានីរួមនៅទីក្រុង ម៉ូស្គូ ក្រោមអំណាចរបស់គណបក្សកុម្មុយនីស្ត ។ ក្រោយសង្គ្រាមត្រជាក់ត្រូវបញ្ចប់ នៅពេលដែលសហភាពសូវៀតដួលរលំ ក្នុងឆ្នាំ១៩៩១ ប្រទេសទាំង ១៥ នោះបានប្រកាសជារដ្ឋឯករាជ្យគឺៈ រុស្ស៊ី (Russia) អ៊ុយក្រែន (Ukraine) ម៉ុលដាវី (Moldova) បេឡារុស(Belorussia) អាមេនី (Amenia) អាស៊ែបៃហ្សង់ (Azerbaijan) កាហ្សាក់ស្ថាន (Kazakhstan) អ៊ូសបេគីស្ថាន (Uzbekistan) តួកម៉េនីស្ថាន(Turkmenistan) កៀហ្ស៊ីស៊ីស្ថាន(Kyrgystan) តាជីគិស្ថាន (TajiKistan) អេសតូនី (Estonia) ឡាត់វី (Latvia) លីធូនី (Lithuania) ។ នៅក្នុងសង្គ្រាមត្រជាក់ សហភាពសូវៀតជាមេនៃប្លុកលោកកុម្មុយនីស្តប្រឆាំងនិងប្លុកលោកសេរី ដែលមានសហរដ្ឋអាមេរិកជាមេដឹកនាំ ។

សុខរបស់គេ ។ ចិនយល់ឃើញថា ពួកគេមានផលប្រយោជន៍យ៉ាងខ្លាំង ក្នុងការធ្វើសហប្រតិបត្តិការជាមួយសហរដ្ឋអាមេរិក និង លោកខាងលិច ដើម្បីប្រឆាំងនិងអនុត្តរភាពរបស់សហភាពសូវៀត ។ ម្យ៉ាងទៀត មេដឹកនាំចិនមើលឃើញថាកិច្ចសហប្រតិបត្តិការនោះ អាចនាំប្រទេសចិនទៅរកទំនើបភាវូបនីយកម្មដែលជាជំហានដ៏ចាំបាច់ឆ្ពោះទៅអភិវឌ្ឍប្រទេសជាតិរបស់គេឲ្យរីកចំរើនផង ។ លោក តេង ស៊ាវពីង[63] ដែលបានគេចខ្លួនរួចផុតយ៉ាងអស្ចារ្យពីការសម្លាប់ នាសម័យបដិវត្តន៍វប្បធម៌ ជាស្ថាបត្យករនៃទំនើបភាវូបនីយកម្មនេះ ។ មេដឹកនាំចិនរូបនេះ បានបញ្ចេញពាក្យសុភាសិតរបស់គាត់ថា "ឆ្មាសម្បុរអ្វីក៏បានដែរ ឲ្យតែវាចាប់កណ្តុរ" ។ ទំនើបភាវូបនីយកម្មបួនយ៉ាងរបស់ប្រទេសចិននោះគឺ៖ ទំនើបភាវូបនីយកម្មនៃកសិកម្ម ទំនើបភាវូបនីយកម្មនៃឧស្សាហកម្ម ទំនើបភាវូបនីយកម្មនៃបច្ចេកវិជ្ជា និង ទំនើបភាវូបនីយកម្មនៃផ្នែកការពារប្រទេស ។ នយោបាយទំនើបភាវូបនីយកម្មទាំងបួនយ៉ាងនេះ បានដើរស្របគ្នាជាមួយទ្រឹស្តីរបស់ចិនដែលគេហៅថា "ទ្រឹស្តីលោកបី" ដែលនៅក្នុងនោះ ចិនចាត់ទុកសហរដ្ឋអាមេរិក និង សហភាពសូវៀតជាលោកទី១ ប្រទេសអភិវឌ្ឍនៃលោកខាងលិចដូចជា៖ បារាំង អង់គ្លេស អាល្លឺម៉ង់ អូស្ត្រាលី និង កាណាដាជាលោកទី២ ហើយចំណែកឯប្រទេសកំពុងលូតលាស់ឯទៀត ជាលោកទី៣ ឬ តតិយលោក ។ ដោយប្រើយុទ្ធវិធីឡោមព័ទ្ធស្រុកស្រែឲ្យជាប់អស់ ដើម្បីឈានទៅវាយយកទីក្រុង មេដឹកនាំចិន បានធ្វើការលួងលោមអន្ទង លោកទី២ និង លោកទី៣ ឲ្យរួមគ្នាទប់ទល់នឹងឥទ្ធិពលលោកទី១ ។ ក៏ប៉ុន្តែ នៅសម័យនោះ ចិនបានវិភាគឃើញថា ក្នុងលោកទី១ មានការខុសគ្នារវាងសហភាពសូវៀត និង សហរដ្ឋអាមេរិក ។ នៅសម័យនោះ ចិនសំគាល់ថាសហភាពសូវៀត ជាមហា

---

[63] ពីដំបូង គេហៅមេដឹកនាំចិនរូបនេះថា តេង ស៊ាវពីង (Teng Xiaoping) ក្រោយមកគេហៅថា ដេង ហ្សៀវពីង (Deng Xiaoping) ទៅវិញ។

អំណាចវាយលុកគេ (Offensive power) រីឯសហរដ្ឋអាមេរិកគ្រាន់តែជាមហាអំណាចរង់ចាំការពារខ្លួន (Defensive power) តែប៉ុណ្ណោះ ។ ដូច្នេះ សហការជាមួយសហរដ្ឋអាមេរិកមិនមានគ្រោះថ្នាក់ដល់ចិនទេ ។ ជាពិសេស ចាប់តាំងពីសហរដ្ឋអាមេរិក បានដកកងទ័ពចេញពីវៀតណាម ។ ដូច្នេះចិនមានផលប្រយោជន៍យ៉ាងខ្លាំងក្នុងការទាក់ទងអូសទាញឲ្យសហរដ្ឋអាមេរិក និង ប្រទេសលោកខាងលិចរាប់រកខ្លួន ដើម្បីទប់ទល់នឹងការវាតទីនិយមរបស់សហភាពសូវៀត ។

ចាប់តាំងពីប្រទេសឥណ្ឌូចិនកុម្មុយនីស្តទាំងបី (លាវ វៀតណាម កម្ពុជា) បានទទួលជ័យជំនះនៅឆ្នាំ ១៩៧៥ ចិនដែលធ្លាប់តែនិយាយថាទំនាក់ទំនងរវាងវៀតណាម និង ចិន[64] មានការជិតស្និទ្ធគ្នាដូចជាធ្មេញ និង បបូរមាត់ បានមើលឃើញថាវៀតណាមឈរនៅក្នុងជួរសហភាពសូវៀតទៅវិញ មិនឈរនៅខាងចិនឡើយ ។ អ្នកវិភាគនយោបាយនៅលោកខាងលិច បានអះអាងថាប្រទេសវៀតណាម ទោះបីជាបានទទួលជំនួយដ៏ច្រើនសន្ធឹកសន្ធាប់ និង កិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយចិនអស់ជាច្រើនឆ្នាំក៏ដោយ ក៏វៀតណាមនៅតែមិនទាន់អាចបំភ្លេចបាននូវអនុស្សាវរីយ៍ដ៏ជូរចត់ ស្តីពីការត្រួតត្រារបស់ចិនលើវៀតណាមអស់រយៈពេលមួយពាន់ឆ្នាំកន្លងមកនោះឡើយ ។ អ្នកវិភាគនយោបាយទាំងនោះអះអាងទៀតថានៅពេលដែលអ្នកដឹកនាំវៀតណាម ឡេ យន់ ទៅធ្វើទស្សនកិច្ចនៅប្រទេសចិន ក្នុងខែ កញ្ញា ១៩៧៥ លោក តេង ស៊ាវពីង បានអំពាវនាវម្តងរួចហើយឲ្យវៀតណាមដកខ្លួនថយចេញពីឥទ្ធិពលសូវៀត ។ គេបន្ថែមទៀតថា នៅពេលលោក ឡេ យន់ ធ្វើទស្សនកិច្ចនៅប្រទេសចិនម្តងទៀតក្នុងខែ វិច្ឆិកា ១៩៧៧ អ្នកដឹកនាំវៀតណាមរូបនេះ បានសង្កេតឃើញថានយោបាយទំនើបភាវូបនីយកម្មរបស់

[64] ចំណុចទាំងឡាយដែលខ្ញុំលើកមកសរសេរនេះ ជាការវិភាគនយោបាយចេញផ្សាយតាមសារព័ត៌មាន លោកខាងលិចដែលខ្ញុំបានអាន ។

ចិន មានភាពលំអៀង ឬ មានភាពអនុគ្រោះទៅលោកខាងលិច ។ ពេលនោះ លោក ឡេ យន់ បានឲ្យចិនដឹងថាក្រុងហាណូយ មិនទាន់ត្រៀមខ្លួនដកចេញពីឥទ្ធិពលសូវៀតនៅឡើយទេ ។ អ្នកវិភាគនយោបាយបានគូសបញ្ជាក់ថាអ្នកដឹកនាំវៀតណាមមានការមិនពេញចិត្ត ព្រោះថាចាប់តាំងពីឆ្នាំ ១៩៧៥ មក ចិនមិនដែលផ្តល់ជំនួយយោធាដល់វៀតណាមទេ ផ្ទុយទៅវិញ ចិនបានផ្តល់ជំនួយយោធាដល់ខ្មែរក្រហមយ៉ាងសន្ធឹកសន្ធាប់ ។ លើសពីនេះទៅទៀត នៅពេលដែលខ្មែរក្រហមមានជម្លោះទល់ដែនជាមួយវៀតណាមនៅខែ ធ្នូ ១៩៧៧ ចិនគាំទ្រខ្មែរក្រហមដោយស្រែកបន្ទរថាវៀតណាមជាអ្នកឈ្លានពានកម្ពុជា ។ ចិនគាំទ្រខ្មែរក្រហម និងសរសើរខ្មែរក្រហមចំពោះការខំប្រឹងប្រែងការពារបូរណភាពទឹកដីរបស់ខ្លួន ។

នៅថ្ងៃទី ៣០ ធ្នូ ១៩៧៧ ខ្មែរក្រហម បានប្រកាសកាត់ផ្តាច់ចំណងការទូតជាមួយវៀតណាមជាបណ្តោះអាសន្ន នៅពេលដែលមានការវាយប្រហារគ្នាយ៉ាងខ្លាំងក្លានៅតាមទល់ដែន ។ ខ្មែរក្រហមបានចោទវៀតណាមថា ប៉ុនប៉ងបង្កើតគណបក្សកុម្មុយនីស្តថ្មីមួយក្នុងចំណោមជនក្បត់បក្ស ។ នៅក្នុងបទសម្ភាសន៍ជាមួយអ្នកសារព័ត៌មានយូហ្គោស្លាវីនៅភ្នំពេញ នាយករដ្ឋមន្ត្រីខ្មែរក្រហម ប៉ុល ពត បានឲ្យដឹងថា វៀតណាមមានបំណងដាក់បញ្ចូលប្រទេសកម្ពុជាទៅក្នុងសហព័ន្ធឥណ្ឌូចិន[65] ដែលនៅក្នុងនោះ ជនជាតិវៀតណាមរាប់លាននាក់អាចមករស់នៅក្នុងទឹកដីខ្មែរ ។ ប៉ុល ពត យល់ឃើញថា តែនៅក្នុងរយៈពេលសាមសិបឆ្នាំតែប៉ុណ្ណោះ ប្រជាពលរដ្ឋខ្មែរអាចនឹងក្លាយទៅជាជនជាតិភាគតិច ។ ជាធម្មតា ប្រទេសវៀតណាមបានបដិសេធនូវពាក្យចោទប្រកាន់នោះ ហើយបានបកស្រាយថាក្រុមខ្មែរក្រហមកំពុងបង្កើតបញ្ហាផ្ទៃក្នុងដោយខ្លួនឯង ។

[65] Nayan Chanda, Vietnam Prepares for a Long War, Far Eastern Economic Review, April 21, 1978, pp.17-22.

អ្នកជំនាញខាងកុម្មុយនីស្តឥណ្ឌូចិនបានបកស្រាយថាគណបក្សកុម្មុយនីស្តខ្មែរមានពីរខ្សែ[66] ។ ខ្សែទី១ ជាអ្នកជិតស្និទ្ធជាមួយវៀតណាម និង គាំទ្រណោសិរ្សរួមប្រឆាំងប្រក្រពត្តិនិយម ។ ខ្សែនេះប្រកាន់គោលជំហរសាមគ្គីបដិវត្តន៍ ខ្មែរ លាវ និង វៀតណាម ។ ខ្សែទី២គឺ ជាក្រុមដែលចាត់ទុកសម្តេច សីហនុ ថាជាសក្តិភូមិ គឺជាមុខសញ្ញាដែលត្រូវតែកំទេច រួមទាំងការទម្លាក់ពីអំណាចផង ។ ពួកនេះប្រកាន់គោលនយោបាយរបស់បក្សកុម្មុយនីស្តមួយដែលគេថា ឯករាជ្យ មិនចំណុះបក្សខាងក្រៅ ជាពិសេស បក្សវៀតណាម ។ វៀតណាមបានគាំទ្រខ្សែទី១ តាំងពីដើមរៀងមក ។ អ្នកជំនាញខាងកុម្មុយនីស្តឥណ្ឌូចិនបានអះអាងថា អ្នកដឹកនាំវៀតណាមតែងរំលឹកថា នៅពេលដែលខ្មែរក្រហមនៅទន់ខ្សោយនៅឡើយ ពួកខ្មែរក្រហម បានសុំឲ្យវៀតណាមធ្វើសង្គ្រាមជំនួសខ្លួន វៀតណាមក៏ធ្វើតាម ។ បន្ទាប់ពីវៀតណាម បានកំទេចប្រតិបត្តិការយោធារបស់ លន់ នល់ ឈ្មោះ ចេនឡាទី២ ពួកខ្មែរក្រហម ក៏សុំឲ្យវៀតណាមដកខ្លួនថយចេញ វៀតណាមក៏ព្រមធ្វើតាម ។ ក៏ប៉ុន្តែ ប៉ុល ពត មិនដែលទទួលស្គាល់ថា វៀតណាមបានជួយខ្លួននៅគ្រាដំបូងនៃសង្គ្រាមប្រឆាំង លន់ នល់ នោះឡើយ ។ ដូច្នេះទីក្រុងហាណូយ ក៏ខឹងសម្បារយ៉ាងខ្លាំងចំពោះ ប៉ុល ពត ព្រោះអ្នកដឹកនាំវៀតណាមយល់ថា ខ្មែរក្រហមរមិលគុណ ។ អ្នកជំនាញបានមើលឃើញថា អ្នកដឹកនាំវៀតណាមចង់ឲ្យមានទំនាក់ទំនងពិសេសរវាងវៀតណាម និង កម្ពុជា ដូចរវាង វៀតណាម និង លាវ ដែរ បំណាច់បានជួយខ្មែរក្រហមឲ្យបានជោគជ័យជាស្ថាពរ លើកងទ័ពសាធារណរដ្ឋ លន់ នល់ ។ អ្នកជំនាញទាំងនោះបានធ្វើវិភាគថា យោងតាមបទពិសោធន៍ពីមុនមក ពួកខ្មែរតែងមានការព្រួយបារម្ភខ្លាចក្រែងវៀតណាម ដែលមានប្រជាពលរដ្ឋរហូតដល់៧០លាននាក់នោះ អាចហៀរចូលមកលើទឹកដីខ្មែរ ។ អ្នកដឹកនាំជាតិនិយមខ្មែរភាគច្រើន

[66] Asiaweek, Where does it leave Sihanouk, April 21, 1978 p.15.

ធ្លាប់រំលឹកថា ទឹកដីវៀតណាមខាងត្បូងបច្ចុប្បន្នធ្លាប់ជាទឹកដីខ្មែរ ។ ទឹកដីនេះបានត្រូវបាត់បង់ទៅ ដោយសារតែការហូរចូលមកក្នុងទឹកដីខ្មែរនៃពួកអន្តោប្រវេសន៍វៀតណាម ។ តាមពិតទៅ គណបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលរួមមានវៀតណាម ខ្មែរ និង លាវកុម្មុយនីស្ត ធ្លាប់បានចេញសេចក្ដីថ្លែងការណ៍បង្កើតសហព័ន្ធនៃប្រទេសទាំងបី បន្ទាប់ពីបានរំដោះចេញពីអំណាចត្រួតត្រារបស់បារាំង ។ ក៏ប៉ុន្តែចាប់តាំងពីរំលាយគណបក្សកុម្មុយនីស្តឥណ្ឌូចិននៅឆ្នាំ ១៩៥១ មក គំនិតបង្កើតសហព័ន្ធនេះក៏ត្រូវបានបោះបង់ចោលទៅ ។ ពួកអ្នកវិភាគអះអាងថា ដោយឈរលើមូលដ្ឋានយុទ្ធមិត្ត យុទ្ធសាមគ្គី អ្នកដឹកនាំវៀតណាមទទូចឲ្យមានទំនាក់ទំនងពិសេសជាមួយលាវ និង កម្ពុជា ។ ពួកអ្នកវិភាគរៀបរាប់ថា ក៏ប៉ុន្តែពួកខ្មែរក្រហមឆ្លើយតបទៅវៀតណាមវិញថា ពួកគេមិនចង់បានទំនាក់ទំនងពិសេសអ្វីទេ ទំនាក់ទំនងធម្មតាគ្រប់គ្រាន់ណាស់ទៅហើយ ។

បើនិយាយតាមអ្នកវិភាគបញ្ហាបក្សកុម្មុយនីស្តឥណ្ឌូចិនដែលថា បក្សកុម្មុយនីស្តខ្មែរមានពីរខ្សែនោះ បក្សរបស់ ប៉ុល ពត គឺ ប្រាកដជាមិនមែនខ្សែទី១ ដែលមានទំនាក់ទំនងល្អជាមួយវៀតណាមនោះឡើយ ។ ប៉ុល ពត ស្អប់ខ្ពើមណាស់ចំពោះយុទ្ធមិត្តរបស់គាត់ដែលធ្លាប់រៀនសូត្រនៅហាណូយ ។ គួរកត់សំគាល់ដែរថា ក្រុមកុម្មុយនីស្តខ្សែទី១នេះ ក៏ធ្លាប់ផ្ដល់ការគាំទ្រជាយុទ្ធវិធី ឬ កលយុទ្ធ ដល់សម្ដេច សីហនុ ដោយសារនយោបាយអព្យាក្រឹតភាពរបស់ព្រះអង្គ ។ ផ្ទុយទៅវិញ ក្រុមខ្សែទី២ដែលមាន ប៉ុល ពត នៅក្នុងនោះ បានបង្ហាញឲ្យឃើញនូវនយោបាយជាតិនិយមមួយ ដើម្បីបក្សកុម្មុយនីស្តខ្មែរឯករាជ្យពីវៀតណាម និង មានគោលនយោបាយប្រឆាំងនឹងរបបសម្ដេច សីហនុ ផង ។ អ្នកបដិវត្តន៍កុម្មុយនីស្តរាប់ពាន់នាក់ ដែលធ្លាប់សិក្សារៀនសូត្រ និង ស្នាក់នៅក្នុងប្រទេសវៀតណាមខាងជើង តាំងពីឆ្នាំ ១៩៥៤ ត្រូវបានអ្នកវិភាគវាយតម្លៃថា ជាក្រុមខ្សែទី១ ដែលមានគោលជំហរ

សម្រុះសម្រួល និង សហការជាមួយសម្តេច សីហនុ ។ បន្ទាប់ពីព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ ភ្លាម អ្នកទាំងនោះបានចូលរួមយ៉ាងសកម្ម ក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសម្តេច សីហនុ ជាប្រធាន ។ ចាប់ពីឆ្នាំ ១៩៧១ មក អ្នកបដិវត្តទាំងនោះ បានចាប់ផ្តើមវិលត្រឡប់មកកម្ពុជាវិញ ។ ភ្លាមៗនោះ ប៉ុល ពត បានធ្វើការព្រមានដល់អ្នកបិដវត្តទាំងនោះថា ពួកគេត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈឹមបក្សគឺ នៅក្រោមបញ្ជាផ្ទាល់របស់ ប៉ុល ពត ហើយមិនត្រូវមកបង្គាប់បញ្ជា ប៉ុល ពត ឡើយ ។ ដូច្នេះ ពួកអ្នកបដិវត្តទាំងនោះបានត្រូវ ប៉ុល ពត ចាត់ទុកជាមុខសញ្ញា ដែលត្រូវកំទេចតាមនយោបាយសម្រឹតសម្រាំងបក្សជាបន្តបន្ទាប់ ។ ដោយសារការកាប់សម្លាប់ជាទូទៅដែល ប៉ុល ពត យកមកអនុវត្ត ដើម្បីក្តាប់អំណាចរបស់ខ្លួន រួមទាំងការកាប់សម្លាប់កម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តខ្មែរផង ចលនាប្រឆាំងផ្ទៃក្នុងក៏លេចចេញឡើងជារូបរៀង និង ទ្រង់ទ្រាយផ្សេងៗ តូចក៏មាន ធំក៏មាន តែភាគច្រើនជាការតស៊ូសម្ងាត់ ។

## ចលនាតស៊ូផ្ទៃក្នុងប្រឆាំង ប៉ុល ពត

តាំងពីចុងឆ្នាំ ១៩៧៤[67] ក្រុមអ្នកតស៊ូមួយ នៅខេត្តកោះកុងដែលដឹកនាំដោយលោក សាយ ភូថង លោក ទៀ បាញ់ និង លោក វ៉ុង ផ្លាមកែសន ព្រមទាំងកងទ័ពប្រមាណ ២ កងវរសេនាតូច និង ប្រជាពលរដ្ឋមួយចំនួនផង បានផ្តាច់ខ្លួនពីពួក ប៉ុល ពត ចូលទៅរស់នៅក្នុងប្រទេសថៃ ។ ចំណែកនៅឯភូមិភាគ

[67] ក្រុមស្រាវជ្រាវ ឆយ យីហ៊ាង ប្រែង ពីសិដ្ឋ លេង ណៃគីម ម៉ិល វាសនា ភិន ណារ៉ុង ម៉ម សារិត ជា មុនីឫទ្ធិ គិន ភា៖ ក្នុងសៀវភៅ ក្រោមចំណងជើង "សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, នាយករដ្ឋមន្ត្រីប្រសូតចេញពីត្រកូលកសិករ", រោងពុម្ព ពន្លឺពេជ្រ, ភ្នំពេញ ២០០៧ ទំព័រ ៧៩ ។

ឿសាន ក្នុងខេត្តរតនគីរី ចាប់តាំងពីចុងឆ្នាំ ១៩៧៥[68] ក៏មានចលនាប្រឆាំង ប៉ុល ពត ដែរដែលមានលោក ប៊ុន មី លោក ប៊ូ ថង និង លោក ស៊ើយ កែវ ជាអ្នកដឹកនាំនៅក្នុងតំបន់មួយ ដែលមានប្រជាពលរដ្ឋមួយចំនួន និង កងកម្លាំងប្រមាណ ២ កងវរសេនាតូចផង ។ ចលនាប្រឆាំងទាំងនោះ បានធ្វើឲ្យ ប៉ុល ពត រឹតតែចងកំហឹង និង បង្កើនការបោសសំអាតផ្ទៃក្នុងកាន់តែសាហាវឡើងៗ និង ក្នុងទ្រង់ទ្រាយកាន់តែធំ ។ ជាមួយគ្នានោះ ការប៉ះទង្គិចខាងផ្លូវអាវុធជាមួយវៀតណាម ក៏កាន់តែញឹកញាប់ឡើង ។

ក្នុងចំណោមការតស៊ូរើបំរះចេញពីរបប ប៉ុល ពត ប្រវត្តិតស៊ូរបស់ប្រធានសេនាធិការកងវរសេនាធំមួយរូប ដែលនៅកំពុងស្ថិតក្នុងភាពយុវវ័យនៅឡើយ នៅសម័យនោះ បានបង្ហាញនូវការប្តេជ្ញាចិត្តដ៏មុះមត់ និង សេចក្តីក្លាហានដ៏រឹងមាំអស្ចារ្យកម្រមាន នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា រហូតដល់សម្រេចជោគជ័យផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត បានទាំងស្រុង ។ ប្រវត្តិតស៊ូនោះគឺ ជាប្រវត្តិរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បច្ចុប្បន្នជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ជាអ្នកដឹកនាំខ្មែរជំនាន់ក្រោយមួយរូបចេញពីត្រកូលកសិករ ដែលគូបដិបក្ខខាងនយោបាយស្ទើរទាំងអស់ វាយតម្លៃខុសខាងសមត្ថភាពការងារដឹកនាំ ។

## ហ៊ុន សែន ចេញប្រឆាំង ប៉ុល ពត

ក្រោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ យុវជន ហ៊ុន ប៊ុនណាល់ កាលនោះមានអាយុ ១៨ ឆ្នាំ បានស្ម័គ្រចិត្តចូលរួមក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ដែលមាន

[68] ដូចយោងខាងលើ ។

សម្តេច នរោត្តម សីហនុ ជាប្រធានតាមសេចក្តីអំពាវនាវរបស់ព្រះអង្គផ្សាយតាមវិទ្យុប៉េកាំង ឲ្យប្រជារាស្ត្ររត់ចូលព្រៃម៉ាគី ក្រោកឡើងកាន់អាវុធប្រឆាំងពួកលន់ នល់-សិរិមតៈ ដែលបានធ្វើរដ្ឋប្រហារទម្លាក់សម្តេចពីតំណែងព្រះប្រមុខរដ្ឋ ។ នៅពេលចូលរួមចលនាតស៊ូនោះ យុវជននេះបានប្តូរឈ្មោះជា ហ៊ុន សំរេច ហើយត្រូវបានចាត់ឲ្យចូលទៅហ្វឹកហាត់ ធ្វើជាយុទ្ធជននៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា[69] ។

ពីរសប្តាហ៍ក្រោយមកយុវជន ហ៊ុន សំរេច បានទទួលមុខនាទីជាមេបញ្ជាការកងអនុសេនាតូច ដែលមានទាហាន ៣៦ នាក់នៅក្រោមបញ្ជា ។ តាមរយៈថ្វីដៃដឹកនាំ និង ជោគជ័យជាបន្តបន្ទាប់នៅលើសមរភូមិប្រយុទ្ធនៅចុងឆ្នាំ ១៩៧៤ នាយទាហានដ៏ក្មេងនេះ បានត្រូវតម្លើងតួនាទីជាមេបញ្ជាការកងវរសេនាតូច បញ្ជាលើយុទ្ធជន ៥០០ នាក់ ។ គឺនៅក្នុងតួនាទីថ្មីនេះហើយ ដែលមេបញ្ជាការរូបនេះបានប្តូរឈ្មោះជាថ្មីម្តងទៀតពី ហ៊ុន សំរេច មកជា ហ៊ុន សែន រហូតមក ។ មួយថ្ងៃមុនកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា រំដោះទីក្រុងភ្នំពេញពីរបបសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ គឺ នៅព្រឹកថ្ងៃទី ១៦ មេសា ១៩៧៥ យុវមេបញ្ជាការ ហ៊ុន សែន បានទទួលរងរបួសភ្នែកខាងឆ្វេង នៅលើសមរភូមិខេត្តកំពង់ចាមហើយត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ ។ ក្នុងរយៈពេលចូលរួមក្នុងជួររណសិរ្សរួបរួមជាតិកម្ពុជា លោក ហ៊ុន សែន បានសង្កេតឃើញជាតុពិតនៃរណសិរ្សនេះ ដែលមិនមែនដឹកនាំដោយសម្តេច នរោត្តម សីហនុ នោះទេ តែស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ខ្មែរក្រហម ។ ជាមួយគ្នានេះ នយោបាយកាប់សម្លាប់ និង អំពើ

---

[69] នេះជាឈ្មោះផ្លូវការ នៅសម័យនោះ របស់កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសម្តេច នរោត្តម សីហនុ ជាប្រធាន (Forces Armées Populaires de Libération Nationale du Kampuchea) ក្រោយ មកមានឈ្មោះជាកងទ័ពបដិវត្តកម្ពុជា ។

រំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងររបស់ខ្មែរក្រហម មកលើប្រជាពលរដ្ឋខ្មែរដ៏ស្លូតត្រង់ បានធ្វើឲ្យលោកមេបញ្ជាការ ហ៊ុន សែន ចងកំហឹងយ៉ាងខ្លាំង និង មានគំនិតរើបំរះចេញពីរបបព្រៃផ្សៃប្រល័យជាតិឯងនោះ ។ នៅខែ សីហា ឆ្នាំ ១៩៧៥ លោក ហ៊ុន សែន ត្រូវបានតម្លើងតួនាទីជាប្រធានសេនាធិការនៃកងវរសេនាធំ ដែលឈរជើងនៅស្រុកមេមត់ ខេត្តកំពង់ចាម ក្នុងតំបន់ ២១ នៃភូមិភាគបូព៌ា និង ដែលមានទាហានក្រោមបញ្ជាចំនួន ២០០០ នាក់ ។ តួនាទីថ្មីនៅក្នុងជួរកងទ័ព រឹតតែផ្តល់មធ្យោបាយបន្ថែមគឺ កងកម្លាំងយោធាកាន់តែច្រើន បង្កើនលទ្ធភាពដល់លោក ហ៊ុន សែន ឲ្យធ្វើការតស៊ូប្រឆាំងរបបប្រល័យពូជសាសន៍ ប៉ុល ពត ។

ក្នុងសម័យនោះ ការគ្រប់គ្រងរបស់ខ្មែរក្រហមមានចែកជាៈ អង្គការមជ្ឈិម ដែលនៅក្រោមអំណាចផ្ទាល់របស់ ប៉ុល ពត និង ភូមិភាគមួយចំនួន ។ ភូមិភាគនីមួយៗចែកជាតំបន់ ឯតំបន់ចែកជាស្រុក ។ ក្នុងឆ្នាំ ១៩៧០-១៩៧៥ ភូមិភាគនីមួយៗសុទ្ធតែស្វយ័ត និង មានកងទ័ពផ្ទាល់របស់ខ្លួន ។ ចាប់ពីថ្ងៃជ័យជំនះ ១៧ មេសា ១៩៧៥ មក មជ្ឈិមបង្កើនការសម្រឹតសម្រាំងកម្មាភិបាលក្នុងជួរគណបក្សកុម្មុយនីស្តកម្ពុជា និង ប្រើអំណាចទៅក្តាប់ឲ្យណែននូវការគ្រប់គ្រងភូមិភាគទាំងអស់ ។ ប៉ុល ពត មានការចាំបាច់ត្រូវធ្វើការបោសសំអាតកម្មាភិបាលភូមិភាគបូព៌ា ដែលភាគច្រើនធ្លាប់បានទៅសិក្សារៀនសូត្រ អស់រយៈពេលជាច្រើនឆ្នាំ នៅវៀតណាម ឬ ដែលមានទំនាក់ទំនងយ៉ាងល្អជាមួយទីក្រុងហាណូយ ។ ភូមិភាគបូព៌ាមានខេត្តមួយចំនួនជាប់ជាមួយប្រទេសវៀតណាមដូចជាខេត្ត ព្រៃវែង ស្វាយរៀង ទឹកដីខ្លះក្នុងខេត្តកំពង់ចាម និង ខេត្តកណ្តាល ព្រមទាំងមានលោក សោ ភឹម ដែលធ្លាប់ជាអ្នកតស៊ូប្រឆាំងអាណានិគមនិយមបារាំងក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ ជាលេខាបក្ស ។ ម្យ៉ាងទៀតចាប់តាំងពីពេលប្រកាសរដ្ឋធម្មនុញ្ញ[70] នៃកម្ពុជាប្រជាធិប

[70] របបកម្ពុជាប្រជាធិបតេយ្យបានអនុម័តរដ្ឋធម្មនុញ្ញថ្មីនេះនៅខែ មករា ១៩៧៦ ។

តេយ្យរបស់ខ្មែរក្រហមនៅខែ មេសា ១៩៧៦ មក លោក សោ ភឹម ក៏ទទួលមុខតំណែងជាអនុប្រធាននៃគណៈប្រធានរដ្ឋដែលមានលោក ខៀវ សំផន ជាប្រធាន។ នៅខែ មេសា ១៩៧៦ នោះដែរ ប្រធានកងពលធំម្នាក់នៃភូមិភាគបូព៌ាឈ្មោះ ចាន់ ចក្រី[71] បានត្រូវចោទប្រកាន់ថាប៉ុនប៉ងធ្វើរដ្ឋប្រហារ ។ ចាន់ ចក្រី ត្រូវបានចាប់ខ្លួននៅខែ ឧសភា ហើយដោយសារការវាយធ្វើទារុណកម្មសួរចម្លើយខ្លាំងពេក ចាន់ ចក្រី ក៏បង្ខំចិត្តឆ្លើយសារភាព ។ ក្នុងចម្លើយសារភាព ចាន់ ចក្រី ធ្វើឲ្យមានការពាក់ព័ន្ធដល់កម្មាភិបាលសំខាន់ៗមួយចំនួន និង ប្រទេសវៀតណាមផង ។ នៅឆ្នាំ ១៩៧៧ យុទ្ធមិត្តរបស់លោក ហ៊ុន សែន ប្រមាណ ៥០ នាក់ បានត្រូវចាប់ខ្លួនជាបន្តបន្ទាប់ ។

នៅពាក់កណ្តាលអធ្រាតថ្ងៃទី ២០ ឈានចូលទី ២១ មិថុនា ១៩៧៧ លោក ហ៊ុន សែន និង មនុស្សជំនឹតបួននាក់ទៀត បានសម្រេចចិត្តចេញដំណើរឆ្លងកាត់ព្រំដែន ចូលទៅក្នុងប្រទេសវៀតណាម ដើម្បីសុំជំនួយពីកងទ័ពប្រទេសជិតខាងនេះ ដែលកំពុងមានទំនាស់ជាមួយរបប ប៉ុល ពត ផងនោះ ឲ្យមកជួយរំដោះប្រជាពលរដ្ឋខ្មែរពីអំពើប្រល័យពូជសាន៍ ប៉ុល ពត ឲ្យទាន់ពេលវេលា ។ គួរបញ្ជាក់ថានៅសម័យនោះ ប្រទេសវៀតណាម ទោះបីជាកំពុងមានការប៉ះទង្គិចខាងផ្លូវយោធាដ៏ញឹកញាប់ជាមួយកម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ ក៏អាជ្ញាធរវៀតណាមនៅបន្តចាប់បញ្ជូនមកកម្ពុជាវិញនូវជនភៀសខ្លួនខ្មែរ ដែលលបលួចឆ្លងកាត់ទល់ដែនចូលក្នុងទឹកដីវៀតណាម លើកលែងតែជនភៀសខ្លួនណា ដែលបានចូលជ្រៅទៅដល់ទីរួមខេត្ត ឬ ទីក្រុងសំខាន់ៗ ដូចជាទីក្រុងព្រៃនគរជាដើម ទើបរួចខ្លួន ។ ដូច្នេះលោក ហ៊ុន សែន បានគិតក្នុងចិត្តជាស្រេចថា ប្រសិនបើវៀតណាមមិនជួយ ហើយបែរជាបញ្ជូនពួកលោកមកកម្ពុជាវិញនោះ លោកនឹងរកវិធីធ្វើអត្ត

[71] ចាន់ ចក្រី ក៏កាន់តំណែងជាលេខាបក្សតំបន់ ២៤ នៃភូមិភាគបូព៌ាដែរ យោងតាមឯកសារតុលាការ អ.ស.ប-កម្ពុជា ។

ឃាតសម្លាប់ខ្លួនឯងភ្លាមមិនឲ្យធ្លាក់ចូលក្នុងកណ្តាប់ដៃ ប៉ុល ពត វិញបានឡើយ ។ ជាមួយនិងក្តីបារម្ភខ្លាចក្រែងអាជ្ញាធរវៀតណាមចាប់បញ្ជូនមកឲ្យ ប៉ុល ពត ក៏មានគ្រោះថ្នាក់ដល់អាយុជីវិតមួយទៀតគឺ គ្រាប់មីនដែលបង្កប់ពាសពេញនៅតាមទល់ដែនខ្មែរ-វៀតណាម ដែលអាចបង្កក្តីអន្តរាយដោយមិនដឹងខ្លួននៅពេលឆ្លងកាត់ ។

នៅវេលាម៉ោង ២ ទៀបភ្លឺថ្ងៃទី ២១ មិថុនា ១៩៧៧ ក្រុមលោក ហ៊ុន សែន បានឆ្លងចូលទៅក្នុងទឹកដីវៀតណាមដោយសុវត្ថិភាព រួចក៏សម្រាកនៅទីនោះរង់ចាំដល់ពេលភ្លឺ ទើបបន្តដំណើរតទៅទៀត ។ ព្រឹកឡើង ក្រុមលោក ហ៊ុន សែន នាំគ្នាធ្វើដំណើរតាមផែនទី ឆ្ពោះទៅភូមិមួយឈ្មោះ ហលី ក្នុងស្រុក ឡុក និញ ។ ក្រុមអ្នកក្លាហានទាំងនោះ បានទៅដល់នៅម៉ោងប្រហែល ១៤ម៣០ នាទី ។ ជាទូទៅ វាសនារបស់ជនជាតិខ្មែរ ដែលឆ្លងដែនដោយខុសច្បាប់ ចូលទៅក្នុងទឹកដីប្រទេសជិតខាង មានមិនសូវខុសគ្នាឡើយ ។ ពួកគេត្រូវឃាត់ខ្លួន ចាប់សួរចម្លើយ និង ជាប់ឃុំឃាំងមួយរយៈពេល ទម្រាំអាជ្ញាធរនៃប្រទេសជិតខាងនោះធ្វើសេចក្តីសម្រេចជាចុងក្រោយ ទៅតាមករណីនីមួយៗ ។ នៅសម័យនោះ ជនរួមជាតិខ្មែរដែលឆ្លងចូលក្នុងទឹកដីថៃ ក៏ជួបប្រទះរឿងរ៉ាវបែបនេះ អ្នកដែលឆ្លងចូលក្នុងទឹកដីវៀតណាមក៏ជួបប្រទះរឿងរ៉ាវដូចគ្នាដែរ ។ កាលពេលនោះ អ្វីដែលខុសគ្នាគឺនៅប្រទេសថៃ អាជ្ញាធររបស់គេ មានអង្គការចាត់តាំងសម្ងាត់ចាំទទួលអ្នកស្ម័គ្រចិត្តឲ្យចូលទៅបំរើចលនាប្រឆាំង ប៉ុល ពត នៅពេលដែលរដ្ឋាភិបាលថៃ មិនមានលទ្ធភាពចេញមុខវាយប្រហារក្នុងទ្រង់ទ្រាយធំ ដើម្បីផ្តួលរំលំរបបខ្មែរក្រហមសោះនោះ ។ ចំណែកនៅឯប្រទេសវៀតណាម ពេលវេលាហាក់ដូចជាមិនទាន់មកដល់ដើម្បីប្រទេសនេះចេញមុខជួយផ្តួលរំលំរបប ប៉ុល ពត នៅឡើយទេ ។ គេត្រូវរង់ចាំដល់ដំណាច់ឆ្នាំ ១៩៧៧ នៅពេលដែលអ្នកដឹកនាំខ្មែរក្រហមប្រកាសជាសធារណៈថា ពួកគេកំពុងធ្វើសង្គ្រាមប្រឆាំងវៀតណាមឈ្លានពាន និង ប្រកាសផ្តាច់ចំណង

ការទូតរវាងប្រទេសទាំងពីរ ។ ដូច្នេះ ករណីក្រុមលោក ហ៊ុន សែន ក៏ស្ថិតនៅក្នុងបរិបទនៃទំនាក់ទំនងរវាងវៀតណាម និង កម្ពុជាប្រជាធិបតេយ្យនាសម័យនោះ ។ ក្រុមរបស់លោកត្រូវបានអាជ្ញាធរវៀតណាម សង្ស័យថាជាពួកទាហានស៊ើបការណ៍ឲ្យ ប៉ុល ពត ដូច្នេះត្រូវសួរចម្លើយ សួរហើយសួរទៀត ពីកន្លែងមួយទៅកន្លែងមួយ ពីទីស្នាក់ការភូមិហាលី ទៅមន្ទីរឃុំឃាំងស្រុកឡុកនិញ រហូតទៅជាប់ក្នុងមន្ទីរឃុំឃាំងយោធាខេត្តសុងបៃ អស់រយៈពេល ២២ ថ្ងៃ ។ ដោយសារចម្លើយដដែលៗ និង ការយល់ដឹងយ៉ាងច្បាស់លាស់អំពីបញ្ហា និង ភូមិសាស្ត្រយោធារបស់លោក ហ៊ុន សែន អាជ្ញាធរវៀតណាមក៏ចាប់ផ្តើមជឿថាលោកពិតជានាយទាហានជាន់ខ្ពស់ម្នាក់ ដែលកំពុងស្វែងរកជំនួយ ដើម្បីធ្វើការតស៊ូប្រឆាំងរបបប្រល័យពូជសាសន៍ ប៉ុល ពត មែន ។

នៅថ្ងៃទី ២៧ កញ្ញា ១៩៧៧ លោក ហ៊ុន សែន ត្រូវបានអនុញ្ញាតឲ្យជួបជាមួយនាយទាហានថ្នាក់ឧត្តមសេនីយនៃអគ្គសេនាធិការកងទ័ពវៀតណាម និង ជាសមាជិកការិយាល័យនៃគណបក្សកុម្មុយនីស្តមួយរូប ។ នៅក្នុងជំនួបនោះលោក ហ៊ុន សែន បានស្នើសុំឲ្យប្រទេសវៀតណាម ឈប់ចាប់បញ្ជូនជនភៀសខ្លួនដែលឆ្លងចូលមកក្នុងទឹកដីវៀតណាមទៅឲ្យ ប៉ុល ពត វិញ ព្រមទាំងផ្តល់សិទ្ធិជ្រកកោននយោបាយដល់កម្មាភិបាលខ្មែរក្រហមណា ដែលមានបំណងរត់ចេញពីរបបប្រល័យពូជសាសន៍ មករស់នៅក្នុងប្រទេសវៀតណាម ។ សំណើសុំទាំងពីរចំណុចនេះ ខាងអាជ្ញាធរវៀតណាមអាចផ្តល់បានភ្លាម ។ ជាមួយគ្នានោះ លោក ហ៊ុន សែន ក៏ទទូចសុំឲ្យវៀតណាមផ្តល់ជំរកសុវត្ថិភាព និង ជំនួយយោធា ជាពិសេស អាវុធ និង ស្បៀងដល់ចលនាតស៊ូ ឬ ដល់កងកម្លាំងថ្មី ដែលត្រូវកសាងដើម្បីវាយរំដោះប្រជាពលរដ្ឋខ្មែរពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ។ តាមពិតទៅគឺ ចំណុចចុងក្រោយទាំងនេះទេ ដែលលោក ហ៊ុន សែន ប្រាថ្នាចង់បានជាងគេ

ព្រោះជាគោលបំណងចម្បងនៃការភៀសខ្លួនរបស់ពួកលោក នៅក្នុងទឹកដីវៀតណាមនាពេលនោះ ។ ក៏ប៉ុន្តែប្រទេសវៀតណាមបដិសេធ ព្រោះគេជៀសវាងការចោទប្រកាន់ពីបទជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ។ ជំហរបែបនេះ ធ្វើឲ្យលោក ហ៊ុន សែន មានការសោកស្តាយជាខ្លាំង ។

នៅក្នុងឆ្នាំ ១៩៧៧ កងទ័ពវៀតណាម និង កងទ័ពខ្មែរក្រហមមានការប៉ះទង្គិចគ្នារឹតតែញឹកញាប់ និង ទ្រង់ទ្រាយធំ ជាពិសេស នៅខែ មេសា គឺ នៅពេលដែលកងទ័ពខ្មែរក្រហម ធ្វើការវាយប្រហារយ៉ាងព្រហើន លើទីប្រជុំជនវៀតណាម នៅ ទិញបៀន និង ភូមិមួយចំនួន នៅក្នុងខេត្តអានយ៉ាង តាមដងទន្លេមេគង្គ ដែលធ្វើឲ្យជនស៊ីវិលស្លាប់អស់ជាច្រើននាក់ ។ វៀតណាមធ្វើការវាយតបវិញរួមទាំងការទំលាក់គ្រាប់បែកតាមយន្តហោះផង ជាមួយនិងការព្យាយាមចរចាដែរ តែពុំបានសំរេច ។ នៅថ្ងៃទី ២៤ កញ្ញា ១៩៧៧ ពួកខ្មែរក្រហមបើកការវាយប្រហារទ្រង់ទ្រាយធំជាលើកទី២ នៅតៃនិញ ដោយធ្វើឲ្យជនស៊ីវិលបាត់បង់ជីវិតអស់ច្រើនរយនាក់។ នៅក្នុងខែ តុលា និង វិច្ឆិកា កងទ័ពវៀតណាម បានវាយប្រហារតបវិញយ៉ាងខ្លាំងនៅខេត្តស្វាយរៀង ។ នៅខែ ធ្នូ កងទ័ពនេះបន្តវាយក្នុងទ្រង់ទ្រាយធំ តាមទល់ដែន នៅខេត្តកំពង់ចាម ក្រចេះ និង តាកែវ ដែលធ្វើឲ្យកងទ័ពខ្មែរក្រហមទទួលបរាជ័យជាដំណំ ។ ក្នុងការវាយបកវិញនោះ កងទ័ពវៀតណាមបានចូលមកកាន់កាប់ស្រុកស្នួលនៃខេត្តក្រចេះ ស្រុកទ្រមូង[72] ស្រុកពញាក្រែក ស្រុកត្បូងឃ្មុំ ស្រុកមេមត់នៃខេត្តកំពង់ចាម ។ ឆ្លៀតក្នុងពេលនោះ លោក ហ៊ុន សែន ក៏បានចូលមកពិនិត្យសភាពការណ៍ផ្ទាល់នៅលើទឹកដីខ្មែរ ។ ក៏ប៉ុន្តែ លោក ហ៊ុន សែន មានការខកចិត្តជាខ្លាំង ដោយកងទ័ពវៀតណាមនោះ ដកថយទៅវិញមិនទុកឱកាសឲ្យចលនាប្រឆាំងខ្មែរក្រហមមានទីជម្រកសុវត្ថិភាព ដើម្បីកសាងកម្លាំង

[72] បច្ចុប្បន្ន ស្រុកទ្រមូង ត្រូវបានបញ្ចូលក្នុងស្រុកមេមត់ ។

ឬ ទុកជាតំបន់រំដោះរបស់ពួកគេឡើយ ។ ជាមួយនោះ យុវមេបញ្ជាការយោធារូបនេះក៏មានអំណរខ្លះដែរ ដោយកងទ័ពវៀតណាមយល់ព្រមអនុញ្ញាតឲ្យប្រជាពលរដ្ឋខ្មែរ ដែលរត់ចូលទឹកដីវៀតណាម អាចរស់នៅលើទឹកដីរបស់ប្រទេសគេបាន ។

## ខ្មែរក្រហមផ្តាច់ទំនាក់ទំនងការទូត

នៅថ្ងៃទី ៣១ ធ្នូ ១៩៧៧ លោក ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ បរិហារការឈ្លានពានរបស់វៀតណាមជាសាធារណៈ រីឯលោក អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរក្រហមក៏បានចេញសេចក្តីប្រកាសកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាម ។ ជម្លោះរវាងរបបខ្មែរក្រហម ប៉ុល ពត ជាមួយប្រទេសវៀតណាម បានឈានដល់ដំណាក់កាលថ្មីតម្រូវឲ្យវៀតណាមប្រកាន់យកនយោបាយគាំទ្រដោយចំហរ ដល់ចលនាតស៊ូខ្មែរប្រឆាំងរបបប្រល័យយពូជសាសន៍យ៉ាងដាច់ខាត ។

បើតាមបណ្តាញសារព័ត៌មានលោកខាងលិច ដែលចេញផ្សាយនាសម័យនោះថា នៅខែ មករា ១៩៧៨ កងទ័ពវៀតណាមវាយដេញទ័ពខ្មែរក្រហមចូលមកក្នុងទឹកដីខ្មែរប្រមាណចម្ងាយ ៣០-៤០ គីឡូម៉ែត្រ ។ ជនភៀសខ្លួនខ្មែរដែលបានទៅដល់ជំរុំបេនសាំង នៃខេត្តតៃនិញ នៅពេលដដែលនោះ និយាយថាមានជនជាតិខ្មែរប្រមាណមួយម៉ឺននាក់ បានរត់ឆ្លងកាត់ទល់ដែនចូលទៅក្នុងប្រទេសវៀតណាម ។ នៅក្នុងជំរុំនោះ មានការប្រជុំនយោបាយ រៀបចំដោយសមាជិកនៃគណបក្សកុម្មុយនីស្តខ្មែរ ដែលបណ្តុះបណ្តាលដោយក្រុងហាណូយ ។ បញ្ហាដូចជាការ

ស្ម័គ្រចិត្តត្រឡប់ចូលទៅកម្ពុជាវិញ ដើម្បីវាយប្រហាររបប ប៉ុល ពត ដើម្បីសងសឹកចំពោះការកាប់សម្លាប់ឪពុក ម្តាយ បង ប្អូន កូន ចៅខ្លួន ឬ ធ្វើការផ្លាស់ប្តូររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ត្រូវបានលើកឡើងមកធ្វើការផ្លាស់ប្តូរមតិគ្នា ។ នៅក្នុងជំរុំនេះ ក៏មានធ្វើការអប់រំឡើងវិញដល់ទាហានខ្មែរក្រហម ដែលវៀតណាមចាប់បានដើម្បីឲ្យកែខ្លួនទៅជាពលរដ្ឋល្អវិញ និង ដើម្បីឲ្យយល់ដឹងពីជាតុពិតរបស់ ប៉ុល ពត និង ធ្វើខ្លួនឲ្យទៅជាកម្មាភិបាលម៉ាកឡេនីនពិតប្រាកដ ។

នៅខែ មករា នោះដែរ ប៉ុល ពត បង្កើនការបោសសំអាតនៅភូមិភាគបូព៌ា ។ ចំណែកនៅឯប្រទេសវៀតណាមវិញ លោក ហ៊ុន សែន បានជួបនាយទាហានជាន់ខ្ពស់ដែលជាមេបញ្ជាការយោធភូមិភាគទី៧ និង ជាតំណាងបក្ស និង រដ្ឋវៀតណាម ដែលនាំដំណឹងថារដ្ឋាភិបាលវៀតណាមបានអនុញ្ញាតឲ្យលោក ហ៊ុន សែន កសាងកម្លាំងទ័ព ដោយរើសក្នុងចំណោមជនភៀសខ្លួនខ្មែរ និង ដោយខាងភាគីវៀតណាមផ្តល់ជំនួយយោធាមានអាវុធ គ្រាប់រំសេវ ស្បៀង និង ការហ្វឹកហ្វឺន ព្រមទាំងជំនួយហិរញ្ញវត្ថុផង ដោយឡែកចំពោះបញ្ហានយោបាយ វៀតណាមសុំភាគីកម្ពុជាដោះស្រាយខ្លួនឯង ។ ដោយមានការគាំទ្រយ៉ាងរឹងមាំយ៉ាងនេះ លោក ហ៊ុន សែន ក៏ចាប់ទទួលកម្មាភិបាលខ្មែរក្រហមដែលរត់ចោលជួរ និង កសាងកម្លាំងជាបន្តបន្ទាប់ ។

នៅថ្ងៃ ១៤ មីនា ១៩៧៨ កងទ័ពខ្មែរក្រហម ប៉ុល ពត បានបើកការវាយប្រហារនៅខេត្តមាត់ជ្រូក ឬ ចូវដុក ធ្វើឲ្យជនស៊ីវិលវៀតណាមស្លាប់ និង របួសជាច្រើននាក់ ។ ជាមួយគ្នានោះវិទ្យុកម្ពុជាប្រជាធិបតេយ្យបានផ្សព្វផ្សាយនូវការប្តេជ្ញាចិត្តរបស់កម្មាភិបាលខ្មែរក្រហម ប៉ុល ពតក្នុងការកាប់សម្លាប់ផ្តាច់ពូជភ្នាក់ងារពួកវាតទីនិយម បរិវារ និង វៀតណាមឈ្លានពានឲ្យអស់ពីអង្គភាព និង ឲ្យអស់ពីទឹកដីកម្ពុជាជារៀងរហូត ។ ការបោសសំអាតនៅភូមិភាគបូព៌ាកាន់តែសាហាវឡើង ឯការរើបំរះផ្ទៃក្នុងក៏កាន់តែសកម្មដែរ ។ ចលនាបះបោរជាទូទៅ ក៏បានងើបឡើង

នៅក្នុងភូមិភាគបូព៌ាទាំងមូល ។ ក្រោយដែលលោក សោ ភឹម ទទួលមរណភាពទៅ ចលនាបះបោរប្រឆាំង ប៉ុល ពត នៅភូមិភាគបូព៌ានេះ ត្រូវបានដឹកនាំដោយលោក ហេង សំរិន និង លោក ជា ស៊ីម ។ នៅខែ មេសា ១៩៧៨ កងទ័ពវៀតណាមប្រមាណមួយសែននាក់ បានត្រូវរាយការណ៍ថាបានប្រមូលផ្តុំគ្នានៅតាមទល់ដែនវៀតណាម-កម្ពុជា ។ វៀតណាម បានអំពាវនាវឲ្យទាហានខ្មែរក្រហមក្រោកឡើងកាន់អាវុធ ប្រឆាំងនឹងមេខ្មែរក្រហមប្រល័យពូជសាសន៍វិញ ។ យុទ្ធសាស្ត្រថ្មីរបស់វៀតណាមបានផ្តល់ផ្លែផ្កាល្អណាស់ ដោយសារនៅផ្ទៃក្នុងរបបខ្មែរក្រហមមានការរពើតរពើងបះបោរយ៉ាងខ្លាំង ។

## រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា

នៅខែ វិច្ឆិកា ១៩៧៨ ប្រជាពលរដ្ឋខ្មែររាប់សែននាក់ បានរត់ទៅប្រទេសវៀតណាម ។ នៅខែ វិច្ឆិកា នោះដែរ កម្លាំងតស៊ូប្រឆាំង ប៉ុល ពត បានជួបជុំគ្នាដើម្បីពិភាក្សារៀបចំចាត់តាំងអង្គការនយោបាយ សម្រាប់ដឹកនាំការតស៊ូផ្តួលរំលំរបប ប៉ុល ពត ។ ក្រុមខ្មែរអ្នកតស៊ូ ៤ ក្រុម បានចូលរួមប្រជុំគឺៈ ១. ក្រុមមកពីកម្លាំងបះបោរនៅភូមិភាគបូព៌ា តំណាងដោយលោក ហេង សំរិន និង លោក ជា ស៊ីម ២. ក្រុមភូមិភាគឦសាន ដោយលោក ប៊ុន មី និង លោក ប៊ូ ថង ៣. កម្លាំងផ្តាច់ខ្លួនកសាងថ្មីដោយលោក ហ៊ុន សែន ៤. ក្រុមកម្មាភិបាលដែលស្នាក់នៅប្រទេសវៀតណាមតាំងពីសន្និសីទទីក្រុងហ្សឺណែវ ១៩៥៤ ដោយលោក ប៉ែន សុវណ្ណ លោក រស់ សម័យ និង លោក ម៉ុក សាគុណ ។ ឯក្រុមទី ៥ ដែលដឹកនាំដោយលោក សាយ ភូថង បានយល់ព្រមចូលរួមការតស៊ូ តែមិនទាន់ចេញមុខ ។

នៅពេលនោះ កម្លាំងថ្មីរបស់លោក ហ៊ុន សែន បានចាប់ផ្តើមពី១កងអនុសេនាធំ ហើយរីកធំធាត់យ៉ាងឆាប់រហ័ស រហូតដល់ ២៨ កងវរសេនាតូច ដែលមានកម្លាំងសរុបប្រមាណ ១០ ០០០ នាក់ ។ នៅថ្ងៃទី ២ ធ្នូ ១៩៧៨ អ្នកតស៊ូទាំង ៥ ក្រុម បានប្រកាសបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលមានលោក ហេង សំរិន ជាប្រធាន ។ នៅថ្ងៃទី ២៥ ធ្នូ ១៩៧៨ កងទ័ពវៀតណាមចំនួនមួយសែនប្រាំម៉ឺននាក់ និង កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលហៅតាមពាក្យសាមញ្ញថាកងទ័ព ហេង សំរិន ទាំងអស់ប្រមាណពីរម៉ឺននាក់ បានវាយប្រហារជាទ្រង់ទ្រាយធំសម្រុក ចូលមកក្នុងប្រទេសខ្មែរ ហើយដណ្តើមទីក្រុងភ្នំពេញ បានទាំងស្រុងនៅថ្ងៃទី ៧ មករា ១៩៧៩ ។ ប៉ុល ពត និង កងទ័ពពិសេសរបស់ខ្មែរក្រហមបានរត់រហូតទៅដល់ទល់ដែនថៃ ដែលនៅទីនោះពួកគេបានទទួលការគាំទ្រពីចិន និង ថៃ ឲ្យរៀបចំកងទ័ពសាជាថ្មីឡើងវិញ ដើម្បីបន្តសង្គ្រាមមួយតទៅទៀត ដែលគេហៅថា "សង្គ្រាមរំដោះជាតិ" ។ នៅថ្ងៃទី ៨ មករា ១៩៧៩ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយ ដែលហៅថាក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ដោយមានលោក ហេង សំរិន ជាប្រធាន លោក ប៉ែន សុវណ្ណ ជាអនុប្រធាន និង ជារដ្ឋមន្ត្រីក្រសួងការពារប្រទេស លោក ហ៊ុន សែន ជាសមាជិក និង រដ្ឋមន្ត្រីក្រសួងការបរទេស លោក ជា ស៊ីម ជាសមាជិក និង ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងសមាជិក ៥ រូបទៀត ដែលកាន់តំណែងជារដ្ឋមន្ត្រីសំខាន់ៗគឺ ក្រសួងឃោសនាការព័ត៌មាន និង វប្បធម៌ ក្រសួងសិក្សាធិការ ក្រសួងសង្គមកិច្ច សុខាភិបាល និង ក្រសួងសេដ្ឋកិច្ច និង ជីវភាព ។ នៅថ្ងៃទី ១១ មករា ១៩៧៩ ថ្នាក់ដឹកនាំរណសិរ្ស និង ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា បានមកដល់ទីក្រុងភ្នំពេញ ។

# ប៉ុល ពត ស្នើសុំឲ្យសម្ដេច សីហនុ ជួយ

គួររំលឹកអំពីតួនាទីរបស់សម្ដេច នរោត្តម សីហនុ ម្ដងវិញ ។ ក្រោយពីព្រះអង្គលាលែងតំណែងប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យនៅខែ មីនា ១៩៧៦[73]មក ខ្មែរក្រហមក៏បោះបង់ព្រះអង្គចោល ។ ពួកប៉ុល ពត បានវាយប្រហារជាសាធារណៈលើរបបសង្គមរាស្ត្រនិយមរបស់សម្ដេចថាជារបបសក្តិភូមិផ្ដាច់ការ ព្រមទាំងធ្វើការបោសសំអាតកាប់សម្លាប់អ្នកសីហនុនិយមស្ទើរទាំងអស់ទៀតផង ។ ក្រៅពីឃាត់ឃាំងព្រះអង្គ មិនឲ្យយាងចេញពីព្រះរាជដំណាក់ ពួកខ្មែរក្រហម ប៉ុល ពត បានសម្លាប់ព្រះរាជវង្សានុវង្ស ដែលមានរួមទាំងព្រះរាជបុត្រាបុត្រីផ្ទាល់ចំនួន ៥ ព្រះអង្គ និង ព្រះរាជនត្តាផ្ទាល់(ចៅ)ចំនួន ១៤ ព្រះអង្គផង[74] ។ នៅពេលដែលពួកខ្មែរក្រហមត្រូវការព្រះអង្គ ពួកគេយកចិត្តទុកដាក់ថ្វាយម្ហូបចំណីសមរម្យ តែនៅពេលមិនត្រូវការ ពួកគេក៏មិនរវីរវល់អ្វីទាំងអស់ ។ សម្ដេច នរោត្តម សីហនុ បានផ្សព្វផ្សាយតាមសៀវភៅដែលទ្រង់ព្រះរាជនិពន្ធក្នុងឆ្នាំ ១៩៨៦ ក្រោមចំណងជើង "អ្នកជាប់គុកខ្មែរក្រហម" ថាព្រះអង្គទ្រង់ជ្រាបអំពីជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យជាមួយវៀតណាម ដោយសារព្រះអង្គស្ដាប់ព័ត៌មានផ្សាយចេញពីវិទ្យុអន្តរជាតិដូចជា វិទ្យុអង់គ្លេស ប៊ីប៊ីស៊ី វិទ្យុបារាំង ហ្វ្រង់អាំងទែ វិទ្យុអូស្ត្រាលី ឬ វិទ្យុអាឡឺម៉ង់ជាដើម តាមវិទ្យុទទួលសម្លេងមួយគ្រឿងដែលលោក ខៀវ សំផន ថ្វាយព្រះអង្គ ។

---

73 តាំងពីខែ មករា ១៩៧៦ របបខ្មែរក្រហម ប៉ុល ពត បានអនុម័តរដ្ឋធម្មនុញ្ញថ្មី ដែលបង្កើតរដ្ឋកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែមិនទាន់ប្រកាសឲ្យប្រើ ។ ក្នុងនោះ មានតំណែងប្រធានគណៈប្រធានរដ្ឋជំនួស ដំណែងប្រមុខរដ្ឋ ។ សម្ដេច នរោត្តម សីហនុ បានដាក់ពាក្យលាលែងពីតំណែងប្រមុខរដ្ឋ នៅខែ មីនា និង ត្រូវបានជំនួសដោយលោក ខៀវ សំផន នៅខែ មេសា ១៩៧៦ នៅពេលដែលរដ្ឋធម្មនុញ្ញថ្មីចូលជាធរមាន ។

74 Norodom Sihanouk, Les Prisonniers des Khmers Rouges, Edition Cameron, 1986, p. 320.

នៅថ្ងៃទី ១ មករា ១៩៧៨ ក្រោយពីព្រះអង្គតើនពីផ្ទំ ដោយមានការយឺតយ៉ាវជាងធម្មតា ព្រោះតែព្រះអង្គសោយថ្នាំឲ្យផ្ទំលក់ពីល្ងាច និង បន្ទាប់ពីទ្រង់បានទទួលដំណឹងតាមវិទ្យុថា កម្ពុជាប្រជាធិបតេយ្យបានផ្តាច់ចំណងការទូតជាមួយប្រទេសវៀតណាម ព្រមទាំងបានរុញច្រានកងទ័ពឈ្លានពាននេះចេញពីទឹកដីកម្ពុជាផង សម្តេចទ្រង់ប្រញាប់ប្រញាល់សរសេរសំបុត្រមួយច្បាប់ ជូនអង្គការខ្មែរក្រហម[75] ដ៏ជាទីគោរព ដើម្បីថ្លែងការកោតសរសើរអំពីជោគជ័យរបស់កងទ័ពបដិវត្តកម្ពុជា និង ស្នើថា ព្រះអង្គត្រៀមព្រះកាយបំរើអង្គការ ប្រសិនបើមាតុប្រទេសត្រូវការ ។ ស្នែកឡើងអង្គការ បានផ្សាយតាមវិទ្យុនូវសារសសើររបស់សម្តេច ក៏ប៉ុន្តែមិនផ្សាយអំពីការស្នើគ្រព្រះទ័យបំរើអង្គការជាថ្មីរបស់ព្រះអង្គឡើយ ។ សម្តេចសីហនុ បានសង្កេតឃើញថា នៅចន្លោះថ្ងៃទី ១ មករា ១៩៧៨ និង ទី ១ ធ្នូ ១៩៧៨ ប្រទេសវៀតណាមតែងតែប្រកាសតាមវិទ្យុក្រុងហាណូយ និង វិទ្យុក្រុងហូជីមិញ សុំឲ្យធ្វើការដោះស្រាយជម្លោះតាមការចរចា ។ ជាចម្លើយតបវិញ វិទ្យុខ្មែរក្រហម ប៉ុល ពត ផ្សាយថាគ្មានអ្វីចរចានោះទេ ព្រោះវៀតណាមឈ្លានពាន និង លុកលុយកម្ពុជាប្រជាធិបតេយ្យដ៏ស្លូតត្រង់ និង ដែលស្នេហាសន្តិភាព ។ សម្តេចទ្រង់សង្កេតទៀតថា ជម្លោះកាន់តែធំធាត់កាលណា កាលនោះទូទឹកកករបស់ព្រះអង្គ ក៏កាន់តែសម្បូណ៌ទៅដោយម្ហូបចំណីល្អៗដែរ ដោយសារតែខ្មែរក្រហមកាន់តែយកចិត្តទុកដាក់ជាមួយព្រះអង្គខ្លាំងឡើងៗ ។

នៅពេលថ្ងៃលិចនាថ្ងៃទី ៥ មករា ១៩៧៩ លោកប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន បានមកយាងសម្តេច ពីព្រះដំណាក់នៅក្រោយវត្តបុទមវត្តី ទៅជួប ប៉ុល ពត នៅវិមានរដ្ឋាភិបាល ឯវត្តភ្នំដែលសព្វថ្ងៃបានក្លាយជាទីស្នាក់ការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ សម្តេចធ្លាប់បានជួប ប៉ុល ពត តែម្តងគត់គឺ នៅពេលព្រះ

[75] Norodom Sihanouk, Les Prisonniers des Khmers Rouges, op. cit., p. 248.

អង្គយាងមកធ្វើទស្សនកិច្ចនៅឆ្នាំ ១៩៧៣ នៅក្នុងតំបន់រំដោះ នាសម័យសង្គ្រាមប្រឆាំងរបប លន់ នល់ ។ តាំងពីពេលនោះមក ព្រះអង្គមិនដែលបានជួបមេដឹកនាំកំពូលនៃរបបប្រល័យពូជសាសន៍នេះទេ ។ ដូច្នេះ នេះជាជំនួបលើកទី២ ។ នៅពេលយាងទៅដល់ ប៉ុល ពត ដោយទឹកមុខញញឹម ឈរចាំព្រះអង្គជាស្រេច នៅមាត់ទ្វារធំ ដោយរួមជាមួយមានលោក អៀង សារី និង សម្តេច ប៉ែន នុត ដែលអញ្ជើញទៅដល់មុនព្រះអង្គ ។ ជាការគួរឲ្យភ្ញាក់ផ្អើលសម្រាប់ព្រះអង្គ ប៉ុល ពត មុននឹងអោបរឹបសម្តេចតាមទម្លាប់ ម្តងនេះគាត់លើកដៃសំពះ ដោយបន្ទុចជង្គង់បន្តិចជាការគោរពផង[76] ។ ដោយឡែកលោក អៀង សារី លើកដៃសំពះទាំងបង្ខំចិត្ត តែតាមលក្ខណៈឆ្មើងឆ្មៃរបស់គាត់ៗមិនបន្ទន់ខ្លួនបន្តិចណាឡើយចំពោះសម្តេច ដែលជាអតីតព្រះមហាក្សត្រខ្មែរ ។ ប៉ុល ពត ថ្វាយសម្តេចឲ្យគង់ខាងស្តាំដៃរបស់គាត់លើកៅអីពូកដ៏ក្រាស់ ដែលគេសម្រាប់ទទួលភ្ញៀវជាន់ខ្ពស់ថ្នាក់ប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល ។ យុវជនខ្មែរក្រហមក្នុងសំលៀកបំពាក់ដ៏សង្ហារ ញាប់ដៃញាប់ជើងបំរើទឹកតែ និង នំ ចំណីជាមួយនិងទឹកក្រូចពោធិសាត់ប្រចាប់ស្រស់ៗ ។ សម្តេចបានរៀបរាប់ក្នុងសៀវភៅនោះថា ដោយព្រះអង្គខានបានសោយជាយូរមកហើយ ទឹកក្រូចនេះមានឱជារសខ្លាំងណាស់ នាំឲ្យព្រះអង្គសោយហើយសោយទៀតអស់ជាងដប់កែវ ក្នុងរយៈពេលជាងបួនម៉ោងនៃកិច្ចសន្ទនាគ្នានោះ[77]។

តាមពិតទៅ ប៉ុល ពត ចង់ជួបសម្តេច ដើម្បីបញ្ជាក់ផ្ទាល់មាត់ថែមទៀតថា តើព្រះអង្គយល់ព្រមយាងចេញ ទៅការពារកម្ពុជាប្រជាធិបតេយ្យនៅអង្គការសហប្រជាជាតិ ដូចរបាយការណ៍របស់ លោក ខៀវ សំផន មែនឬទេ? នៅចំពោះមុខការវាយប្រហារដ៏ខ្លាំងក្លា និង ការរុលទៅមុខយ៉ាងឆាប់រហ័សនៃកងទ័ពវៀត

[76] Norodom Sihanouk, Les Prisonniers des Khmers Rouges, op.cit, p. 317.

[77] ដូចយោងខាងលើ ។

ណាម ។ បើតាមអ្វីដែល ប៉ុល ពត ទូលព្រះអង្គនោះ សម្តេចត្រូវយាងទៅ អ.ស.ប រួចត្រឡប់មកគង់នៅទីក្រុងប៉េកាំងវិញមិនលើសពីបីខែទេ ជារយៈពេលដែល ប៉ុល ពត ប៉ាន់ស្មានថាខ្មែរក្រហមអាចវាយបណ្តេញកងទ័ពវៀតណាម ឲ្យចេញអស់ពីទឹកដីខ្មែរបាន ។ ដូច្នេះទោះជានៅក្នុងភាពអាសន្នក៏ដោយ ក៏ ប៉ុល ពត នៅតែមានអំនួត និង នឹកថាទាហានរបស់ខ្លួន អាចទប់ទល់ជាមួយកងទ័ពវៀតណាមបាន ។ មែនទែន សម្តេច សីហនុ ក៏ទ្រង់សព្វព្រះទ័យចំពោះគំនឹតឲ្យព្រះអង្គយាងទៅ អ.ស.ប.នេះណាស់ដែរ ព្រោះនោះជាលទ្ធភាពអាចឲ្យព្រះអង្គស្វែងរកសេរីភាពជាថ្មីឡើងវិញបាន ។ ក្រោយពេលសម្តេចលាឈប់ពីដំណែងប្រមុខរដ្ឋនាឆ្នាំ ១៩៧៦ ព្រះអង្គធ្លាប់សុំចេញទៅប្រទេសចិន ដើម្បីព្យាបាលព្រះរោគ តែខ្មែរក្រហមមិនអនុញ្ញាត ។

នៅក្នុងជំនួបនោះ ប៉ុល ពត ទូលព្រះអង្គថា រសៀលថ្ងៃស្អែកនឹងមានយន្តហោះចិនមួយគ្រឿងមកដឹកសម្តេច អ្នកម្នាងម៉ូនិច ព្រះរាជបុត្រ និង ព្រះញាតិ ព្រមទាំងអ្នកហែរហមរបស់ព្រះអង្គឆ្ពោះទៅប្រទេសចិន ។ នៅពេលនោះ លោក អៀង សារី បាននិយាយទៅកាន់ ប៉ុល ពត ថាយន្តហោះចិននោះ មិនមានកន្លែងសម្រាប់ទាំងអស់គ្នាទេ មានតែកន្លែងថ្វាយសម្តេច និង ជូនអ្នកម្នាងតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែ ប៉ុល ពត បានបញ្ជាដាច់ខាតឲ្យលោក អៀង សារី ស្នើទៅភាគីចិនឲ្យជួលសំរួលរកកន្លែងឲ្យគ្រប់ដើម្បីបានចេញទៅទាំងអស់គ្នា ។

វិលមកព្រះដំណាក់វិញ សម្តេចនៅតែមិនទាន់អស់ព្រះទ័យ ខ្លាចក្រែងអ្វីដែលលោក អៀង សារី និយាយថាយន្តហោះមិនមានកន្លែងសម្រាប់គ្រប់គ្នានោះជាកលល្បិចរបស់ខ្មែរក្រហម ដើម្បីឃាត់ទុកព្រះរាជបុត្រ និង ព្រះញាតិវង្សឯទៀតជាចំណាប់ខ្មាំង កុំឲ្យព្រះអង្គមានសេរីភាពអាចធ្វើអ្វីតាមព្រះទ័យរបស់ព្រះអង្គបាន ។ ស្អែកឡើងព្រឹកថ្ងៃទី ៦ មករា លោក អៀង សារី បញ្ជូនបេសកជនមកទូលថាយន្ត

ហោះនោះ មានកន្លែងគ្រប់សម្រាប់ចេញដំណើរទាំងអស់គ្នា ពេលនោះទើបព្រះអង្គឈប់ព្រួយព្រះទ័យ ។ បន្ថែមលើដំណឹងដ៏ល្អនេះ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត បានថ្វាយប្រាក់បេសកកម្មចំនួន២ហ្មឺនដុល្លារអាមេរិកទៀតផង ។ សម្តេច សីហនុ អ្នកម្នាង ម៉ូនិច[78]ព្រះរាជបុត្រ[79] និង ព្រះញាតិឯទៀត ព្រមទាំងអ្នកហែរហមទាំងអស់របស់ព្រះអង្គ ក៏ដូចជាសម្តេច ប៉ែន នុត បានទៅដល់ប្រទេសចិននៅយប់ថ្ងៃទី ៦ មករា ១៩៧៩ ដោយសុវត្ថិភាព[80] ។ នៅល្ងាចថ្ងៃទី ៧ មករា ១៩៧៩ ចិនរៀបចំជប់លៀងទទួលសម្តេច តែអារម្មណ៍ពួកចិនកំពុងខ្វាយខ្វល់អំពីការដួលរលំនៃរបប ប៉ុល ពត ឯនោះទេ ។

នៅថ្ងៃ ទី ៨ មករា ១៩៧៩ សម្តេច បានធ្វើសន្និសីទសារព័ត៌មានមួយអស់រយៈពេល៦ម៉ោង នៅទីក្រុងប៉េកាំងនៅចំពោះមុខអ្នកកាសែតអន្តរជាតិចំនួន ២០០ នាក់ ក្នុងគោលបំណងធំបង្អស់គឺ ការពារបុព្វហេតុដ៏ត្រឹមត្រូវនៃកម្ពុជាប្រជាធិបតេយ្យ ដែលរងគ្រោះដោយអំពើឈ្លានពានពីសាធារណរដ្ឋសង្គមនិយមវៀតណាម ។ ក៏ប៉ុន្តែនៅទីបញ្ចប់ សន្និសីទសារព័ត៌មាននោះ ក៏ត្រឡប់ក្លាយទៅជាវេទិកាសម្រាប់សម្តេច សីហនុ ថ្កោលទោសយ៉ាងធ្ងន់ធ្ងរដល់របបប្រល័យពូជសាសន៍ខ្មែរក្រហមទៅវិញ តាមរយៈសំណួរជជីកដេញដោលយ៉ាងតឹងតែង ពីសំណាក់អ្នកកាសែតអន្តរជាតិទាំងនោះ ។

---

[78] កាលនោះ សម្តេចម៉ែ សម្តេចយាយ នៅជាអ្នកម្នាង មិនទាន់ឡើងជាសម្តេច នៅឡើយទេ ។

[79] ព្រះរាជបុត្រនោះគឺ ព្រះករុណាសម្តេចព្រះបរមនាថ សីហមុនី និង សម្តេច នរិន្ទ្រពង្ស ដែលសុគត នៅប្រទេសបារាំង នៅឆ្នាំ ២០០៣ ។

[80] ក្នុងបេសកកម្មក្រៅប្រទេសរបស់សម្តេច សីហនុ នៅពេលនោះ អង្គការ ប៉ុល ពត បានចាត់មន្ត្រីជាន់ខ្ពស់ ៣ នាក់ឲ្យធ្វើដំណើរតាមជាប់រហូតដល់ទីក្រុង ញូវយ៉ក ស.រ.អា គឺ៖ លោក ជួន ប្រសិទ្ធ លោក គាត ឈន់ និង កញ្ញា ប៉ុក ម៉ូណា ។

បន្ទាប់មក សម្តេច និង អ្នកម្នាង រួមទាំងមន្ត្រីជាន់ខ្ពស់ខ្មែរក្រហមមាន លោក ជួន ប្រសិទ្ធ និង លោក គាត ឈន់[81] ផង ក៏ធ្វើដំណើរទៅកាន់ទីក្រុងញូវយ៉ក ដើម្បីចូលរួមប្រជុំក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ស្តីពីការលុកលុយកម្ពុជាប្រជាធិបតេយ្យ ដោយកងទ័ពវៀតណាម ដូចព្រះអង្គបានសន្យាជាមួយ ប៉ុល ពត មេដឹកនាំកំពូលរបស់ខ្មែរក្រហមយ៉ាងដូច្នេះមែន ។ ក្នុងដំណើររបស់ព្រះអង្គ ទៅកាន់ទីក្រុងញូវយ៉កលើកនេះ សម្តេច សីហនុ បានវាស់ស្ទង់នូវទំហំដ៏ធំធេងនៃការស្អប់ខ្ពើមរបស់សាធារណមតិអន្តរជាតិ ចំពោះរបប ប៉ុល ពត ។ ការដែលព្រះអង្គទទួលមុខនាទីជាអ្នកនាំពាក្យ ឬ អ្នកតំណាងឲ្យរបបនេះ មិនបានលើកកិត្តិយសរបស់ព្រះអង្គឡើយ ។ ការបាត់បង់ព្រះរាជបុត្រា បុត្រី ព្រះរាជនត្តា និង បុគ្គលជាទីស្រឡាញ់របស់ព្រះអង្គ ធ្វើឲ្យព្រះអង្គធ្លាក់ទឹកព្រះទ័យជាខ្លាំង ។ ម្យ៉ាងទៀត ទោះជាស្ថិតនៅក្នុងសភាពដុនដាបយ៉ាងខ្លាំងណាស់ទៅហើយក៏ដោយ ក៏ពួកខ្មែរក្រហមនៅតែប្រកាន់ឫកពាដ៏គឃ្លើនចំពោះព្រះអង្គទៀត ។ ទាំងនេះរឹតតែធ្វើឲ្យសម្តេចសម្រេចព្រះទ័យរត់ចោលពួក ប៉ុល ពត ដើម្បីរំដោះព្រះអង្គ និង ស្វែងរកសេរីភាពឲ្យធំទូលាយ ។

# ភាពគឃ្លើនរបស់ខ្មែរក្រហមចំពោះព្រះអង្គ

នៅក្នុងសៀវភៅរបស់ព្រះអង្គនោះ[82] សម្តេច សីហនុ សរសេរថា ទឹកពីរតំណក់ចុងក្រោយ ដែលធ្វើឲ្យទឹកហៀរចេញពីកែវនោះគឺ ជាហេតុផលទ្រាំពុំបាន

[81] នេះជាការលើកឡើងដោយសម្តេចព្រះ នរោត្តម សីហនុ ក្នុងសៀវភៅរបស់ព្រះអង្គ ក្រោមចំណងជើង អ្នកជាគុកខ្មែរក្រហម

[82] Norodom Sihanouk, Les Prisonniers des Khmers Rouges, op.cit, p. 341.

ជំរុញឲ្យព្រះអង្គរកវិធីគេចចេញពីការត្រួតត្រាឃ្លាំមើលរបស់ខ្មែរក្រហម ។ តំណក់ទឹកទី១៖ លោក ជួន ប្រសិទ្ធ ទូលសម្តេចថា ភារកិច្ច និង បេសកកម្មរបស់ព្រះអង្គនៅក្រុមប្រឹក្សាសន្តិសុខ បន្ទាប់មកទៀតនាពេលខាងមុខ នៅមហាសន្និបាតអង្គការសហប្រជាជាតិលើកនេះ ត្រូវតែទទួលមហាជោគជ័យ ព្រោះតាំងពីឆ្នាំ ១៩៧៥ រហូតមកមិត្ត អៀង សារី បានប្រមែប្រមូលនូវការគោរពស្រឡាញ់រាប់អាន និង ការគាំទ្រដ៏ធំធេងពីសំណាក់សមាជិកភាគច្រើន ចំពោះរបបកម្ពុជាប្រជាធិបតេយ្យរួចទៅហើយ ។ ឮសំដីអំនួតបែបនេះ សម្តេច នឹកថាបើរបប ប៉ុល ពត មានប្រជាប្រិយភាពនៅលើឆាកអន្តរជាតិមែន និង ប្រសិនបើ ប៉ុល ពត មិនត្រូវការព្រះអង្គទេនោះ ម្ល៉េះសម ប៉ុល ពត មិនមកសុំឲ្យព្រះអង្គចេញពីក្នុងស្រុកមកក្រៅប្រទេសដូច្នេះទេ ឬ ប៉ុល ពត អាចធ្វើឃាតព្រះអង្គចោលផងក៏បាន ។ តំណក់ទឹកទី២៖ ពីទីក្រុងប៉េកាំង សម្តេច សីហនុ បានទទួលសារមួយច្បាប់ ទូលព្រះអង្គថា នៅពេលចប់ការពិភាក្សានៅក្រុមប្រឹក្សាសន្តិសុខរួចហើយ សូមឲ្យសម្តេច ដឹកនាំ "ជាបណ្តោះអាសន្ន" នូវគណៈប្រតិភូរបស់កម្ពុជាប្រជាធិបតេយ្យ ចូលរួមមហាសន្និបាត អ.ស.ប លើកទី ៣៤ តទៅទៀតសិន ទម្រាំប្រធានគណៈប្រតិភូពេញសិទ្ធិ គឺលោក អៀង សារី ធ្វើដំណើរមកដល់ទីក្រុងញូវយ៉ក ។ ចំណុចនេះសម្តេច ដែលជាអតីតមហាក្សត្រ និង ប្រមុខរដ្ឋខ្មែរមិនអាចទទួលយកបានឡើយ ។ ព្រះអង្គប្រាកដជាមិនអាចបន្តដង្ហែរមេខ្មែរក្រហមតទៅទៀត ជាពិសេស នៅបន្តហែរហម អៀង សារី ដែលជាបុគ្គលត្រូវគេមាក់ងាយទូទាំងសាកលលោក និង គួរឲ្យស្អប់ខ្ពើមជាទីបំផុត ដោយមានឋានៈត្រឹមតែជាអនុប្រធានទេនោះ ។ ចំណុចពីរខាងលើនេះជាមូលហេតុនាំព្រះអង្គឲ្យសំរេចព្រះទ័យគេចចេញពីខ្មែរក្រហម ។

# បានពួក អេហ្វ ប៊ី អាយ ជួយរំដោះព្រះអង្គ

បន្ទាប់ពីបានបញ្ចប់បេសកកម្មនៅក្រុមប្រឹក្សាសន្តិសុខ ដោយជោគជ័យរួចមក នៅវេលាម៉ោង ២ ហៀបភ្លឺថ្ងៃទី ១៤ មករា ១៩៧៩ ដោយបានណាត់គ្នាជាមុនជាមួយភ្នាក់ងារសម្ងាត់ អេហ្វ ប៊ី អាយ (FBI: Federal Bureau of Investigation) របស់អាមេរិក សម្តេច សីហនុ បានលបយាងចេញពីសណ្ឋាគារដ៏ធំ និង ថ្លៃជាងគេនៅទីក្រុងញ៉ូវយ៉ក ជាមួយវ៉ាលីសមួយតែមួយព្រះអង្គឯង តាមរថយន្តឆ្ពោះទៅស្ថានតំណាងអចិន្ត្រៃយ៍របស់ ស.រ.អា ប្រចាំអង្គការសហប្រជាជាតិ ដែលមានលោកឯកអគ្គរដ្ឋទូត អង់ឌ្រូវ យ៉ង់ (Andrew Young)[83] ជាប្រមុខ ។ ព្រឹកឡើងថ្ងៃទី ១៤ នោះ អាជ្ញាធរអាមេរិក ក៏ជួយនាំអ្នកម្នាងជាព្រះជាយាឲ្យបានមកជួបជុំជាមួយព្រះអង្គដោយសុវត្ថិភាព ។ មុននឹងបែកពីខ្មែរក្រហម អ្នកម្នាង ម៉ូនិច បានប្រគល់ប្រាក់ ២ ហ្មឺនដុល្លារដែលជាប្រាក់បេសកកម្មទៅឲ្យមន្ត្រីជាន់ខ្ពស់ខ្មែរក្រហមវិញ ។ តាមពិតទៅ លោកឯកអគ្គរដ្ឋទូត អង់ឌ្រូវ យ៉ង់ ក៏បានយកចិត្តទុកដាក់ជួយរំដោះសម្តេច និង អ្នកម្នាងពីអំណាចខ្មែរក្រហម ប៉ុល ពត ដែរ ដោយបញ្ជូនឲ្យទៅត្រួតពិនិត្យព្រះសុខភាពភ្លាមនៅមន្ទីរពេទ្យដ៏ធំមួយ ក្នុងទីក្រុងញូវយ៉ក ។ យាងទៅដល់មន្ទីរពេទ្យ សម្តេច សីហនុ និង អ្នកម្នាង បន្តស្វែងរកសេរីភាពតទៅទៀត ។ រំពេចនោះព្រះអង្គសរសេរលិខិតសុំសិទ្ធិជ្រកកោននៅ ស.រ.អា ។ ដោយពុំមានចម្លើយពី ស.រ.អា ព្រះអង្គក៏សុំទៅ ប្រទេសបារាំងឲ្យផ្តល់លិខិតឆ្លងដែនបារាំងពីរច្បាប់មួយសម្រាប់ព្រះអង្គផ្ទាល់ មួយច្បាប់ទៀតសម្រាប់អ្នកម្នាងជាព្រះជាយា ព្រោះព្រះអង្គមិនចង់កាន់លិខិតឆ្លងដែនរបស់ខ្មែរក្រហមតទៅទៀតឡើយ ។ បារាំងឆ្លើយមកសម្តេចវិញថា ប្រទេសបារាំងថ្វាយសិទ្ធិជ្រកកោនតែ

[83] Norodom Sihanouk, Les Prisonniers des Khmers Rouges, op.cit, p. 342.

មានលក្ខខណ្ឌគឺ សម្តេចមិនត្រូវធ្វើសកម្មភាពនយោបាយ និង ទាក់ទងជាមួយអ្នកកាសែតឡើយនៅលើទឹកដីបារាំង ។ ចម្លើយនេះធ្វើឲ្យព្រះអង្គមិនពេញព្រះទ័យទាល់តែសោះ ។ គាប់ជួននៅពេលនោះ មេដឹកនាំចិនលោក តេង ស៊ាវពីង បានទៅធ្វើទស្សនកិច្ចនៅ ស.រ.អា និង បានស្នើសម្តេចយាងនិវត្តទៅប្រទេសចិនវិញ ។

## ទីបំផុតព្រះអង្គព្រមយាងត្រឡប់ទៅស្រុកចិនវិញ

សម្តេច សីហនុ បានសរសេរក្នុងសារណារបស់ព្រះអង្គ ដែលបកប្រែជាភាសាអង់គ្លេសដោយលោក ជូលីយ៉ូ ជេលដ្រេស (Julio A. Jeldres)[84] ថានៅថ្ងៃទី ៣១ មករា ១៩៧៩ លោក តេង ស៊ាវពីង បានយាងសម្តេចទៅសោយអាហារពេលល្ងាច នៅវិមានទទួលភ្ញៀវរដ្ឋរបស់អាមេរិក ប្លែរ ហៅស្ស៍ (Blair House) នៅទីក្រុងវ៉ាស៊ិនតោន ។ នៅឱកាសនោះ មេដឹកនាំចិនរូបនេះបានស្នើសម្តេចឲ្យព្រះអង្គទទួលធ្វើជាមេដឹកនាំនៃមហារណសិរ្សបង្រួបបង្រួមជាតិ និង ជាប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យឡើងវិញ ដោយលោក តេង ស៊ាវពីង ទូលព្រះអង្គថា ឥឡូវនេះមេដឹកនាំទាំងអស់នៃរបបកម្ពុជាប្រជាធិបតេយ្យសន្យាថា មិនធ្វើឲ្យមានកំហុសខុសឆ្គងដូចមុនទៀតឡើយ ។ម្យ៉ាងទៀតមេដឹកនាំខ្មែរក្រហមទាំងនោះទទួលស្គាល់កំហុសថា បន្ទាប់ពីជ័យជំនះឆ្នាំ ១៩៧៥ ពួកគេបានរំលាយរណសិរ្សរួបរួមជាតិកម្ពុជាចោល ដោយយកចំណេញសម្រាប់តែភាគីរបស់ពួកខ្លួនតែឯងនេះបើតាមសំដីលោក តេងស៊ាវពីង ។ សម្តេច ប្រកែកពុំព្រមទទួលតាមសំណើនេះទេ ទោះបីជាលោក តេង ស៊ាវពីង ខំពន្យល់ព្រះអង្គយ៉ាងណាក៏ដោយ ។ នៅទី

[84] Norodom Sihanouk, Shadow Over Angkor, Memoirs of His Majesty the King of Cambodia, translated by Ambassador Julio A. Jeldres, Monument Books, Phnom Penh, 2005, p. 205-206.

បំផុតមេដឹកនាំចិន ក៏លះបង់គំនិតស្នើសុំឲ្យសម្ដេចធ្វើជាប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យសាជាថ្មី និង ឈប់ពាក់ព័ន្ធព្រះអង្គជាមួយខ្មែរក្រហមតទៅទៀត ។ ក៏ប៉ុន្តែ លោក តេង ស៊ាវពីង ទទូចសុំតែចំណុចមួយទេគឺ សុំឲ្យព្រះអង្គវិលត្រឡប់ទៅគង់នៅប្រទេសចិនវិញ រហូតដល់ពេលព្រះអង្គ អាចយាងវិលទៅកម្ពុជាវិញបាន ព្រមទាំងធានាថារដ្ឋាភិបាលចិនថ្វាយសេរីភាពគ្រប់យ៉ាង ទាំងនៅក្នុងប្រទេសចិន ទាំងនៅក្នុងទស្សនកិច្ចម្ដងម្កាលរបស់ព្រះអង្គនៅក្រៅពីប្រទេសចិន ។ ហេតុដូច្នេះហើយបានជាសម្ដេច សីហនុ ព្រមយាងទៅប្រទេសចិនវិញ ម្ដងនេះក្នុងឋានៈព្រះអង្គជាមនុស្សសេរី ដែលរួចចាកពីអំណាចខ្មែរក្រហមរហូតមក ។

## អរផង ភ័យផង ចំពោះជ័យជំនះ ៧ មករា

សហគមន៍ខ្មែរនៅប្រទេសបារាំង ក៏ដូចជាប្រជាពលរដ្ឋខ្មែរទាំងមូលនោះដែរ បានទទួលអបអរសាទរចំពោះការដួលរលំនៃរបបខ្មែរក្រហម ។ ក៏ប៉ុន្តែ ដំណឹងដែលថាកងទ័ពវៀតណាមជាអ្នកផ្ដួលរំលំរបប ប៉ុល ពត និង ថាកងទ័ពវៀតណាមរាប់សែននាក់នេះកាន់កាប់ទឹកដីខ្មែរ បានធ្វើឲ្យអំណរសាទរ និង ក្ដីសប្បាយរបស់សហគមន៍ខ្មែរទាំងនោះក្លាយជាក្ដីបារម្ភ និង ការភ័យខ្លាចរបស់ពួកគេក្នុងការបាត់បង់ទឹកដីកម្ពុជាទាំងមូលទៅវិញ ។ មែនទែនទៅ ខ្មែរនៅក្រៅប្រទេសភាគច្រើនហាក់ដូចជាមិនបាននឹកនាដល់គ្រោះមហន្តរាយនៃការវិលត្រឡប់របស់ ប៉ុល ពត មកកាន់អំណាចវិញឡើយ ។ សហគមន៍ខ្មែរនៅក្រៅប្រទេសទាំងនោះទទួលស្គាល់ថា ខ្មែរក្រហមពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មកាប់សម្លាប់ជ្រាពលរដ្ឋខ្មែរមែន ក៏ប៉ុន្តែការកាន់កាប់ទឹកដីខ្មែរដោយកងទ័ពវៀតណាមគឺ ជាសញ្ញានៃការបាត់បង់ព្រលឹងជាតិខ្មែរ ។ ការមិនអាចទទួលយកបាននូវការលុកលុយរបស់បរទេសនេះ បាន

បង្កើតឡើងនូវស្មារតីស្នេហាជាតិ និង ជាតិនិយមនៃខ្មែរនៅក្រៅប្រទេសដែលបានរួបរួមគ្នាជាក្រុម ជាសមាគម ហើយបានជំរុញឲ្យពួកគេទាំងនោះ នាំគ្នាចូលប្រឡូកធ្វើសកម្មភាពនយោបាយឡើង ។ នៅសម័យនោះ និន្នាការទូទៅនៅក្រៅប្រទេសគឺវៀតណាមឈ្លានពានកម្ពុជា មិនមែនមកជួយយកអាសារប្រជាជនកម្ពុជាឲ្យរួចចាកពីរបបប្រល័យពូជសាសន៍ឡើយ ។ ខ្មែរភាគច្រើននៅក្រៅប្រទេសរួមទាំងរូបខ្ញុំផងមិនបាននឹកដល់ថាបើគ្មានប្រល័យពូជសាសន៍ ក៏គ្មានអំពើឈ្លានពានរបស់បរទេសនេះដែរ ។ ម្យ៉ាងទៀត បើរង់ចាំឲ្យក្រុមអ្នកតស៊ូខ្មែរនៅទិសខាងលិច ដែលពឹងពាក់ថៃមកជួយរំដោះ មិនដឹងជាត្រូវរង់ចាំប៉ុន្មានឆ្នាំទៀត បើថៃនៅពេលនោះលំអៀងទៅខាងចិន ដែលផ្តល់ការគាំទ្រយ៉ាងរឹងមាំដល់ ប៉ុល ពត ។ នៅសម័យនោះថៃមិនមានឆន្ទៈនយោបាយ និង មធ្យោបាយផ្នែកទ័ពអាចមកវាយរំដោះប្រជាពលរដ្ឋខ្មែរពីរបបប្រល័យពូជសាសន៍ ប៉ុល ពត សោះឡើយ ។ ដូច្នេះតើ ប៉ុល ពត អាចបន្តកាប់សម្លាប់ខ្មែរប៉ុន្មានហ្មឺន ប៉ុន្មានសែននាក់ទៀត បើខ្មែរយើងត្រូវរង់ចាំចលនាតស៊ូនៅជាយដែនថៃមកជួយរំដោះនោះ ?

វិលត្រឡប់មកនិយាយអំពីចលនានៅប្រទេសបារាំងម្តងវិញ នាដើមឆ្នាំ ១៩៧៩ នោះ ។ ភ្លាមៗនោះ មានការរៀបចំប្រជុំនៅច្រើនកន្លែង ។ ខ្ញុំក៏បានទទួលការអញ្ជើញឲ្យចូលរួមប្រជុំមួយដែរ ។ សេចក្តីអញ្ជើញដែលខ្ញុំបានទទួលតាមប្រៃសណីយមួយនោះ មិនមានបញ្ជាក់ពីអង្គការ ដែលរៀបចំប្រជុំនោះទេ គេគ្រាន់តែឲ្យដឹងពីពេលវេលា ទីកន្លែង និង កម្មវត្ថុនៃអង្គប្រជុំតែប៉ុណ្ណោះ ។ អាស័យដ្ឋាននៃអង្គប្រជុំគឺ ឋិតនៅផ្លូវ ហ្វូបួ សាំង-ដឹនី (Faubourg Saint-Denis) ជាកន្លែងមួយដែលគួរឲ្យឆ្ងល់ ។ នៅពេលដែលខ្ញុំទៅដល់កន្លែងនោះ ខ្ញុំមិនហ៊ានចូលទៅភ្លាមទេ ព្រោះជាហាងលក់សៀវភៅ និង ប្រដាប់ប្រដាសំរាប់ផ្លូវភេទ (Sex Shop) ហើយម្យ៉ាងទៀត នៅខាងក្នុងមានមនុស្សតែពីរបីនាក់ប៉ុណ្ណោះ ។ ខ្ញុំដើរចុះដើរឡើង រេរា

ជាច្រើនដង ព្រោះខ្ញុំនឹកថាកន្លែងនេះមិនគួរជាទីកន្លែង ដែលត្រូវពិភាក្សាពីរឿងនយោបាយស្រុកទេសនោះឡើយ ។ នៅពេលដែលខ្ញុំសំរេចថាចូលទៅខាងក្នុងនោះ មានអ្នកលក់ម្នាក់ជាជនជាតិខ្មែរ ប្រាប់ខ្ញុំថាឲ្យដើរចូលទៅខាងក្នុង ដែលនៅទីនោះ ខ្ញុំឃើញយុវជនខ្មែរបួន ឬ ប្រាំនាក់ ដែលមានអាយុប្រហាក់ប្រហែលខ្ញុំដែរ ហើយដែលខ្ញុំមិនដែលស្គាល់សោះនោះ កំពុងជជែកគ្នាអំពីអំពើឈ្លានពានរបស់វៀតណាមមកលើកម្ពុជា ។ ខ្ញុំមានការខកចិត្តជាខ្លាំង ដោយខ្ញុំពុំបានឮអ្វីជាខ្លឹមសារ ឬ យុទ្ធសាស្ត្រអ្វីជាក់លាក់ ដែលអាចធ្វើឲ្យពាក្យពេចន៍ស្នេហាជាតិ ឬ អ្នកជាតិនិយមនោះ អាចក្លាយជាសកម្មភាពជាក់ស្តែងក្នុងការប្រយុទ្ធប្រឆាំងនឹងកងទ័ពវៀតណាមឈ្លានពាននោះឡើយ ។ ម្យ៉ាងទៀត ខ្ញុំមិនអាចផ្ទង់ស្មារតីជជែកពិភាក្សាអំពីបញ្ហាប្រទេសជាតិអស់នោះ នៅចំពោះមុខគំនរសៀវភៅ និង រូបភាពអាសអាភាសដែលគេទុក និង ព្យួររណោងរណោងពាសពេញទីនោះបានឡើយ ។ ខ្ញុំយល់ឃើញថារវាងខ្មែរ និង វៀតណាម ប្រាកដជាមានអរិភាពយ៉ាងខ្លាំងក្លាមែន ព្រោះសូម្បីតែនៅក្នុងហាងលក់សៀវភៅ និង ប្រដាប់ប្រដាសំរាប់ផ្លូវភេទបែបនេះ ក៏គេនាំគ្នានិយាយអំពីនយោបាយ និង ការតស៊ូប្រឆាំងនឹងវៀតណាមដែរ ។ នៅពេលនោះ ខ្មែរយើងនៅក្រៅប្រទេសភាគច្រើន មិនទទួលយកគំនឹតថាកងទ័ពវៀតណាមទាំងនោះមកជួយរំដោះខ្មែរយើង ឲ្យរួចពីការកាប់សម្លាប់របស់ពួកប្រល័យពូជសាសន៍ ប៉ុល ពត នោះទេ ។

# អបអរសាទរព្រះអង្គ ដែលនៅគង់ព្រះជន្មនៅឡើយ

ខ្មែរមួយចំនួនធំ ដោយរាប់ទាំងលោកតា សឺន សាន ផងមានការធូរស្បើយក្នុងចិត្តនៅពេលដែលដឹងថា សម្តេច សីហនុ នៅគង់ព្រះជន្មនៅឡើយ ហើយបាន

រត់រួចពីកងទ័ពវៀតណាម ។ នៅថ្ងៃ ៨ មករា ១៩៧៩ លោកតា សឺន សាន បានផ្ញើសារទូរលេខមួយច្បាប់ក្នុងនាមព្រឹទ្ធាចារ្យខ្មែរនៅប្រទេសបារាំង ទៅថ្វាយព្រះអង្គថា៖ "ឯ.ឧ. នង គិមនី ឯ.ឧ. ញឹក ជូឡុង ឯ.ឧ. ចាយ ធុល ឯ.ឧ. ថុន អ៊ុក និងទូលបង្គំ មានសេចក្តីត្រេកអរជាខ្លាំង ដោយដឹងថាព្រះអង្គបានយាងមកដល់ទីក្រុងប៉េកាំង ស្តុប[85] ជនរួមជាតិខ្មែរនៅបរទេសភាគច្រើនណាស់ រួមទាំងនាយទាហានជាន់ខ្ពស់ផងមានជំនឿលើអង្គសម្តេច ដើម្បីបណ្តេញជាបន្ទាន់នូវរបប ប៉ុល ពត ដែលពិភពលោកផ្តន្ទាទោស និង ដើម្បីឲ្យកងទ័ពវៀតណាមខាងជើងទាំងអស់ ដកចេញពីប្រទេសកម្ពុជា ឆ្ពោះទៅសម្រេចមហាសាមគ្គីជាតិក្នុងក្របខ័ណ្ឌកម្ពុជាអព្យាក្រឹត្យពិតប្រាកដ និង ឯករាជ្យ ស្តុប ដោយគោរពជាទីបំផុត ស្តុបបញ្ចប់ សឺន សាន[86]" ។ ដោយបានទទួលដំណឹងថា សម្តេច យាងទៅទីក្រុងញូវយ៉ក លោកតា សឺន សាន ក៏ធ្វើដំណើរទៅរកជួបព្រះអង្គ នៅសហរដ្ឋអាមេរិក ។ ក៏ប៉ុន្តែ នៅពេលលោកតាទៅរកសម្តេចឯសណ្ឋាគារនាទីក្រុងញូវយ៉កនោះ ភ្នាក់ងារសម្ងាត់អាមេរិកបានរំដោះព្រះអង្គឲ្យគង់នៅក្នុងមន្ទីរពេទ្យមួយ ដែលមិនអាចទៅជួបបាន ។ លោកតា សឺន សាន បានត្រឹមតែជួបព្រះអង្គតាមទូរស័ព្ទតែប៉ុណ្ណោះ ។

## នយោបាយជាន់ខ្ពស់របស់លោកតា សឺន សាន

នៅពេលត្រឡប់ពីទីក្រុងញូវយ៉កវិញ នៅចុងខែ មករា ១៩៧៩ លោកតា សឺន សាន បានបញ្ជូនឧត្តមសេនីយ ដៀន ដែល ឲ្យទៅប្រទេសថៃ រួចចុះទៅដល់

---

[85] នៅក្នុងសារទូរលេខ ដោយគេមិនអាចប្រើខណ្ឌសញ្ញាបាន គេប្រើអក្សរ (STOP) ស្តុបជំនួសខណ្ឌសញ្ញា និង (STOPEND) ស្តុបបញ្ចប់ ជំនួសសញ្ញាខណ្ឌចប់ ។

[86] Son Sann (Télégramme 00740 de) à SAR Norodom Sihanouk c/o Ministère des Affaires Etrangères, le 8 octobre 1979, RP Chine, Pékin.

សមរភូមិនៅតាមទល់ដែនខ្មែរ-ថៃ ដើម្បីប្រមែប្រមូលចងក្រងកម្លាំងតស៊ូទាំងអស់ ដែលនៅរប៉ាត់រប៉ាយគ្នានោះឲ្យទៅជាកម្លាំងរួបរួមជាតិមួយក្នុងការតស៊ូរំដោះជាតិ ។ លោកតា សឺន សាន បានប្រាប់ពួកយើងនៅពេលក្រោយៗមកទៀតថា លោកតាបានទូលសម្តេច សីហនុ តាមទូរស័ព្ទឲ្យជ្រាបអំពីសេចក្តីសំរេចបង្កើតកម្លាំងតស៊ូ ហើយបានស្នើសុំឲ្យព្រះអង្គដឹកនាំចលនាតស៊ូរំដោះជាតិនេះ ដែលប្រុងនឹងបង្កើតនោះ ។ បើតាមសំដីលោកតា សឺន សាន សម្តេច សីហនុ មិនព្រមទទួលមុខនាទីដឹកនាំចលនាតស៊ូនេះទេ ព្រោះព្រះអង្គមិនមានបំណងនឹងធ្វើសកម្មភាពនយោបាយណាមួយឡើយនៅពេលនោះ ។ លោកតា សឺន សាន បញ្ជាក់ថា សម្តេចក៏មិនបានប្រឆាំងគំនិតបង្កើតចលនាតស៊ូនេះដែរ គ្រាន់តែសុំកុំអាលយកព្រះនាមព្រះអង្គមកប្រើតែប៉ុណ្ណោះ ។

តាមរយៈលោកឧត្តមសេនីយ ដៀន ដែល លោកតា សឺន សាន បានផ្ញើសារមួយច្បាប់ទៅជូនមេៗយុទ្ធជនសេរីកាទាំងអស់ ដើម្បីណែនាំថា លោក ដៀន ដែល ទទួលបេសកកម្មពីលោកតាឲ្យមកបង្កើតកងទ័ពរំដោះជាតិមួយដោយប្រមូលយុទ្ធជនទាំងអស់ នៅតាមជាយដែន មុននឹងឈានទៅបង្កើតអង្គការចាត់តាំងខាងនយោបាយមួយ ដើម្បីដឹកនាំការតស៊ូរំដោះជាតិ ។ លោកតា បានគូសបញ្ជាក់ថា បើមិនធ្វើតាមនេះទេ យុទ្ធជនទាំងនោះមិនអាចសង្ឃឹមថា នឹងទទួលនូវជំនួយពីប្រទេសជាមិត្តឡើយ ។ ដូច្នេះ ជំនួយជាកត្តាគន្លឹះនៃការអូសទាញប្រមែប្រមូលកម្លាំងនេះ ព្រោះបើគ្មានជំនួយពីខាងក្រៅទេ យុទ្ធជនទាំងនោះ មិនអាចសង្ឃឹមធ្វើសកម្មភាពអ្វីឲ្យធំដុំបានឡើយ ។

តាមពិតលោកតា សឺន សាន បានធ្វើការបញ្ចុះបញ្ចូលអំពាវនាវដល់មេដឹកនាំក្រុមអ្នកតស៊ូទាំងអស់នៅតាមជាយដែននោះ ឲ្យមករួបរួមគ្នាដើម្បីបង្កើតជាកងទ័ពនៅក្នុងរណសិរ្សមួយប្រឆាំងវៀតណាម ។ ឧត្តមសេនីយ ដៀន ដែល ឈ្មោះ

ចម្បាំងហៅថា ដែល ដេវី បានធ្វើដំណើរពីទីក្រុងប៉ារីស ក្នុងនាមជាបេសកជនរបស់លោកតា សឺន សាន ដើម្បីនាំសាររបស់លោកតា មកជូនយុទ្ធជនសេរីកានៅលើសមរភូមិ ។ លោកឧត្តមសេនីយបានទទួលជោគជ័យដោយបានទទួលការស្វាគមន៍ ពីក្រុមយុទ្ធជនសេរីកាស្ទើរទាំងអស់ ។

នៅថ្ងៃទី ៥ មីនា ១៩៧៩ អ្នកតស៊ូខ្មែរ ១៦ នាក់[87] បានជួបជុំគ្នានៅលើទឹកដីខ្មែរ ។ អ្នកទាំងនោះ សុទ្ធតែជាមេដឹកនាំក្រុមអ្នកតស៊ូ ដែលមានៈ ១. លោក អ៊ឹម ឈូដេត ២. លោក កេត រ៉េត ៣. លោក សុខ សេរី ៤. លោក ក្រវ៉ាញ ផល ៥. លោក មហាក្រៃ ៦. លោក លុច ផៃ ៧. លោក ទួន ចាយ ៨. លោក សែន សុខរស្មី ៩. លោក ដែល ដេវី ១០. លោក សេក សំអៀត ១១. លោក កែវ សារុធ ១២. លោក ចាយ សីលា ឬ ម៉ៅ ហម ១៣. លោក មួន សុភ័ណ ១៤. ញ៉ែម ភួង ១៥. លោក បែន វី ១៦. លោក សៀម សំអុន ។ អ្នកដឹកនាំទាំង ១៦ រូបនេះបានស្រុះស្រួលគ្នាបង្កើតជាកងទ័ពមួយឈ្មោះថា កងកម្លាំងជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។ គេទាំងអស់គ្នា បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍បង្កើតកងទ័ពនេះ ដោយបានគូសបញ្ជាក់អំពីហេតុផល ឬ មូលហេតុ ដែលនាំឲ្យកងទ័ពកកើតឡើង និងដោយបានធ្វើការអំពាវនាវ ឲ្យខ្មែរគ្រប់និន្នាការចូលមករួបរួមជាមួយយុទ្ធជនសេរីកា ដើម្បីបង្កើតរណសិរ្សយោធា និង នយោបាយមួយ នៅពេលក្រោយ ដែលគេនឹងឲ្យឈ្មោះថា រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ.) ដើម្បីរំដោះកម្ពុជាឲ្យចេញពីការកាន់កាប់របស់បរទេស និង ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរធ្វើការជ្រើសរើសដោយសេរីនូវរបបនយោបាយគ្រប់គ្រងប្រទេសរបស់ខ្លួន ។ ក្រុមយុទ្ធជនសេរីកាទាំងនោះបានសុំឲ្យលោកតា សឺន សាន ធ្វើជាអ្នកដឹកនាំរបស់ពួកគេក្នុងបេសកកម្មបង្រួបបង្រួមជនរួមជាតិខ្មែរ[88] ដោយក្រុមយុទ្ធជនទាំងនោះប្រគល់ជូនលោកតានូវ

[87] KPNLF Bulletin No. 4, March 12, 1983 p. 1.
[88] KPNLF Bulletin no. 4, “Declaration of the KPNLAF, March 5, 1979” op. cit, p.3.

អំណាចគ្រប់យ៉ាងដើម្បីបំពេញបេសកកម្មនេះ ។ ក៏ប៉ុន្តែនៅក្នុងសេចក្តីថ្លែងការណ៍របស់ក្រុមយុទ្ធជនសេរីកាទាំងនោះ ពួកគេបានបើកទ្វារចំហរថ្វាយសម្តេច សីហនុ ក្រែងថ្ងៃណាមួយ សម្តេចនឹងយាងចូលរួមធ្វើការតស៊ូជាមួយ ដោយទុកលទ្ធភាពថ្វាយព្រះអង្គ ចូលមកធ្វើការដឹកនាំចលនាតស៊ូនៅពេលណាក៏បាន ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ក្រុមយុទ្ធជនសេរីកានោះ មានថ្លែងជាអាទិថា៖ "រ.ជ.រ.ប.ខ. នឹងបំរើឥស្សរជនខ្មែរណា ដែលគោរពគោលការណ៍របស់ពួកគេ ហើយដែលអាចបង្កើតឲ្យមានសាមគ្គីភាពនៃខ្មែរទាំងអស់" ។ ឥស្សរជនខ្មែរនាពេលនោះ សំដៅលើអង្គសម្តេច សីហនុ នេះតែម្តង ។ ទទួលបានសំណូមពររបស់យុទ្ធជនសេរីកាទាំងនោះរួចហើយ លោកតា សឺន សាន មិនទាន់សម្រេចចិត្តភ្លាមទេ ។ លោកតាប្រើពេលវេលាប្រហែលពីរខែ ដើម្បីថ្លឹងថ្លែងថាតើគួរទៅដឹកនាំយុទ្ធជនសេរីកាទាំងនោះដែរឬទេ? ម្យ៉ាង លោកតានៅស្ទាក់ស្ទើរក្នុងចិត្ត ដោយមិនទាន់ដឹងច្បាស់ថា តើសម្តេចសីហនុ មានបំណងយ៉ាងណា? តើព្រះអង្គយាងមកដឹកនាំចលនាតស៊ូដែរឬទេ? ក្រោយមក នៅថ្ងៃទី ២៩ មេសា ១៩៧៩ លោកតា សឺន សាន ដែលមានអាយុ ៦៨ ឆ្នាំ បានយល់ព្រមតាមសំណើរបស់អ្នកតស៊ូទាំង ១៦ នាក់ ដើម្បីចូលទៅរៀបចំចលនា រ.ជ.រ.ប.ខ. នេះឡើង ។

ការសម្រេចចិត្តរបស់លោកតា សឺន សាន ទាំងនេះក៏សុទ្ធតែជា "នយោបាយជាន់ខ្ពស់" ដែលគ្មាននរណាដឹងឮសោះឡើយ ក្រៅតែពីអ្នកដែលនៅជិតដិតប៉ុន្មាននាក់តែប៉ុណ្ណោះ ។ សមាជិកភាគច្រើននៅក្នុងសមាគមមិនបានដឹងរឿងសម្ងាត់ទាំងអស់នោះទេ ។ រឿងនេះ ក៏ដូចជារឿងសម្ងាត់ដែលលោកតា សឺន សាន ធ្វើដំណើរ ទៅទីក្រុងញូវយ៉ក ដើម្បីជួបសម្តេច សីហនុ ។ នៅពេលត្រឡប់ពីទីក្រុងញូវយ៉កមកវិញ ទើបលោកតាកោះប្រជុំសមាជិកសកម្ម ដើម្បីផ្តល់ព័ត៌មានខ្លះៗតែប៉ុណ្ណោះ ។ មែនទែនទៅ លោកតា សឺន សាន និង មនុស្សជំនិតៗឃុំគ្រងព័ត៌មាន

បានល្អណាស់គឺ អ្វីដែលអាចឲ្យដឹង និង អ្វីដែលរក្សាជាការអាថ៌កំបាំង ។ គេឲ្យដឹងចំពោះនរណាដែលស្មោះត្រង់ពិតប្រាកដ ជាពិសេស អ្នកណាដែលមានការទុកចិត្តពីក្រុមគ្រួសាររបស់លោកតា តាមរបៀបធ្វើការដោយបើកចំហរផងដោយការសម្ងាត់ផង ។ នៅពេលដែលលោកតា សឺន សាន បញ្ជូនឧត្តមសេនីយ ដៀន ដែល ទៅទល់ដែនខ្មែរ-ថៃ លោកតាមិនបានឲ្យពួកយើងដឹងឡើយ ។ តាមពិតទៅពួកយើងក្មេងៗ ដែលស្ម័គ្រចិត្តមកធ្វើការជាមួយលោកតា សឺន សាន មិនដែលទាមទារចង់ដឹងចង់ឮអំពីការសម្ងាត់អ្វីទេ ។ ក៏ប៉ុន្តែជួនកាលយើងក៏មានការភ្ញាក់ផ្អើលខ្លះដែរ នៅពេល ដែលយើងទទួលដំណឹងអំពីការសម្ងាត់ដែលលោកតាលាក់បាំងយ៉ាងជិតនោះ ត្រូវបានខ្ចរខ្ចាយទៅក្រៅៗពីរង្វង់សមាគមយើង ដែលនាំឲ្យពួកយើងម្តងៗមានការខ្មាស់អៀនយ៉ាងខ្លាំង ។ យើងមានការខ្មាស់អៀន ព្រោះថាទោះបីជានៅធ្វើការផ្ទាល់ជាមួយលោកតាក៏ដោយ ក៏មិនបានដឹងរឿងរ៉ាវជំជុំអ្វី ដូចអ្នកនៅក្រៅដែលគេទទួលបានព័ត៌មានសម្ងាត់ៗទាន់ពេលវេលា ។

## លោកតា សឺន សាន និង សម្តេច សីហនុ តាមមាគ៌ាទីទៃៗ

នៅថ្ងៃទី ៨ មេសា ១៩៧៩ សមាគម អា ហ្សេ កា អឺ បានបើកប្រជុំមហាសន្និបាតលើកទី១របស់ខ្លួន ។ លោកតា សឺន សាន បានត្រូវជ្រើសតាំងតាមផ្លូវការជាប្រធានសមាគម លោក នង គឹមនី អតីតរដ្ឋមន្ត្រីជាអនុប្រធាន ឯចំណែកលោកទ្រឿង មាលី ជាអគ្គលេខាធិការ ។ លោក ចាយ ធុល អតីតរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និង រូបខ្ញុំ ត្រូវបានតែងតាំងជាស្នងការគណនេយ្យ[89] ។ សមាគមនេះបន្ត

---

[89] នេត គុណ, សាយ បូរី, សេចក្តីកត់ហេតុនៃការិយាល័យរៀបចំបោះឆ្នោតជ្រើសរើសគណកម្មាធិការនាយកសំរាប់ឆ្នាំ ១៩៧៩-៨០ថ្ងៃទី ៨/៤/៧៩ ។

សកម្មភាពជាធម្មតាគឺ លើកតម្កើងការពារវប្បធម៌ជាតិ ព្រះពុទ្ធសាសនា និង ស្វែងរកជំនួយពីសហគមន៍ខ្មែរនៅប្រទេសបារាំង និង ផ្តល់ជំនួយដល់ជនភៀសខ្លួនខ្មែរដែលទើបមកដល់ថ្មីៗ ។ ក៏ប៉ុន្តែតាមផ្លូវសម្ងាត់វិញ សមាគមនេះ ក៏ចាប់ផ្តើមជ្រើសរើសអ្នកស្ម័គ្រចិត្តឲ្យចូលទៅបំរើក្នុងចលនាតស៊ូរំដោះជាតិដែរ ។

ចំពោះសម្តេច នរោត្តម សីហនុ វិញ ជាដំបូងព្រះអង្គហាក់ដូចជានៅស្ទាក់ស្ទើរក្នុងសកម្មភាពនយោបាយណាមួយ ។ ប៉ុន្តែក្រោយមក ព្រះអង្គក៏ប្តូរព្រះទ័យទៅវិញ ។ ព្រះអង្គប្រហែលជាយល់ឃើញថាកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ (ក.ជ.រ.ប.ខ.) ជាក្រុមឃោជាមួយ ដែលបង្កើតឡើងដោយពួកឧត្តមសេនីយសាធារណរដ្ឋដែលបានទម្លាក់ព្រះអង្គនៅឆ្នាំ ១៩៧០ គឺជាក្រុមដែលមិនអាចឲ្យព្រះអង្គលើកលែងទោសឲ្យបានឡើយ ។ ប្រហែលជាព្រះអង្គទតឃើញថាក្រុមលោកតា សឺន សាន ភាគច្រើនជាអ្នកសាធារណរដ្ឋ ទើបព្រះអង្គមិនឆ្លើយតបតាមសំណើរបស់លោកតា ។ ព្រះអង្គក៏ចាប់ផ្តើមនូវសកម្មភាពមួយចំនួន ។ ពេលនោះ សម្តេចទ្រង់គង់នៅទីក្រុងប៉េកាំងផង និង ទីក្រុងព្យុងយ៉ាងនៃប្រទេសកូរ៉េខាងជើងផង ដែលនៅទីនោះមហាមិត្តរបស់ព្រះអង្គគឺ លោកសេនាប្រមុខ គីម អ៊ីលស៊ុង បានថ្វាយដល់ព្រះអង្គនូវវិមានដ៏ធំស្កឹមស្កៃមួយដើម្បីទ្រង់គង់ប្រថាប់នៅ ។ ការដែលព្រះអង្គសំរេចព្រះទ័យចេញមកធ្វើនយោបាយឡើងវិញ និង ការដែលព្រះអង្គមិនព្រមដឹកនាំកម្លាំងតស៊ូ ដែលមានលោកតា សឺន សាន ជាមេកើយនោះ បានបង្ខំឲ្យសមាជិក អា ហ្សេ កា អឺ ខ្លះ ដែលជាអ្នកសីហនុនិយមដាច់ខាត ឬ ដែលជាសមាជិករាជវង្សានុវង្សដូចជាព្រះអង្គម្ចាស់ក្សត្រី នរោត្តម រដ្ឋរ៉ា បានលាចេញពីសមាគម ។ ដូច្នេះក្រុមរបាំប្រពៃណីនៅទីក្រុងប៉ារីស ក៏បានត្រូវបំបែកជាពីរគឺ មួយជាក្រុមសីហនុនិយម និង មួយទៀតជាក្រុម សឺន សាននិយម ។ រីឯសមាគមខ្មែរមិនមែនកុម្មុយនីស្តនៅប្រទេសបារាំង ក៏បែកជាពីរក្រុមធំៗ ដូចក្រុមរបាំប្រពៃណីនេះដែរ ។

នៅខែ កក្កដា ១៩៧៩ សម្តេច សីហនុ បានផ្ញើសារទី១របស់ព្រះអង្គទៅជូនជនរួមជាតិនៅក្រៅប្រទេស ដោយបានសំដែងនូវការខកព្រះទ័យរបស់ព្រះអង្គចំពោះអង្គការសហប្រជាជាតិ ដែលមិនបានអនុញ្ញាតឲ្យព្រះអង្គទៅថ្លែងក្នុងនាមជនភៀសខ្លួនខ្មែរ និង ដើម្បីឲ្យព្រះអង្គបានថ្លែងអំពីផែនការរបស់ព្រះអង្គសំរាប់អនាគតដើម្បីដោះស្រាយបញ្ហាខ្មែរ ។ ព្រះអង្គបានស្នើពីទីក្រុងព្យុងយ៉ាង តាមសារចុះថ្ងៃទី ១២ កក្កដា ១៩៧៩ ឲ្យបង្កើតជាបន្ទាន់នូវរណសិរ្សរួមខ្មែរដើម្បីសង្គ្រោះជាតិ និង រដ្ឋាភិបាលបណ្តោះអាសន្ននៃកម្ពុជាឯករាជ្យ អព្យាក្រឹត្យ ដែលហៅតាមអក្សរកាត់ជាភាសាបារាំងថា ហ៊្វុកសាណា (FUKSANA: Front Uni Khmer pour le Salut National) និង ហ្គូបប៉ិចស៊ិន (GOUPECIN: Gouvernement Provisoire de l'Etat du Cambodge Indépendant)[90]។ សម្តេចបានស្នើថា ឲ្យសមាគមខ្មែរនៅបរទេសទាំងអស់ ក្លាយជាផ្នែករបស់ហ៊្វុកសាណា (FUKSANA) ហើយឲ្យសមាគមទាំងនោះចាត់តាំងតំណាងរបស់ខ្លួន ទៅចូលរួមក្នុងសមាជជាតិមួយ ដែលនឹងត្រូវរៀបចំឡើងនៅប្រទេសបារាំង ឬ នៅសហរដ្ឋអាមេរិក ។ នៅក្នុងសមាជជាតិនេះ សម្តេច សីហនុ ស្នើជាផ្លូវការដាក់បេក្ខភាពជាប្រធាននៃរណសិរ្ស និង ជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់ ហ្គូបប៉ិចស៊ិន (GOUPECIN) ។ នៅក្នុងសារទី២ នៅថ្ងៃដដែល សម្តេចបានស្នើថាគោលការណ៍ថ្មីនៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាមិនត្រូវយករាជានិយម ឬ សាធារណរដ្ឋទេ ក៏ប៉ុន្តែឲ្យយកយ៉ាងខ្លីត្រឹមតែ"កម្ពុជា" ។ ប្រមុខរដ្ឋនឹងត្រូវហៅថាប្រមុខរដ្ឋនៃកម្ពុជា ហើយដែលត្រូវតែងតាំងឡើងជាផ្លូវការក្រោយការបោះឆ្នោតជាទូទៅមួយ ក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ដោយអ្នកតំណាងរាស្ត្រ និង ព្រឹទ្ធសភា ។ ទង់ជាតិ និង ភ្លេងជាតិត្រូវយកដូច

[90] Norodom Sihanouk (Message du Prince) A Tous Ses Compatriotes A l'Etranger, Pyong-Yang, le 12 juillet 1979.

ទង់ជាតិ និង ភ្លេងជាតិមុនរដ្ឋប្រហារ ១៩៧០ តែភ្លេងជាតិនោះ យកតែវគ្គទី២គឺចាប់ពីប្រាសាទសីលាកំបាំងកណ្ដាលព្រៃ..តែប៉ុណ្ណោះ ។ នៅក្នុងកម្មវិធីនយោបាយរបស់រណសិរ្ស និង រដ្ឋាភិបាលដែលសម្ដេចស្នើនោះ សម្ដេច បានសុំឲ្យមានការគោរពសិទ្ធិមនុស្ស និង ធម្មនុញ្ញអង្គការសហប្រជាជាតិ ព្រមទាំងការគោរពលទ្ធិប្រជាធិបតេយ្យបែបលោកខាងលិចមួយរយភាគរយ ឲ្យមានសេរីភាពក្នុងការធ្វើដំណើរចំពោះអ្នកកាសែតជាតិ និង អន្តរជាតិជាដើម ។ល។ ចំពោះនយោបាយក្រៅប្រទេស សម្ដេចស្នើលើកយកគោលការណ៍បញ្ចសីលា ដោយមានទំនាក់ទំនងល្អ និង សហប្រតិបត្តិការល្អជាមួយប្រទេសទាំងអស់នៅក្នុងពិភពលោក លើកលែងតែជាមួយប្រទេសអ៊ីស្រាអែល និង កូរ៉េខាងត្បូងរបស់លោក ប៉ាក់ ជុងហ៊ី ចេញ ។ នៅក្នុងសារទី២នេះ សម្ដេចបានសុំឲ្យមានការតែងតាំងព្រះអង្គជានាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការបរទេស ហើយប្រសិនបើព្រះអង្គត្រូវបានតែងតាំងតាមសំណើមែននោះ ក្នុងឋានៈព្រះអង្គជានាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការបរទេសព្រះអង្គនឹងចាត់វិធានការផ្នែកការទូត និង តាមផ្លូវមិត្តភាព ដើម្បីសាកល្បងធ្វើឲ្យមានការដកកងទ័ពវៀតណាមចេញពីកម្ពុជា ដោយគ្មានការបង្ហូរឈាមខ្មែរ[91] ។

នៅថ្ងៃជាមួយគ្នានោះដែរគឺ ថ្ងៃទី ១២ កក្កដា ១៩៧៩ សម្ដេច បានផ្ញើសារទី៣របស់ព្រះអង្គអំពាវនាវឲ្យភាគីខ្មែរ ដែលមានជម្លោះខាងផ្លូវអាវុធឲ្យនាំគ្នាទំលាក់អាវុធចោល និង បញ្ឈប់នូវការតស៊ូខាងមនោគមវិជ្ជារបស់ខ្លួន ដោយសម្ដេចបានអញ្ជើញលោក ប៉ុល ពត អៀង សារី និង អ្នកទទួលខុសត្រូវឯទៀតនៃរបបប្រល័យពូជសាសន៍ឲ្យដកខ្លួនដោយសុវត្ថិភាពទៅនៅប្រទេសចិន។ ជាមួយគ្នានោះ សម្ដេច

[91] Norodom Sihanouk (Deuxièm Message du Prince) A Tous Ses Compatriotes A l’Etranger, Pyong-Yang, le 12 juillet 1979.

បានអញ្ជើញក្រុមលោក ហេង សំរិន ឲ្យត្រឡប់ទៅទីក្រុងព្រៃនគរ និង ហាណូយវិញ[92] ។

សមាជិកជាច្រើននៃសមាគម អា ហ្សេ កា អឺ មានការមិនសប្បាយចិត្តចំពោះការផ្តួចផ្តើមគំនិតថ្មីរបស់សម្តេច សីហនុ នេះ ជាពិសេសចំពោះគំនិត បង្កើតរណសិរ្សថ្មី នៅពេលដែលគេបានបង្កើតកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរទៅហើយនោះ ហើយដែលកងទ័ពនេះនឹងត្រូវដឹកនាំតាមផ្លូវនយោបាយដោយរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។ លោកតា សឺន សាន បានឲ្យដឹងថា នៅក្នុងសេចក្តីប្រកាសបង្កើតកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ កងទ័ពនេះបានត្រៀមខ្លួនបំរើឥស្សរជនជាន់ខ្ពស់ខ្មែរមួយរូប ដែលក្នុងន័យនេះ គេចង់និយាយថាត្រៀមខ្លួនបំរើសម្តេច សីហនុ ។ នៅពេលនោះ លោកតា សឺន សាន ដែលជាអតីតរដ្ឋមន្ត្រីទីមួយម្នាក់របស់សម្តេចសីហនុ បានកោះប្រជុំសមាជិក ដើម្បីជជែកពិភាក្សាអំពីសំណើរបស់សម្តេច ។ គំនិតថានឹងចាត់វិធានការផ្នែកការទូត និង ជាផ្លូវមិត្តភាព ដើម្បីសាកល្បងឲ្យទទួលបាននូវការដកកងទ័ពវៀតណាមចេញពីកម្ពុជា ដោយមិនឲ្យមានការបង្ហូរឈាមខ្មែរនោះ បានធ្វើឲ្យក្រុមគ្រួសារលោកតា សឺន សាន និង ក្រុមដែលនៅជុំវិញលោកតាមានការមិនសប្បាយចិត្ត ។ ពួកអ្នកទាំងនោះយល់ថា វិធានការនេះ និង គំនិតនេះគ្រាន់តែជាការរវើរវាយមួយ ដែលមិនអាចក្លាយជាការពិតបានឡើយ ។ ពួកអ្នកទាំងនោះ យល់ថាបើគ្មានការគាបសង្កត់យ៉ាងខ្លាំងខាងផ្លូវយោធាទេនោះ កងទ័ពវៀតណាមប្រាកដជាមិនត្រូវដកចេញពីកម្ពុជាបានឡើយ ។

ទោះបីជាយ៉ាងនោះក្តី សម្តេច សីហនុ នៅតែបន្តផ្ញើសារចេញមកជូនជនរួមជាតិជាបន្តបន្ទាប់ ។ នៅក្នុងសារមួយនោះ ព្រះអង្គស្នើសុំឲ្យមានការតែងតាំងអតីត

---

[92] Norodom Sihanouk (Troisième Message du Prince) A Tous Ses Compatriotes A l’Etranger, Pyong-Yang, le 12 juillet 1979.

ទីប្រឹក្សារបស់ព្រះអង្គគឺលោកតា ញ៉ឹក ជូឡុង និង លោកតា សឺន សាន ជាអ្នកព្រាងលក្ខន្តិកៈកម្មវិធីនយោបាយ សេចក្តីថ្លែងការណ៍ប្រកាសបង្កើតរណសិរ្សរួបរួមជាតិរបស់ព្រះអង្គ ។ សេចក្តីព្រាងទាំងនេះ នឹងត្រូវដាក់ជូនសមាជជាតិអនុម័តនៅពេលខាងមុខ ។ ក៏ប៉ុន្តែព័ត៌មានស្តីពីប្រតិកម្ម ឬ ការមិនសប្បាយចិត្តដែលលេចចេញពីទីក្រុងប៉ារីស ដែលសម្តេចទទួលនៅពេលនោះ បានបង្ហាញថាមិនមានការគាំទ្រដល់ការផ្តួចផ្តើមគំនិតរបស់ព្រះអង្គប៉ុន្មានឡើយ ដែលធ្វើឲ្យព្រះអង្គមិនសប្បាយព្រះទ័យ ។

នៅក្នុងសារទី៨ សម្តេច មានបន្ទូលថាៈ "នៅទីក្រុងប៉ារីសបច្ចាមិត្ររបស់ខ្ញុំគេកំពុងធ្វើការមួលបង្កាច់មកលើរូបខ្ញុំ ដើម្បីធ្វើវិច្ឆេទកម្មលើគំរោងរៀបចំសមាជជាតិ និង ការបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នដែលខ្ញុំបានស្នើ" "ខ្ញុំពុំមានមហិច្ឆតាអ្វីផ្ទាល់ខ្លួនទេ" ។ "ដោយសារមហាមិត្តភាពជាពិសេស ដែលខ្ញុំមានជាមួយសាធារណរដ្ឋប្រជាមានិតចិន ជាមួយលោកប្រធានាធិបតី គីម អ៊ីលស៊ុង ការរស់នៅរបស់ខ្ញុំទាំងផ្លូវកាយទាំងផ្លូវចិត្តទាំងផ្លូវសម្ភារៈគឺ មានភាពសម្បូរសប្បាយជាងកាលទសវត្សរ៍ឆ្នាំ ១៩៥០-១៩៦០ ទៅទៀត" ។ "វាំងរបស់ខ្ញុំនៅព្យុងយ៉ាងមានទំហំប្រាំដង និង មានភាពប្រណិតជាងមហាប្រាសាទខេមរិន្ទទៅទៀត" ។ មហាប្រាសាទខេមរិន្ទជាព្រះរាជដំណាក់នៅក្នុងព្រះបរមរាជវាំងនៅទីក្រុងភ្នំពេញ[93] ។ នៅក្នុងសារទី៩ របស់សម្តេចចុះថ្ងៃទី ២១ កក្កដា ១៩៧៩ សម្តេច សីហនុ បានបង្ហាញពីគោលជំហររបស់ព្រះអង្គខុសពីគោលជំហរលោកតា សឺន សាន គឺព្រះអង្គមានគំរោងបង្កើត និង ដឹកនាំគណបក្សនយោបាយផ្សេងពី លោកតា សឺន សាន នៅក្នុងការបោះ

[93] Norodom Sihanouk (Huitième Message du Prince) A Ses Compatriotes A l'Etranger (undated)?.

ឆ្នោតណាមួយនៅពេលអនាគត[94] ។ នៅទីបំផុតសមាគម អា ហ្សេ កា អឺ បានសំរេចថា នឹងឆ្លើយតបទៅនឹងលិខិតអញ្ជើញរបស់សម្តេច ។

លោកតា សឺន សាន មិនចង់ជាប់ជំពាក់ដោយផ្ទាល់ក្នុងការប៉ះទង្គិចពាក្យសំដីជាមួយសម្តេច សីហនុ ទេ ។ ក៏ប៉ុន្តែកិរិយារបស់លោកតាជាអ្នកប្រឆាំងសម្តេច សីហនុ យ៉ាងខ្លាំងក្លាបំផុតនាសម័យនោះ ។ លោកយាយ សឺន សាន ចាត់ទុកសម្តេច សីហនុ ថាជាអ្នកទទួលខុសត្រូវទាំងស្រុង ចំពោះជោគវាសនារបស់ប្រទេសខ្មែរដែលកំពុងជួបប្រទះនូវវិបត្តិដ៏ធ្ងន់ធ្ងរនៅពេលនោះ ។ លោកយាយបានបន្ទោសសម្តេច សីហនុ ថាព្រះអង្គឋិតនៅក្រោមឥទ្ធិពលនៃមនុស្សនៅជុំវិញមួយចំនួនដែលមានអ្នកម្នាង ម៉ូនិច[95] និង លោកយាយ ប៉ុម ជាមាតាអ្នកម្នាងជាមេកើយ ។ តាមពិតទៅលោកយាយ សឺន សាន មានភក្តីភាពយ៉ាងស្មោះចំពោះម្ចាស់ក្សត្រី នរលក្ខណ៍ ដែលជាព្រះជាយាមួយអង្គទៀតរបស់សម្តេច សីហនុ ។ ផ្ទុយពីអ្នកម្នាង ម៉ូនិច ដែលចេញពីត្រកូលរាស្ត្រសាមញ្ញធម្មតា ព្រះអង្គម្ចាស់ក្សត្រី នរលក្ខណ៍ ប្រសូតចេញពីត្រកូលក្សត្រនៅក្នុងរាជវង្សានុវង្ស ។ម្យ៉ាងទៀតព្រះអង្គម្ចាស់ក្សត្រី នរលក្ខណ៍ បានទទួលសេចក្តីស្រឡាញ់ពេញព្រះរាជហឫទ័យពីសម្តេចមហាក្សត្រីយានី កុសុមៈ ជាព្រះវរាជមាតានៃសម្តេច សីហនុ ។ សម្តេច សីហនុ បានយាងចេញពីព្រះបរមរាជវាំងទៅគង់នៅវិមានចំការមនជាមួយអ្នកម្នាង ម៉ូនិច ប្រហែលតាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៦០ មកម្ល៉េះ ។ ដូច្នេះនៅក្នុងរង្វង់សមាគម ក៏មានអ្នកប្រឆាំង និង អ្នកគាំទ្រសំណើរបស់សម្តេច សីហនុ ឲ្យមានការកោះប្រជុំសមាជជាតិនេះដែរ ។ នៅចុងបំផុត សមាគមបានសំរេចចាត់តាំងសមាជិកក្មេងៗ ឬ យុវសមា

[94] Norodom Sihanouk (Neuvième Message du Prince) A Ses Compatriotes A l'Etranger, Pyong-Yang, le 21 juillet 1979.

[95] នៅសម័យសង្គមរាស្ត្រនិយម សម្តេចម៉ែ សម្តេចយាយ តែងត្រូវបានប្រជាពលរដ្ឋខ្មែរហៅព្រះនាមថាជា អ្នកម្នាងម៉ូនិច ។

ដិកនៃសមាគមជាអ្នកធ្វើលិខិតឆ្លើយតបទៅសម្តេច ។ រូបខ្ញុំត្រូវបានទទួលបន្ទុកតាក់តែងអត្ថបទជាភាសាខ្មែរនៃការឆ្លើយតបនោះ ។

សេចក្តីព្រាងសំបុត្ររបស់ខ្ញុំនោះ បានត្រូវសមាគមអនុម័តទទួលយកទាំងស្រុង ។ នៅក្នុងលិខិតឆ្លើយតបទៅនឹងសម្តេច សីហនុ នោះ ខ្ញុំបានថ្លែងនូវក្តីរំភើបថ្វាយព្រះអង្គ ចំពោះការដែលសម្តេចយកព្រះទ័យទុកដាក់ចំពោះវាសនាជាតិ ទោះបីជាមានឧបសគ្គរាំងស្ទះជាច្រើនយ៉ាងណាក៏ដោយ ។ ខ្ញុំបានគូសបញ្ជាក់នូវសេចក្តីប្តេជ្ញាចិត្តរបស់យើងទាំងអស់គ្នា ក្នុងការរំដោះប្រទេសកម្ពុជាឲ្យចេញពីនឹមយួនឈ្លានពាន ។ ខ្ញុំបានគូសបញ្ជាក់ថែមទៀតនូវសាមគ្គីជាធ្លុងមួយនៃកម្លាំងស្នេហាជាតិទាំងអស់ លើកលែងតែពួកខ្មែរក្រហមចេញគឺ សាមគ្គីភាពនោះហើយដែលអាចធ្វើឲ្យបច្ចាមិត្តមានការភ័យខ្លាច ។ ក្នុងលិខិតនោះ ខ្ញុំផ្តល់មតិថាខ្មាំងសត្រូវកំពុងប្រើល្បិចឲ្យខ្មែរឈ្លោះនឹងខ្មែរគឺ គេធ្វើការបំបែកបំបាក់សាមគ្គីជាតិនោះហើយ ។ លិខិតនោះ[96] ចុះថ្ងៃទី ៨ សីហា ១៩៧៩ មានលោក ទ្រឿង មាលី ជាអ្នកចុះហត្ថលេខាក្នុងនាមជាអគ្គលេខាធិការសមាគម អា ហ្សេ កា អឺ និង ជាតំណាងក្រុមយុវជននៃសមាគមនេះ ដែលមកពីទីក្រុងប៉ារីស ទូលូ លីល ប្រ៉ូវ៉ង់ កូដាហ្ស៊ួរ និងទីក្រុងទួរ ។ លោក ទ្រឿង មាលី នឹងនាំយកលិខិតនេះទៅថ្វាយសម្តេចនៅទីក្រុងព្យុងយ៉ាង និង ទៅចូលរួមសមាជជាតិ ដែលនឹងត្រូវកោះប្រជុំនោះ ។

នៅទីបំផុត សមាជមួយបានត្រូវធ្វើឡើងនៅខែ កញ្ញា ១៩៧៩ នៅប្រទេសកូរ៉េខាងជើង តែមិនមែននៅប្រទេសបារាំង ឬ នៅស.រ.អា ដូចដែលសម្តេច សីហនុ បានគ្រោងក្នុងសាររបស់ព្រះអង្គលើកទី១នោះឡើយ ។ លោក ទ្រឿង មាលី បានធ្វើដំណើរទៅកាន់ទីក្រុងព្យុងយ៉ាង ក្នុងឋានៈជាអ្នកតំណាងសមាគម អា ហ្សេ កា

[96] ទ្រឿង មាលី អគ្គលេខាធិការ ស.ខ.ប. [ទូលថ្វាយសម្តេច នរោត្តម សីហនុ] ប៉ារីសថ្ងៃ ៨ សីហា ១៩៧៩ ។

អឺ ក៏ប៉ុន្តែនៅពេលដែលលោកត្រឡប់មកពីព្យុងយ៉ាងវិញ គាត់ក៏បែកចិត្តពី អា ហ្សេ កា អឺ មកផ្តល់ការគាំទ្រថ្វាយសម្តេច សីហនុ ជាជរាបតមក ។ នៅទីក្រុងព្យុងយ៉ាង សម្តេច សីហនុ មិនបានទទួលជោគជ័យក្នុងការបង្កើតរណសិរ្ស ឬ រដ្ឋាភិបាលបណ្តោះអាសន្នតាមបំណងព្រះអង្គឡើយ ។ សមាជនោះបានត្រូវបញ្ចប់ ដោយគ្រាន់តែមានការបង្កើតនូវសហព័ន្ធមួយឈ្មោះថា សហព័ន្ធខ្មែរអ្នកជាតិនិយម ដែលមានសម្តេច នរោត្តម សីហនុ ជាប្រធាន ។ តាំងពីពេលនោះមក លោក ទ្រឿង មាលី ក៏បានលាឈប់ពីតំណែងអគ្គលេខាធិការសមាគមអា ហ្សេ កា អឺ ដើម្បីមកបំរើចលនាសីហនុនិយមវិញ ។ ដូច្នេះសមាគម អា ហ្សេ កា អឺ ក៏បានជ្រើសរើសលោកបណ្ឌិត ឆាយ ហាន់ចេង កូនប្រសារលោកតា សឺន សាន ឲ្យឡើងកាន់តំណែងជាអគ្គលេខាធិការជំនួសលោក ទ្រឿង មាលី តទៅ ។

## លោកតាប្រកាសបង្កើតរណសិរ្ស

នៅចន្លោះពេលនោះ លោកតា សឺន សាន បានត្រៀមរៀបចំធ្វើដំណើរមកប្រទេសថៃ ។ ដោយមានមនុស្សជំនិតពីរ ឬ បីនាក់ទៅជាមួយផង លោកតាបានចេញដំណើរពីទីក្រុងប៉ារីសជាសម្ងាត់មិនឲ្យពួកយើងដឹងទៀតឡើយ ។ ដោយមានការគាំទ្រពីក្រុមយោធាថៃ លោកតា សឺន សាន ក៏បានសំរេចដូចបំណងក្នុងការបង្កើតជាផ្លូវការនូវរណសិរ្សមួយ ដែលមានឈ្មោះថារណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ "រ.ជ.រ.ប.ខ."[97] ។ រណសិរ្សនេះ ត្រូវបានប្រកាសជាសាធារណៈនៅថ្ងៃទី ៩ តុលា ១៩៧៩ នៅលើទឹកដីខ្មែរជាប់ខេត្តត្រាតនៃប្រទេសថៃនៅលើភ្នំបន្ទាត់ក្នុងភូមិ

[97] Son Sann, Front National du Peuple khmer, Décision No. 79/01/FNL, Territoire Khmer, le 09 Octobre 1979.

មួយឈ្មោះភូមិសុខសាន្ត ដែលឋិតនៅក្រោមការត្រួតត្រារបស់លោកវរសេនីយ ព្រុំ វិត ។

តាមឯកសារផ្លូវការ មានចលនាអ្នកជាតិនិយមចំនួនប្រាំ[98] បានចូលរួមក្នុងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរនេះ ។ ចលនាទាំងប្រាំនោះគឺ៖ ១. រណសិរ្សរួបរួមជាតិរំដោះសាធារណរដ្ឋខ្មែរ ដែលគេស្គាល់ថាជាចលនា រក្សាសម្បុក ដោយមានលោក រក្សា សម្បុក ជាអ្នកដឹកនាំ ២. ចលនាកុកស ៣. ចលនាឃ្លាំងមឿង ៤. ចលនានេនរោង ៥. ចលនាបក្សីចាំក្រុង ។ ឯកសារនោះបានចែងថាមានប្រជាពលរដ្ឋចាត់ឲ្យតំណាងមកពីខេត្ត ១៥ ចូលមករួបរួមបង្កើតជាផ្លូវការនូវរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរនោះ ។ លោកតា សឺន សាន បានត្រូវជ្រើសរើសជាប្រធានឯលោកតា ឈាន វ៉ម ជាអ្នកប្រជាធិបតេយ្យម្នាក់ និង ជាអតីតនាយករដ្ឋមន្ត្រីត្រូវបានជ្រើសរើសជាអនុប្រធាន ។ ភ្លាមៗនោះ រណសិរ្សបានចេញសេចក្តីប្រកាសចំនួនបី ដែលបានទទួលការគាំទ្រពីអ្នកចូលរួមប្រជុំ ។ សេចក្តីប្រកាសទី១ ចែងអំពីការបង្កើតរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ.) ។ សេចក្តីសំរេចទី២ ទទួលស្គាល់កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ ដែលបង្កើតឡើងកាលពីថ្ងៃទី ៥ មីនា ១៩៧៩[99] ឯសេចក្តីសំរេចទី៣ ប្រកាសតែងតាំងឧត្តមសេនីយ ដៀន ដែលជានាយសេនាធិការ[100] ។ រចនាសម្ព័ន្ធរបស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ. ប.ខ.) មានគណៈកម្មាធិការប្រតិបត្តិមួយ ក្រុមប្រឹក្សាជាតិមួយ ក្រុមប្រឹក្សាព្រឹទ្ធាចារ្យមួយ (មនុស្សចាស់ទុំ) និង ក្រុមប្រឹក្សាយោធាមួយ[101] ។

---

[98] Proclaimation of the Khmer People's National Liberation Front, Khmer Teeritory, October 9, 1979

[99] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/02/FNL, Territoire Khmer, le 9 octobre 1979.

[100] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/03/FNL, Territoire Khmer, le 9 octobre 1979.

[101] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/01/FNL, op. cit.

នៅក្នុងសុន្ទរកថា នៃការបង្កើតរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរនោះ លោកតា សឺន សាន បានថ្លែងថា សុខចិត្តទទួលតំណែងជាប្រធានរណសិរ្សក្នុងពេលនេះ[102] ដើម្បីឲ្យរណសិរ្សនោះចាប់ផ្តើមដំណើរការ ក៏ប៉ុន្តែនៅពេលណាមួយដ៏សមស្រប លោកតានឹងស្នើសុំឲ្យមានការតែងតាំងឥស្សរជនដ៏ទៃផ្សេងវិញ ឲ្យមកដឹកនាំចលនាតស៊ូរហូតទទួលជ័យជំនះ ព្រោះថានៅពេលនេះ លោកតាមានអាយុច្រើនណាស់ហើយគឺ ៦៨ ឆ្នាំ ។ លោកតាស្នើនូវគោលការណ៍ចម្បងនៃកម្មវិធីនយោបាយរបស់រណសិរ្សគឺ គោលការណ៍នៃលទ្ធិជាតិនិយម សង្គមនិយមព្រះពុទ្ធសាសនាដោយយកធម៌កណ្តាល អព្យាក្រឹត្យពិតប្រាកដ ឯករាជ្យជាតិ អធិបតេយ្យភាពរបស់ប្រជាពលរដ្ឋ បូរណភាពទឹកដី និង ការរួមរស់ល្អជាមួយអ្នកជិតខាង និងដោយសន្តិភាព ។

នៅទីបំផុតលោកតា សឺន សាន បានធ្វើសេចក្តីអំពាវនាវសូមឲ្យជនរួមជាតិខ្មែរទាំងក្រៅ និង ក្នុងប្រទេសរួបរួមគ្នាដើម្បីប្រមូលផ្តុំកម្លាំងជាតិទាំងអស់ទៅរំដោះជាតិឲ្យរួចផុតពីសត្រូវទាំងឡាយ ដោយមិនត្រូវយកបញ្ហាផ្ទាល់ខ្លួនជាធំឡើយ ។ ចំពោះអង្គការសហប្រជាជាតិ ចំពោះប្រទេសមហាអំណាច និង ចំពោះប្រទេសទាំងឡាយនៅអាស៊ីអគ្នេយ៍ លោកតា សឺន សាន បានអំពាវនាវសុំឲ្យជួយប្រជាពលរដ្ឋខ្មែរឲ្យទាន់ពេលវេលា ដើម្បីឲ្យរួចចាកពីអាណានិគមវៀតណាមខាងជើង ដោយសុំឲ្យមានការកោះប្រជុំនូវសន្និសីទអន្តរជាតិមួយ ដែលប្រទេសអាស៊ានបានស្នើសុំគឺ សន្និសីទមួយដែលមានគោលបំណងបញ្ឈប់ការបាញ់គ្នាជាបន្ទាន់ ដើម្បីឲ្យអង្គការមនុស្សធម៌អន្តរជាតិនាំនូវម្ហូបអាហារ និង ថ្នាំពេទ្យមកជួយដល់កម្ពុជា និង ផ្តល់ដល់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរងគ្រោះ ព្រមទាំងសុំឲ្យកងទ័ពវៀតណាមដកថយចេញពីកម្ពុជា និង ជំនួសដោយកងទ័ពអង្គការសហប្រជាជាតិដើម្បីឲ្យអង្គការសហ

[102] Son Sann, President of the Khmer Pedople's National Liberation Front, Speech, Khmer Territory, October 9, 1979.

ប្រជាជាតិនេះ រៀបចំការបោះឆ្នោតជាទូទៅមួយ ។ នៅទីបញ្ចប់ លោកតា សឺន សាន បានសុំឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសអព្យាក្រិត្យ ។ ចំពោះប្រទេសវៀតណាម និង ប្រទេសលាវ លោកតា សឺន សាន ថ្លែងថា "ពួកវៀតណាមបានលើកទ័ពចូលមកកម្ពុជាដើម្បីជួយរំដោះប្រជាពលរដ្ឋខ្មែរ ឲ្យរួចអំពីរបបសាហាវយង់ឃ្នងរបស់ខ្មែរក្រហម ឥឡូវនេះប្រជាពលរដ្ឋខ្មែរសុំឲ្យវៀតណាមដកកងទ័ពចេញពីកម្ពុជា"[103] ។ "ដោយមានជំនួយពីអង្គការសហប្រជាជាតិ និង ដោយមានជំនួយពីប្រទេសទាំងឡាយដែលស្នេហាសេរីភាព និង សិទ្ធិមនុស្ស ប្រជាពលរដ្ឋខ្មែរនឹងដោះស្រាយបញ្ហាខ្មែរក្រហមដោយខ្លួនឯង បន្ទាប់ពីការដកកងទ័ពរបស់វៀតណាមអស់ពីប្រទេសកម្ពុជា ។ ប្រជាពលរដ្ឋវៀតណាម និង កម្ពុជា ត្រូវនាំគ្នាពន្លត់ភ្លើងកម្មពៀរដែលនាំឲ្យយើងស្អប់ខ្ពើមគ្នាអស់រយៈពេលច្រើនសតវត្សមកហើយ..." ។

ដើម្បីផ្សព្វផ្សាយនូវសេចក្តីប្រកាសបង្កើត រ.ជ.រ.ប.ខ. នេះ លោកតា សឺន សាន បានអញ្ជើញក្រុមសារព័ត៌មានអន្តរជាតិ ដែលមានទីតាំងនៅទីក្រុងបាងកកនៃប្រទេសថៃ ឲ្យចូលមកយកព័ត៌មានផ្ទាល់នៅក្នុងពិធីនោះ ។ ប៉ុន្មានថ្ងៃ ឬ សប្តាហ៍ក្រោយមក ព័ត៌មានស្តីពីការបង្កើតរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរនេះ ក៏បានត្រូវផ្សព្វផ្សាយទូទាំងពិភពលោក ។ នៅទីក្រុងប៉ារីស នៅថ្ងៃទី ១២ តុលា ១៩៧៩ ខ្ញុំក៏បានចូលរួមក្នុងពិធីប្រកាសរណសិរ្សនេះ ដែលរៀបចំឡើងដោយសមាគម អាហ្សេ កា អឺ ។ នៅក្នុងឱកាសនោះ លោក ថុន អ៊ុក អតីតរដ្ឋមន្ត្រី បានធ្វើសន្និសីទសារព័ត៌មានមួយ ក្នុងឋានៈជាអ្នកតំណាងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរនៅក្នុងសណ្ឋាគារមួយឈ្មោះមេរីឌីយែន (Méridienne) ។ លោក ថុន អ៊ុក ផ្សព្វផ្សាយអំពីអំពើប្រល័យពូជសាសន៍របស់ពួកខ្មែរក្រហមទៅលើប្រជាពលរដ្ឋខ្មែរ និង ការលុកលុយរបស់កងទ័ពវៀតណាមខាងជើងចូលមកទឹកដីកម្ពុជាដែលគ្មានគោល

[103] Son Sann, President of the Khmer People's National Liberation Front, Speech, op. cit.

បំណងអ្វីក្រៅពីលេបយកទឹកដីខ្មែរទាំងមូលឡើយ ។ សន្និសីទសារព័ត៌មាននោះបានត្រូវបណ្តាញសារព័ត៌មានបារាំងជាច្រើនយកទៅផ្សាយបន្ត ។ សរុបសេចក្តីទៅការផ្សព្វផ្សាយនេះ ជាជោគជ័យផ្នែកទំនាក់ទំនងសាធារណៈរបស់លោកតា សឺន សាន និង រ.ជ.រ.ប.ខ. ។ សូមបញ្ជាក់ថា នៅសម័យនោះ រ.ជ.រ.ប.ខ. មានលក្ខណៈគួរឲ្យទុកចិត្តបានជាងសហព័ន្ធខ្មែរអ្នកជាតិនិយមរបស់សម្តេច នរោត្តម សីហនុ ដែលបានបង្កើតក្នុងខែ កញ្ញា ១៩៧៩ នៅប្រទេសកូរ៉េខាងជើង ។ ផ្ទុយពីសហព័ន្ធអ្នកជាតិនិយមខ្មែររបស់សម្តេច សីហនុ រ.ជ.រ.ប.ខ. បានត្រូវបង្កើតឡើងនៅលើទឹកដីខ្មែរ ហើយបានប្រមូលផ្តុំអ្នកតស៊ូពិតប្រាកដមែនទែនដែលឋិតនៅក្រោមបញ្ជារបស់ឧត្តមសេនីយម្នាក់ដែលមានគេស្គាល់ច្រើននៅក្នុងរបបសាធារណរដ្ឋ ។ បន្ថែមលើនេះ លោកតា សឺន សាន កាលសម័យនោះ ត្រូវបានគេមើលឃើញថា ជាមនុស្សមិនបានជាប់ជំពាក់ក្នុងរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ក្នុងឆ្នាំ ១៩៧០ ។ ម្យ៉ាងទៀត លោកតា សឺន សាន ក៏ពុំបានជាប់ជំពាក់ក្នុងការជួយជ្រោមជ្រែងឲ្យខ្មែរក្រហមឡើងមកកាន់អំណាចនៅឆ្នាំ ១៩៧៥ ដែរ ។ ឆ្នាំទី១នៃកំណើត រ.ជ.រ.ប.ខ. បានត្រូវទទួលស្គាល់ដោយសារការប្រមូលនូវការគាំទ្រជាច្រើន ពីសហគមន៍ខ្មែរនៅក្រៅប្រទេសទូទាំងពិភពលោក ។

ក៏ប៉ុន្តែលោកតា អ៊ិន តាំ ដែលជាមេដឹកនាំម្នាក់ក្នុងរដ្ឋប្រហារ ១៩៧០ ទម្លាក់សម្តេច សីហនុ និង ជាសមាជិកស្ថាបនិកម្នាក់របស់សមាគម អា ហ្សេ កា អឺ បានចាកចេញពីសមាគមនេះ ទៅចូលរួមជាមួយសម្តេច សីហនុ ។ លោកតា អ៊ិន តាំ មិនសប្បាយចិត្តនឹងការតែងតាំងឧត្តមសេនីយ ដៀន ដែល ឲ្យធ្វើជាអ្នកដឹកនាំកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។ លោកតា អ៊ិន តាំ តវ៉ាថា លោកតា សឺន សាន មិនបានគោរពតាមពាក្យសន្យា ដែលថានឹងតែងតាំងគាត់ឲ្យដឹកនាំកងទ័ពតាំងពីកាលជួបចរចាគ្នា ដើម្បីបង្កើតសមាគម អា ហ្សេ កា អឺ មកម្ល៉េះ ។ លោកតា សឺន

សាន បានសារភាពថាបានសន្យាថានឹងតែងតាំងលោក អ៊ិន តាំ ជាអគ្គមេបញ្ជាការនៃកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ (ក.ជ.រ.ប.ខ.) ។ នៅពេលនេះ លោកតាបានតែងតាំងលោកឧត្តមសេនីយ ដៀន ដែល ធ្វើត្រឹមតែនាយសេនាធិការនៃកងទ័ពតែប៉ុណ្ណោះ មិនមែនជាអគ្គមេបញ្ជាការទេ ។ ដោយសារការមិនយល់គ្នានេះ លោកតា អ៊ិន តាំ ក៏បានបែកចេញពីលោកតា សឺន សាន ហើយបានទៅចូលរួមបំរើសម្តេច សីហនុ ដើម្បីរៀបចំកងទ័ពសីហនុនិយមមួយតាំងពីពេលនោះរៀងមក ។

នៅថ្ងៃទី ១៥ តុលា ១៩៧៩ លោកតា សឺន សាន បានចេញក្រឹត្យជាផ្លូវការបង្កើតនូវស្ថាប័នមួយចំនួន ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងរដ្ឋាភិបាលដ៏តូចមួយដែរ[104] ។ ស្ថាប័នទី១នោះគឺ គណៈកម្មាធិការប្រតិបត្តិហៅកាត់ជាអក្សរបារាំង (COMEX) ។ គណៈកម្មាធិការប្រតិបត្តិនេះ ជាអ្នកទទួលខុសត្រូវលើការងារសំខាន់ៗដូចជាការងារផ្នែកនយោបាយ ការទូត និង រដ្ឋបាល ។ សមាជិកនៃគណៈកម្មាធិការម្នាក់ៗ មានក្រសួងដែលស្ថិតនៅក្នុងអំណាចក្នុងរង្វង់តួនាទីរបស់ខ្លួន ។ នៅពេលនោះ រណសិរ្សបានបង្កើតក្រសួងចំនួនប្រាំពីរនៃគណៈកម្មាធិការប្រតិបត្តិ ដែលមានសមាជិកប្រាំពីររូបជាអ្នកទទួលខុសត្រូវ ។ ក្រសួងទាំងប្រាំពីរនោះគឺ៖ ១. ក្រសួងមហាផ្ទៃ ២. ក្រសួងការបរទេស ៣. ក្រសួងកិច្ចការយោធា ៤. ក្រសួងវប្បធម៌ និង សាសនា ៥. ក្រសួងហិរញ្ញវត្ថុ និង អភិវឌ្ឍន៍ ៦. ក្រសួងព័ត៌មាន និង ឃោសានាការ ៧. ក្រសួងយុត្តិធម៌ ។ នៅពេលនោះដែរ លោកតា សឺន សាន បាន តែងតាំងសមាសភាពនៃគណៈកម្មាធិការប្រតិបត្តិដូចតទៅ៖[105] ១. លោកតា ឈាន វ៉ម ជាអនុប្រធាន ២. លោក នាង ជិនហន

---

[104] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/04/FNL, Territoire Khmer, le 15 octobre 1979.

[105] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/05/FNL, Territoire Khmer, le 15 octobre 1979.

ជាអគ្គលេខាធិការ ៣. លោក ដៀន ដែល ជាសមាជិកទទួលបន្ទុកកិច្ចការយោធា ៤. អ៊ឹម ឈូ ដេត ទទួលបន្ទុកក្រសួងមហាផ្ទៃ ៥. លោក ព្រុំ វិត ទទួលបន្ទុកកិច្ចការសង្គមកិច្ច វប្បធម៌ និង សាសនា ៦. លោក ងួន ពីទូរ៉េត ទទួលបន្ទុកខាងព័ត៌មានឃោសនាការ និង អតីតយុទ្ធជន ។ ចំណែកលោកស្រី សួន កាសេត លោក សឺន ស៊ូប៊ែរ្ត ដែលជាកូនប្រុសច្បងរបស់លោកតា សឺន សាន និង លោក សឺន មុនា កូនប្រុសម្នាក់ទៀត បានទទួលការតែងតាំងជាអ្នកទទួលបន្ទុកផ្នែកបេសកកម្មពិសេសរបស់គណៈកម្មាធិការប្រតិបត្តិ[106] ។

# ខ្ញុំជាសកម្មជន រ.ជ.រ.ប.ខ.

ជាមួយនឹងការកកើតនៃ រ.ជ.រ.ប.ខ. សមាគម អា ហ្សេ កា អឺ បានក្លាយទៅជាទីស្នាក់ការទីពីររបស់រណសិរ្សនេះ នៅទីក្រុងប៉ារីសប្រទេសបារាំង ជាទីដែលលោកតា សឺន សាន ស្នាក់នៅម្តងៗក្នុងចន្លោះនៃការស្នាក់អាស្រ័យរបស់លោកតានៅតាមទល់ដែនខ្មែរ-ថៃ និង ក្នុងទីក្រុងបាងកក ។ គឺនៅទីក្រុង ប៉ារីសនេះហើយ ដែលលោកតា សឺន សាន អាចផ្តួចផ្តើមគំនិតការទូតអ្វីមួយ ឬ សកម្មភាពនយោបាយថ្មីអ្វីមួយ ។ ដូចនេះ សមាគម អា ហ្សេ កា អឺ ក៏បានក្លាយជាសាខាមួយរបស់ រ.ជ.រ.ប.ខ. ប្រចាំទ្វីបអឺរ៉ុប ។ ចាប់ពីពេលនោះតមក ខ្ញុំមិនមែនគ្រាន់តែធ្វើការឲ្យតែសមាគមមួយមុខនោះទេគឺ ខ្ញុំមានការងារធ្វើកាន់តែច្រើនឡើងថែមទៀត ។ ខ្ញុំធ្វើការឲ្យ រ.ជ.រ.ប.ខ. ក្នុងឋានៈជាអ្នកឃោសនាដ៏សកម្មម្នាក់ផង ។ ខ្ញុំធ្វើដំណើរដោយមិនខ្លាចនឿយហត់ទូទាំងប្រទេសបារាំងរួមជាមួយ លោកបណ្ឌិត ឆាយ ហាន់ចេង ក្នុងការប្រឹងប្រែងស្វែងរកការគាំទ្រ ពីសំណាក់អាណិកជនខ្មែររស់នៅ

[106] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/06/FNL, Territoire Khmer, le 15 octobre 1979.

ប្រទេសបារាំងឲ្យដល់ រ.ជ.រ.ប.ខ. ។ ជាញឹកញាប់ខ្ញុំតែងយករូបថត រូបស្លាយ ឬ ខ្សែភាពយន្តដែលផ្ញើតាមត្រង់ពីទីក្រុងបាងកក និង ដែលភាគច្រើនគ្មានចំណង ជើង ឬ បទពន្យល់អ្វីទាំងអស់ មកធ្វើអត្ថាធិប្បាយដោយបញ្ចូល សម្លេង និង ភ្លេង កំដរតាមការយល់ដឹងផ្ទាល់របស់ខ្ញុំ ។ ជួនកាលខ្ញុំត្រូវធ្វើអត្ថាធិប្បាយលើរូបភាព ដែលខ្ញុំមិនបានដឹងន័យពិតប្រាកដផង ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំបាន ខិតខំកែលំអធ្វើឲ្យការផ្សព្វផ្សាយ ឬ ការបញ្ចាំងភាពយន្តទាំងនោះ មានលក្ខណៈ អាជីព ដែលធ្វើឲ្យអ្នកចូលរួមមានការពេញចិត្តជានិច្ច ។ ខ្ញុំបានបញ្ចូលសម្លេងរបស់ ខ្ញុំក្នុងខ្សែភាពយន្តឯកសារទំហំ ១៦ ម.ម.មួយ ដោយមានអមដោយភ្លេងពិណពាទ្យ និង បទអត្ថាធិប្បាយប្រកបដោយខ្លឹមសារប្រវត្តិសាស្ត្រ និង បន្លឺសម្លេងឡើងចុះ ដែលធ្វើឲ្យអ្នកទស្សនាមានក្តីរំភើបយ៉ាងខ្លាំង ។ ចំពោះអាណិកជនខ្មែររស់នៅ ប្រទេសបារាំង ដែលបានទស្សនាខ្សែភាពយន្តនោះ ពួកគេតែងទន្ទឹងរង់ចាំដំណឹង នានាពីប្រទេសខ្មែរ ។

ខ្សែភាពយន្តឯកសាររបស់ខ្ញុំនោះ ធ្វើឲ្យមនុស្សចាស់ៗទប់ទឹកភ្នែកមិនបាន ចង់វិលទៅស្លាប់នៅស្រុកខ្មែរវិញ ។ អ្នកខ្លះនឹកស្រុកខ្លាំងពេក ក៏កើតមានសេចក្តី ស្នេហាជាតិមួយកំរិតថែមទៀត ។ តាមរយៈរូបភាពក្នុងខ្សែភាពយន្ត គេអាចមើល ឃើញក្តីលំបាកវេទនារបស់យុទ្ធជន រ.ជ.រ.ប.ខ. និង ប្រជាពលរដ្ឋ ដែលរស់នៅក្នុង តំបន់កាន់កាប់ដោយ រ.ជ.រ.ប.ខ. នេះ ។ គេអាចមើលឃើញរូបភាពរបស់លោកតា សឺន សាន ដែលទៅធ្វើទស្សនកិច្ចនៅក្នុងតំបន់ទាំងនោះ ។ រូបលោកតាហាក់ដូច ជាស្គមស្គាំង ដែលអាចឲ្យអ្នកមើលយល់ថាលោកតាប្រហែលជារស់នៅជាប្រចាំក្នុង តំបន់នោះពិតប្រាកដមែន ។ យើងទាំងអស់គ្នាគោរពលោកតា ចំពោះសេចក្តីក្លា ហាន និង ស្មារតីលះបង់ខ្ពស់របស់លោកតា ដែលសុខចិត្តចូលមកធ្វើការដឹកនាំ ចលនាតស៊ូ ក្នុងវ័យចំណាស់ទៅហើយ ។ មែនទែនទៅ នៅសម័យនោះ យើងមិន

ដែលគិតថា លោកតារស់នៅឯទីក្រុងបាងកកម្ដងណាទ្បើយ ។ តាមពិតពួកយើងទទួលព័ត៌មានបន្តិចបន្តួច ពីរណសិរ្សតែតាមរយៈបណ្ឌិត ឆាយ ហាន់ចេង តែប៉ុណ្ណោះ ។ លោក ឆាយ ហាន់ចេង ជាប្រធានផ្នែកព័ត៌មាន ដែលជាអ្នកចាត់ចែងតែម្នាក់គត់ក្នុងការចំរាញ់ និង ជ្រើសរើសព័ត៌មាន តើព័ត៌មានណាអាចត្រូវប្រាប់អ្នកណាម្នាក់អំពីសកម្មភាពរបស់ រ.ជ.រ. ប.ខ. ។

នៅក្នុងសមាគម អា ហ្សេ កា អឺ ឬ នៅក្នុង រ.ជ.រ.ប.ខ. នៅប្រទេសបារាំង លោកបណ្ឌិត ឆាយ ហាន់ចេង កាន់តែមានតួនាទីសំខាន់ទ្បើង ដោយសារតែគ្រប់គ្រងបានព័ត៌មានទាំងអស់ទាក់ទងនឹង រ.ជ.រ.ប.ខ. ។ សមាជិកសកម្មមួយចំនួនបន្ទោសថា គាត់មិនបាននិយាយការពិតនៅពេល ដែលលោកតា សឺន សាន និង កូនពីរនាក់គឺ លោក សឺន ស៊ូប៊ែរ្ត៍ លោក សឺន មុនា ព្រមដោយលោកស្រី សួន កាសេត និង លោក នាង ជិនហាន ធ្វើដំណើរចេញពីទីក្រុងប៉ារីសទៅប្រទេសថៃ ។ សមាជិកមួយចំនួនទៀតនឹកគិតថាការ ដែលគេមិនឲ្យដឹងព័ត៌មានសំខាន់ៗ ទាំងនោះប្រហែលជាដោយសារក្រុមលោកតា សឺន សាន មិនទុកចិត្ត ទោះបីជាពួកគេខិតខំបំរើសមាគម អា ហ្សេ កា អឺ និង រ.ជ.រ.ប.ខ. យ៉ាងណាក៏ដោយ ។ សមាជិកទាំងនោះយល់ថា ពួកគេគួរតែបានដឹងព័ត៌មានទាំងនោះ ព្រោះយ៉ាងហោចណាស់ពួកគេអាចទៅជូនដំណើរលោកតា សឺន សាន និង កូនចៅគាត់នៅឯព្រលានយន្តហោះផងដែរ ។ សមាជិកទាំងនោះជឿថា ការចេញដំណើរទាំងនោះគឺជាបេសកកម្មស្នេហាជាតិ ដូច្នេះពួកគេគួរតែទៅជូនដំណើរជាកិត្តិយស ។ ចំពោះខ្ញុំនៅគ្រាដំបូងខ្ញុំក៏មានអារម្មណ៍យ៉ាងដូច្នេះដែរ ព្រោះថាខ្ញុំមិនដែលបានដឹងឮផ្ទាល់អំពីការងារសំខាន់ៗសោះទ្បើយ ។ ក៏ប៉ុន្តែ បន្តិចម្ដងៗខ្ញុំចេះតែនឹកថាបញ្ហាទាំងអស់នោះទាក់ទងទៅនឹងសន្តិសុខ និង សុវត្ថិភាពរបស់អ្នកចេញទៅតស៊ូ ព្រោះកិច្ចការទាំងអស់នេះ អាចប៉ះពាល់ដល់អាយុជីវិតអ្នកទាំងនោះផង ។ យ៉ាងនោះហើយ

ទើបខ្ញុំបានរំសាយចិត្តមួហ្មងទាំងនោះ ហើយក៏ទទួលយកគំនឹតថានេះ ជាការងារចាត់ចែងធម្មតារបស់ថ្នាក់ដឹកនាំតែប៉ុណ្ណោះ ។ ចំណុចនេះគួសបង្ហាញពីរបៀបរបបធ្វើការរបស់លោកតា សឺន សាន ដែលមានភាពអត្តនោម័ត និង ដែលជាកត្តានាំឲ្យមានការមិនយល់ មិនទុកចិត្តគ្នានៅក្នុងចលនា សឺន សាននិយមនេះរហូតមក ។

# ព្រះអង្គទាមទារចរចាផ្ទាល់ជាមួយវៀតណាម

នៅចន្លោះពេលនោះ ខ្ញុំក៏បានដំណឹងពីសារព័ត៌មានបារាំងដែរថា សម្តេចនរោត្តម សីហនុ ក្នុងឋានៈព្រះអង្គជាប្រធានសហព័ន្ធខ្មែរអ្នកជាតិនិយម បានផ្ញើសារមួយច្បាប់ពីដំណាក់របស់ព្រះអង្គ នៅទីក្រុងព្យុងយ៉ាងនៃប្រទេសកូរ៉េខាងជើងទៅជូនលោកនាយករដ្ឋមន្ត្រីវៀតណាមខាងជើង ផាំ វ៉ាន់ដុង ដើម្បីស្នើឲ្យវៀតណាមធ្វើការចរចាផ្ទាល់ជាមួយព្រះអង្គ ក្នុងន័យនាំមកប្រទេសកម្ពុជាវិញនូវឯករាជភាព និង អព្យាក្រឹតភាព ។ តាមឯកសាររបស់ព្រះអង្គដែលបានផ្សព្វផ្សាយជាសាធារណៈនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ថាកាលនោះនៅឆ្នាំ ១៩៧៩ សម្តេច សីហនុ បានផ្ញើសារ ៣ ច្បាប់ ទៅជូនលោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុងគឺៈ សារទី១ ចុះថ្ងៃទី ៧ តុលា សារទី២ ចុះថ្ងៃទី ២៣ តុលា និង សារទី៣ ចុះថ្ងៃទី ១១ វិច្ឆិកា ១៩៧៩ ។ នៅក្នុងសារចុះថ្ងៃទី ៧ តុលា ១៩៧៩ សម្តេចបានរំលឹកមេដឹកនាំវៀតណាមអំពីជំនួយច្រើនរូបភាព ដែលព្រះអង្គបានផ្តល់ដល់ការតស៊ូរបស់ប្រជាជនវៀតណាមក្នុងសង្គ្រាមប្រឆាំងចក្រពត្តិអាមេរិក នាសម័យដែលទ្រង់កាន់អំណាចដូចជាៈ ការផ្តល់ទីជំរកសម្រាប់ឈប់សម្រាក និង ព្យាបាលអ្នករបួស ឬ អ្នកជម្ងឺព្រមទាំងការអនុញ្ញាតឲ្យប្រើប្រាស់កំពង់ផែព្រះសីហនុ ដើម្បីដឹកជញ្ជូនអាវុធយុទ្ធភណ្ឌ

ដល់កងទ័ពវៀតកុងជាដើម ។ ជំនួយទាំងនេះ នាំឲ្យប្រទេសកម្ពុជាត្រូវទទួលការចោទប្រកាន់ថាបានបោះបង់ចោលអព្យាក្រឹតភាពរបស់ខ្លួន ហើយត្រូវទទួលរងនូវការវាយប្រហារតាមជើងគោក និង តាមផ្លូវអាកាសពីកងទ័ពអាមេរិក និង វៀតណាមខាងត្បូង រហូតដល់កើតមានរដ្ឋប្រហារថ្ងៃ ១៨ មីនា ១៩៧០ ។

ក្នុងសាររបស់ព្រះអង្គនោះសម្តេច សីហនុ ស្នើសុំឲ្យមេដឹកនាំវៀតណាមធ្វើការចរចាជាមួយព្រះអង្គ ដើម្បីកសាងឡើងវិញនូវឯករាជ្យ និង អព្យាក្រឹតភាពនៃកម្ពុជា និង ដើម្បីឲ្យមានឡើងវិញនូវទំនាក់ទំនងដ៏រាក់ទាក់ និង ប្រកបដោយផ្លែផ្កា រវាងកម្ពុជា និង វៀតណាម និង រវាងប្រជាជនទាំងពីរ ។ សម្តេចបន្ថែមថា ព្រះអង្គមិនដាក់លក្ខខណ្ឌអ្វីទេគឺ អាចជួបគ្នានៅទីក្រុងហាណូយក៏បាន នៅទីក្រុងព្យុងយ៉ាងក៏បាន ឬ នៅទីក្រុងប្រាកក៏បាន ។ សម្តេច សីហនុ បញ្ជាក់ថាព្រះអង្គជាអ្នកដឹកនាំខ្មែរតែមួយគត់ ដែលបានប្រជាជនខ្មែរទាំងមូលទទួលស្គាល់ ហើយព្រះអង្គក៏ជាអ្នកតំណាងខ្មែរស្នេហាជាតិទាំងអស់ផងដែរ ។ សម្តេច សីហនុ ព្រមានថានឹងមានផលអាក្រក់ដ៏ធ្ងន់ធ្ងរ ប្រសិនបើអ្នកដឹកនាំវៀតណាម មិនព្រមចាប់ដៃចរចាជាមួយព្រះអង្គទេនោះ ។

នៅថ្ងៃ ២៣ តុលា ដដែល សម្តេច ទ្រង់ផ្ញើសារមួយទៀត ទៅជូនលោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ ដុង ។ នៅក្នុងសារទី២នេះ ព្រះអង្គរំលឹកនូវខ្លឹមសារនៃសារមុន ក៏ប៉ុន្តែសម្តេចតវ៉ាថា មិនត្រឹមតែមិនបានទទួលចម្លើយពីលោកនាយករដ្ឋមន្ត្រីប៉ុណ្ណោះទេ ឯកអគ្គរដ្ឋទូតវៀតណាម ថែមទាំងបានថ្លែងនៅចំពោះមុខអ្នកកាសែតអាមេរិក តាមរយៈសន្និសីទកាសែតនៅទីក្រុងប៉េកាំងថា ព្រះអង្គគ្រាន់តែជា "បុគ្គលឯកជនម្នាក់" ហើយដែលរដ្ឋាភិបាលទីក្រុងភ្នំពេញបានផ្តន្ទាទោសថាជា "សត្រូវនៃប្រជាជនខ្មែរ" ទៀតផង ។ នៅក្នុងសារទី៣ ចុះថ្ងៃទី ១១ វិច្ឆិកា ១៩៧៩ សម្តេចចោទសួរថាតើសារលើកនេះនឹងនៅតែគ្មានចម្លើយទៀត ឬ យ៉ាងណា? ព្រះអង្គនៅ

តែទទូចឲ្យមានការចរចាគ្នារវាងវៀតណាម និង ព្រះអង្គ ដែលជារដ្ឋបុរសមានការទទួលខុសត្រូវ បើពុំដូច្នោះទេ សម្ដេចព្រមានថា ព្រះអង្គនឹងត្រូវបង្ខំព្រះទ័យធ្វើការតស៊ូរំដោះជាតិរហូតដល់ទីបំផុត ។ ទាំងសារទី១ ទាំងសារទី២របស់ព្រះអង្គ ពុំបានទទួលចម្លើយណាមួយឡើយ ពីលោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ ដុង នៃប្រទេសវៀតណាម ។ ចំណែកឯសារទី៣ បានត្រូវផ្ញើត្រឡប់មកវិញ ដោយមិនទាំងត្រូវបើកស្រោមផង ។ ដូច្នេះ បំណងរបស់សម្ដេច ក្នុងការស្វែងរកការចរចាក៏ពុំបានសម្រេចដូចក្ដីប្រាថ្នារបស់ព្រះអង្គ ។ ប្រហែលជាដោយសារមេដឹកនាំវៀតណាមមិនបានយកចិត្តទុកដាក់ចំពោះព្រះអង្គបែបនេះហើយ ទើបនៅទីបំផុតសម្ដេច សីហនុ សម្រេចបង្កើតកងទ័ព និង រណសិរ្សរំដោះជាតិផ្ទាល់របស់ព្រះអង្គ មុននឹងចូលរួមជាថ្មីម្ដងទៀតជាមួយខ្មែរក្រហមក្នុងរដ្ឋាភិបាលចម្រុះត្រីភាគីនាឆ្នាំ ១៩៨២ ។

## សម្ដេច សីហនុ យាងមកដល់ទីក្រុងប៉ារីស

នៅថ្ងៃ ២៥ វិច្ឆិកា ១៩៧៩ សម្ដេចបានយាងមកដល់ទីក្រុងប៉ារីស ដែលព្រះអង្គគ្រោងថានឹងគង់ប្រថាប់នៅក្នុងរយៈពេលបីខែ ។ សម្ដេចត្រូវបានទទួលបដិសណ្ឋារកិច្ចពីរដ្ឋាភិបាលបារាំងក្នុងឋានៈជាមិត្តម្នាក់របស់ប្រទេសបារាំង ។ នៅពេលយាងមកដល់ទីក្រុងប៉ារីសសម្ដេចក៏ធ្វើដូចលោកតា សឺន សាន ដែរគឺបានថ្លែងអំពាវនាវឲ្យខ្មែរអ្នកជាតិនិយមទាំងអស់ ត្រូវខិតខំធ្វើយ៉ាងណាឲ្យគេទទួលស្គាល់ថាខ្មែរអ្នកជាតិនិយមជាក្រុមដ៏ហ្មត់ចត់បំផុត ។ ព្រះអង្គថ្លែងថា "យើងត្រូវតែធ្វើឲ្យគេមានទំនុកចិត្តដល់ក្រុមខ្មែរអ្នកជាតិនិយម" "ទាំងនេះគឺ ជាគោលបំណងរបស់ខ្ញុំក្នុងការស្នាក់អាស្រ័យរយៈពេល ៣ ខែ នៅប្រទេសបារាំងនេះ" ។ "ខ្ញុំជឿថា ខ្ញុំនឹងសំរេចគោលដៅនេះ"។ នៅក្នុងសេចក្ដីអំពាវនាវរបស់ព្រះអង្គនោះ សម្ដេចថ្លែងថា៖

"ជនរួមជាតិជាច្រើន បានទទូចសុំឲ្យខ្ញុំលះបង់ចោលនូវការរស់នៅក្រៅប្រទេសរបស់ខ្ញុំ ដើម្បីចូលរួមជាមួយពួកគេក្នុងកិច្ចប្រតិបត្តិការជួយសង្គ្រោះប្រជាជាតិយើង ដែលកំពុងឋិតនៅក្នុងមហន្តរាយ តែខ្ញុំសូមបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំមិនមែនមកទីក្រុងប៉ារីសនេះ ដើម្បីដណ្តើមតំណែងដឹកនាំណាមួយឡើយ ខ្ញុំគ្រាន់តែជាអ្នកស្នេហាជាតិម្នាក់ ដែលនឹងខិតខំគ្រប់បែបយ៉ាងជាមួយនឹងអ្នកស្នេហាជាតិឯទៀត និងប្រជាពលរដ្ឋខ្មែរ ដើម្បីបំពេញករណីយកិច្ច ដែលខ្មែរអ្នកស្នេហាជាតិម្នាក់ៗត្រូវបំពេញ" ។ សម្តេច សីហនុ គូសបញ្ជាក់ថា សហព័ន្ធខ្មែរអ្នកជាតិនិយមរបស់ព្រះអង្គកំពុងអនុវត្តនយោបាយសហការគ្នាល្អជាមួយអង្គការទាំងឡាយណា ដែលមិនមែនជាសមាជិកសហព័ន្ធ (ទាំងនោះរួមទាំងចលនា រ.ជ.រ.ប.ខ. របស់លោកតា សឺន សាន ផង) នៅក្នុងគោលការណ៍ដ៏ពិសិដ្ឋសំរាប់ជួយសង្គ្រោះជាតិ ។

## បានទទួលដំណឹងពីម្តាយខ្ញុំ

ទស្សនកិច្ចរបស់អតីតព្រះរាជា និង ព្រះប្រមុខរដ្ឋខ្មែរនោះបានលើកទឹកចិត្តយ៉ាងខ្លាំងក្លាដល់អ្នកគាំទ្ររបស់ព្រះអង្គនៅប្រទេសបារាំង ។ ក៏ប៉ុន្តែចំពោះខ្ញុំ ក៏ដូចជាអ្នកគាំទ្រលោកតា សឺន សាន មួយចំនួនដែរ វត្តមានរបស់សម្តេចនៅប្រទេសបារាំងមិនបានធ្វើឲ្យយើងផ្លាស់ប្តូរគោលជំហរ បែកចិត្តរាយមាយ ឬ មានភាពឃ្លេងឃ្លោងនៅក្នុងសតិអារម្មណ៍ឡើយ ។ ក៏ប៉ុន្តែ អ្វីដែលកន្ត្រាក់អារម្មណ៍ខ្ញុំឲ្យញាប់ញ័ររំភើបនោះគឺ សំបុត្រមួយច្បាប់ដែលខ្ញុំបានទទួលពីប្រទេសថៃ ។ សំបុត្រនោះ បានមកដល់ចំពេលនៃទស្សនកិច្ចរបស់សម្តេច សីហនុ នៅប្រទេសបារាំងតែម្តងគឺ ជាសំបុត្ររបស់បងថ្លៃស្រីខ្ញុំឈ្មោះ ទេពធីតា ភរិយាបងប្រុសទីពីររបស់ខ្ញុំ ដែលទើបតែធ្វើដំណើរមកដល់ជំរុំជាយដែនខ្មែរ-ថៃ ។ បងស្រីទេពធីតា មិនមានអាស័យដ្ឋាន

ថ្មីរបស់ខ្ញុំនៅទីក្រុងស្តាំងនោះទេ ក៏ប៉ុន្តែគាត់ផ្ញើសំបុត្រទៅអាស័យដ្ឋានចាស់នៅទីក្រុងប៉ារីស ដោយគ្រាន់តែសរសេរឈ្មោះផ្លូវ គ្មានដាក់លេខផ្ទះទេថា "អៀង មូលី ផ្លូវមូឡាំងវែរ (Moulin Vert Paris France)" ។ ជាសំណាងល្អ និង ដោយសារប្រព័ន្ធប្រៃសណីយនៃប្រទេសបារាំងដំណើរការល្អ និង មានប្រសិទ្ធភាពខ្ពស់ សំបុត្រនោះក៏ត្រូវបានបញ្ជូនទៅអាស័យដ្ឋានថ្មីរបស់ខ្ញុំ នៅឯទីក្រុងស្តាំង ។ គួរបញ្ជាក់ថាមុននឹងរើមកនៅទីក្រុងស្តាំងនោះ ខ្ញុំបានទៅចុះឈ្មោះប្រាប់អាស័យដ្ឋានថ្មីរបស់ខ្ញុំ នៅឯមន្ទីរប្រៃសណីយចាស់នៅទីក្រុងប៉ារីស ។ ហេតុដូច្នេះហើយ ទើបគេអាចបញ្ជូនសំបុត្រនោះ ទៅអាស័យដ្ឋានថ្មីរបស់ខ្ញុំបាន ។ បងស្រី ទេពធីតា សរសេរសំបុត្រយ៉ាងខ្លី ប្រហែលជាគាត់ស្ថិតនៅក្នុងភាពប្រញាប់ប្រញាល់ ។ ក៏ប៉ុន្តែ គាត់បានរៀបរាប់អំពីទុក្ខវេទនារបស់ប្រជាពលរដ្ឋយើង និង អំពីមរណភាពឪពុកខ្ញុំក្នុងខែធ្នូ ១៩៧៥ ព្រមទាំងការបាត់បង់ជីវិតរបស់បងប្អូនខ្ញុំបួននាក់ទៀតនៅក្នុងឆ្នាំ ១៩៧៧ ។ ជាមួយនោះ គាត់ក៏រៀបរាប់អំពីជីវភាពដ៏លំបាក តោកយ៉ាករបស់ម្តាយខ្ញុំដែលនៅរស់រានមានជីវិតនៅឡើយ ។ សេចក្តីក្នុងសំបុត្រ បានជំរុញខ្ញុំឲ្យប្តេជ្ញាចិត្តធ្វើពលីកម្មគ្រប់យ៉ាងដើម្បីសេរីភាព ។ ឃ្លាដ៏សំខាន់ក្នុងសំបុត្រនោះសរសេរថា "រាល់ៗយប់ តាំងពីពេលភ្នំពេញត្រូវដួលរលំមក ទោះជាត្រូវជន្លៀសដោយបង្ខំឲ្យទៅរស់នៅឯស្រែក៏ដោយ ក៏ពុក (ឪពុករបស់ខ្ញុំ) នៅតែថ្វាយបង្គំព្រះបន់ស្រន់ឲ្យព្រះអង្គជួយថែរក្សាប្អូន (ខ្ញុំ) ឲ្យបានសេចក្តីសុខគ្រប់ប្រការ ដើម្បីឲ្យប្អូន (ខ្ញុំ) អាចជួយរំដោះពួកយើងចេញពីអំណាចផ្តាច់ការរបស់ពួកខ្មែរក្រហម" ។ សេចក្តីនៃសំបុត្រនេះ មានន័យពិតប្រាកដជាសេចក្តីអំពាវនាវសុំឲ្យជួយយកអាសារអាយុជីវិត និង ជួយរំដោះពួកគេឲ្យមានសេរីភាពឡើងវិញ ។

# ធាតុពិតនៃជ័យជំនះ ៧ មករា

ដោយសារមនុស្សមិនអាចរស់នៅបានដោយខ្វះសេចក្តីថ្លៃថ្នូរ ដោយសេចក្តីថ្លៃថ្នូរមិនអាចកើតមានដល់មនុស្សបាន បើមនុស្សស្ថិតនៅជាទាសករនោះ ទាំងនេះក៏ជាកត្តាដ៏ចម្បងដែលជំរុញមនុស្ស ឲ្យធ្វើការរើបំរះរំដោះខ្លួនឲ្យមានសេរីភាព ។ សេរីភាព និង សេចក្តីថ្លៃថ្នូរ ជាវត្ថុធាតុធម្មជាតិរបស់មនុស្ស ដែលគេនាំមកជាមួយតាំងពីកំណើតរហូតដល់ពេលគេអស់ជីវិតលាចាកលោកនេះ ដោយគ្មាននរណាអាចឆក់ប្លន់ ឬ បង្ខំដកហូតបានឡើយ ។ របបប្រល័យពូជសាសន៍របស់ ប៉ុល ពត មិនគ្រាន់តែបានយកប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសជាទាសកររបស់ខ្លួនតែប៉ុណ្ណោះទេ តែពួកគេបានយកការកាប់សម្លាប់ជនរួមជាតិឯង ជាវិធីការពារអំណាចរបស់ខ្លួនទៀតផង ។ អ្វីដែល ប៉ុល ពត ប្រកាសថាគេធ្វើនយោបាយដើម្បីបំរើផលប្រយោជន៍ប្រជាជន និង ប្រជាជាតិខ្មែរនោះ ក៏ប្រែក្លាយទៅជាមហាវិនាសកម្មដ៏ធំធេងចំពោះជាតិមាតុភូមិទាំងមូលទៅវិញ ។ មហន្តរាយដែលបង្កើតឡើងដោយ ប៉ុល ពត នៅពេលនោះ មិនអាចបញ្ចប់បានឡើយ បើមិនផ្តួលរំលំរបបប្រល័យពូជសាន៍នេះ ឲ្យទាន់ពេលវេលាទេ និង ដោយប្រើគ្រប់មធ្យោបាយទេនោះ ។ មធ្យោបាយនោះមានរួមទាំងការពឹងពាក់កម្លាំងបរទេសឲ្យជួយគាំទ្រផង ។ ការតស៊ូប្រឆាំង ប៉ុល ពត ក៏លេចចេញឡើងតាមច្រើនរូបភាព ដោយចំហរក៏មាន ដោយសម្ងាត់ក៏មាន ។ កម្លាំងតស៊ូខ្លះរត់ទៅទិសខាងលិច រកជំនួយពីថៃ ។ កម្លាំងតស៊ូខ្លះរត់ទៅទិសខាងកើត រកជំនួយពីវៀតណាម ។ កម្លាំងតស៊ូដែលរត់ទៅទិសខាងលិច ឯទល់ដែនខ្មែរ-ថៃ នឹកសង្ឃឹមថាថៃអាចជួយផ្តួលរំលំ ប៉ុល ពត បាន ។ ក៏ប៉ុន្តែ នៅក្នុងបរិបទនយោបាយតំបន់នាសម័យនោះ ថៃមិនហ៊ានចេញមុខជួយវាយខ្មែរក្រហម ឲ្យដួលរលំបានឡើយ ព្រោះនៅពីក្រោយពួកប្រល័យពូជសាសន៍នេះមានចិនឈរជាបង្អែក

ដ៏រឹងមាំ ។ ផ្ទុយទៅវិញ អ្នកតស៊ូដែលរត់ទៅពឹងវៀតណាម មានលទ្ធភាពវាយផ្តួលរំលំច្រើនជាង ដោយសារ ប៉ុល ពត បានយកវៀតណាមជាសត្រូវសួរពូជផង និង បានបង្កទំនាស់ទល់ដែនជាញឹកញាប់ រហូតដល់មានសង្គ្រាមទ្រង់ទ្រាយធំរវាងគ្នា និង គ្នាទៀតផង ។ ជាមួយគ្នានោះ វៀតណាមក៏មានទំនាស់ជាមួយចិនយ៉ាងខ្លាំងក្លាដែរ ។ នៅទីបំផុតវៀតណាម ក៏បានលើកទ័ពមកជួយវាយផ្តួលរំលំរបប ប៉ុល ពត នៅថ្ងៃទី ៧ មករា ១៩៧៩ ។ ក៏ប៉ុន្តែ ដោយសារអរិភាពអស់រយៈច្រើនសតវត្សមកហើយរវាងខ្មែរ និង វៀតណាមនោះ អន្តរាគមន៍របស់កងទ័ពនៃប្រទេសជិតខាងនេះ ក៏ត្រូវបានប្រជាពលរដ្ឋខ្មែរមួយចំនួន ជាពិសេសជនភៀសខ្លួនខ្មែរនៅក្រៅប្រទេសមានការសង្ស័យ និង ចោទប្រកាន់ថាជាការរំលោភឈ្លានពានកម្ពុជាទៅវិញ ។ ព្រឹត្តិការណ៍ទាំងឡាយ ដែលបានកើតឡើងជាហូរហែ បានបញ្ជាក់ឲ្យឃើញថា បើគ្មានអំពើប្រល័យពូជសាសន៍ដ៏សាហាវអស្ចារ្យរបស់ ប៉ុល ពត ទេ អ្វីដែលត្រូវចោទប្រកាន់ថាជាអំពើឈ្លានពានរបស់វៀតណាមមកលើកម្ពុជា ក៏ប្រាកដជាពុំអាចកើតមានបានឡើយ ។

ទៅតាមចលនាវិលចុះវិលឡើងនៃប្រវត្តិសាស្ត្រកម្ពុជានាសម័យនោះ ការស្វែងរកសេរីភាពប្រាកដជាគ្មានពណ៌សម្បុរនយោបាយឡើយ ។ ទាំងអ្នករត់ទៅលិច ទាំងអ្នករត់ទៅកើតសុទ្ធតែមានបំណងចង់ជួយយកអាសាអាយុជីវិតប្រជាពលរដ្ឋខ្មែរ ពីរបបប្រល័យពូជសាសន៍ទាំងអស់ ។ ក៏ប៉ុន្តែ កម្លាំងខាងកើត មានលទ្ធភាព និង មានប្រសិទ្ធភាពជាង ។ ពួកយើងដែលនៅក្នុងយុវវ័យ នាសម័យនោះ សុទ្ធតែមានបេះដូងពុះកញ្ជ្រោលទៅដោយសេចក្តីស្នេហាជាតិ និង ការស្រែកឃ្លានរកសេរីភាព ។ ក៏ប៉ុន្តែ បន្ទាប់ពីការដួលរលំនៃរបបប្រល័យពូជសាសន៍មក សកម្មភាពនយោបាយរបស់យើងម្នាក់ៗ ស្ថិតនៅក្នុងបរិបទនៃសង្គ្រាមត្រជាក់ផង និង ជម្លោះនៅក្នុងតំបន់ផង ។ ដូច្នេះហើយ សេចក្តីស្នេហាជាតិរបស់យើង ជួនកាលវិល

បញ្ច្រាសទិសគ្នាទៅវិញទៅតាមបក្សសម្ព័ន្ធ ឬ ប្លុកនយោបាយដែលយើងឈរជើង។